ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

## ស្តីពីការសិក្សាបឋមលើយន្តការសម្របសម្រួលកិច្ចការពារកុមារ
## ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

សិក្សាដោយអគ្គលេខាធិការដ្ឋាន
ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ឆ្នាំ២០១៩

# អារម្ភកថា

ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់រាជរដ្ឋាភិបាល ប្រទេសកម្ពុជាមានការអភិវឌ្ឍនិងសម្រេចបានសមិទ្ធផលធំៗជាច្រើន ជាក់ស្តែង កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាជាង ៧% ក្នុងមួយឆ្នាំ ធ្វើឱ្យអត្រានៃភាពក្រីក្រដែលត្រូវបានវាស់វែងឃើញថាប្រមាណ ៥៣,៥% ក្នុងឆ្នាំ២០០៤ បានធ្លាក់ចុះមកនៅ ១៣,៥% នៅឆ្នាំ២០១៤ និងបន្តធ្លាក់ចុះក្រោម ១០% នៅឆ្នាំ២០១៨ និងមានគោលបំណងប្រែក្លាយឋានៈរបស់កម្ពុជាឱ្យទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងទៅប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ រាជរដ្ឋាភិបាលបានកំណត់នូវចក្ខុវិស័យរយៈពេលវែងសម្រាប់ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គមគឺ ការកសាងប្រព័ន្ធគាំពារសង្គមប្រកប ដោយបរិយាប័ន្ន ប្រសិទ្ធភាព និងចីរភាពហិរញ្ញវត្ថុដែលជាឧបករណ៍បម្រើដល់ការកាត់បន្ថយ និងទប់ស្កាត់ភាពក្រីក្រ ភាពងាយរងគ្រោះ និងវិសមភាព ហើយរួមចំណែកដល់ការអភិវឌ្ឍ និងគាំពារធនធានមនុស្សកាន់តែទូលំទូលាយ និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។

កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១ រដ្ឋទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ មាត្រា៤៨ រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានភាពមានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងកាងារទាំងឡាយណាដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។

រាជរដ្ឋាភិបាលបានចងក្រងបង្កើត លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ គោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការមួយចំនួនដែលពាក់ព័ន្ធនឹងកិច្ចការពារកុមារ និងបានបង្កើតយន្តការសម្របសម្រួលកិច្ចការពារកុមារដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័ន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រាជធានី ខេត្ត រួមទាំងបានបង្កើតគណៈកម្មាធិការពាក់ព័ន្ធមួយចំនួនជួយដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញា ពិធីសាររបស់អង្គការសហប្រជាជាតិ និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ បច្ចុប្បន្នយន្តការទាំងនេះ ជាពិសេសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងគណៈកម្មការការពារកុមារថ្នាក់ជាតិ ទាមទារការសិក្សាស្រាវជ្រាវបន្ថែម ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងព័ត៌មាន ទិន្នន័យ និងប្រមូលសូចនាករនៃការអនុវត្តកិច្ចការពារកុមារឱ្យបានគ្រប់ជ្រុងជ្រោយ។

ដូច្នេះហើយ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបង្កើតក្រុមការងារដែលមានទីប្រឹក្សាបច្ចេកទេស ធ្វើការសិក្សាបឋមលើយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបច្ចុប្បន្នដើម្បីធ្វើផែនទី និងផ្តល់ជាជម្រើសឱ្យថ្នាក់ដឹកនាំទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ជ្រើសរើសសម្រាប់ពង្រឹងកិច្ចការពារកុមារប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព។ លទ្ធផលនៃការសិក្សាស្រាវជ្រាវនេះនឹងជួយផ្តល់ឱ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ជាពិសេសអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រាជធានី ខេត្ត និងអ្នកពាក់ព័ន្ធអាចយកទៅវិភាគ មុខងារ និងពង្រឹងយន្តការសម្របសម្រួលកិច្ចការពារកុមារជាពហុវិស័យប្រកបដោយប្រសិទ្ធភាព និងមាននិរន្តរភាព។

ខ្ញុំក៏សូមថ្លែងអំណរគុណដល់អង្គការយូនីសេហ្វ អង្គការភ្លែនអន្តរជាតិ និងអង្គការសកម្មភាពដើម្បីកុមារដែលបានផ្តល់ការគាំទ្រទាំងបច្ចេកទេស និងថវិកាដល់ការសិក្សា និងអរគុណដល់ថ្នាក់ដឹកនាំ និងសមាជិកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ប្រធាន អនុប្រធាន សមាជិកគណៈកម្មការការពារកុមារថ្នាក់ជាតិ ក្រុមការងារដើម្បីកុមារតាម

ក្រសួង ថ្នាក់ដឹកនាំ និងមន្ត្រីអគ្គលេខាធិការដ្ឋាន ក.ជ.ក ក្រុមសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រាជធានី ខេត្ត និងគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមាររាជធានី ខេត្ត ដែលបានផ្តល់ជាតុចូលដល់ការសិក្សានេះឱ្យទទួលបានជោគជ័យ។

ថ្ងៃ សុក្រ ១៣កើត ខែ បុស្ស ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២០

**ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

ទេង សុត

# មាតិកា

**អារម្ភកថា**… i

**មាតិកា**…… iii

**១. សេចក្តីផ្តើម** ១

**១.១. គោលបំណង** ២

**១.២. វិធីសាស្ត្រ** ២

១.២.១.ការពិនិត្យឯកសារពាក់ព័ន្ធ ២

១.២.២.ការប្រមូលព័ត៌មាន ២

១.២.៣.ការរៀបចំសិក្ខាសាលា និងកិច្ចប្រជុំក្រុមការងារ ៣

**១.៣. ដែនកំណត់** ៣

**២. បរិបទនៃការបង្កើតយន្តការសម្របសម្រួលកិច្ចការពារកុមារ** ៣

**៣. ការធ្វើផែនទីយន្តកាសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ** ៥

**៣.១. យន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ** ៥

៣.១.១. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ៥

៣.១.២. អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ៧

៣.១.៣. អនុគណៈកម្មការចំណុះក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ៧

៣.១.៤. ក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន ៧

៣.១.៥. គណៈកម្មាធិការពាក់ព័ន្ធដឹកនាំ និងសម្របសម្រួលដោយក្រសួង ស្ថាប័ន ៨

*ក.គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ "គ.ជ.ព"* ៩

*ខ.គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច "គ.ជ.គ.ក"* ១០

*គ.គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស "គ.ជ.ប.ជ"* ១១

*ឃ.គណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះ អំពើហិង្សាលើកុមារ* ១២

*ង.គណៈកម្មការការពារកុមារថ្នាក់ជាតិ* ១៣

*ច.គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា "គ.ស.ម.ក"* ១៣

*ឆ.គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម "គ.ជ.ប.ទ"* ១៤

**៣.២. ការរកឃើញ និងអនុសាសន៍សម្រាប់យន្តការថ្នាក់ជាតិ** ១៧

**៣.៣. ជម្រើសយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ** ១៩

៣.៣.១.ជម្រើសទី១៖ពង្រឹងសមត្ថភាពផ្នែកការការពារកុមារនិងពិនិត្យតាមដាន ១៩

៣.៣.២.ជម្រើសទី២៖បង្កើតក្រុមការងារកិច្ចការពារកុមារ ២០

៣.៣.៣.ជម្រើសទី៣៖ស្នើសុំថ្នាក់ដឹកនាំជាន់ខ្ពស់១រូបដឹកនាំយន្តការកិច្ចការពារកុមារថ្នាក់ជាតិ ២២

**៤. ការធ្វើផែនទីយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ក្រោមជាតិ** ........ ២៤
**៤.១. យន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ក្រោមជាតិ** ........ ២៤
៤.១.១. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី ខេត្ត ........ ២៤
៤.១.២. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ រាជធានី ខេត្ត ........ ២៥
៤.១.៣. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ក្រុង ស្រុក ខណ្ឌ ........ ២៦
៤.១.៤. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ........ ២៧
៤.១.៥. យន្តការសម្របសម្រួលកិច្ចការពារកុមារពាក់ព័ន្ធថ្នាក់ក្រោមជាតិ ........ ៣០
**៤.២. ការរកឃើញ និងអនុសាសន៍សម្រាប់យន្តការថ្នាក់ក្រោមជាតិ** ........ ៣២
**៤.៣. ជម្រើសសម្រាប់យន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ក្រោមជាតិ** ........ ៣៤
៤.៣.១.ជម្រើសទី១៖ពង្រឹងសមត្ថភាពលេខាធិការដ្ឋាន ក.ជ.ក រាជធានី ខេត្ត ........ ៣៤
៤.៣.២.ជម្រើសទី២៖ស្នើសុំអភិបាលរាជធានី ខេត្តជាប្រធានយន្តការថ្នាក់ក្រោមជាតិ ........ ៣៥
**៥. សិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ** ........ ៣៦
**៥.១. លទ្ធផលសិក្ខាសាលាថ្នាក់ក្រោមជាតិ** ........ ៣៦
**៥.២. លទ្ធផលសិក្ខាសាលាថ្នាក់ជាតិ** ........ ៣៧
**៦. សេចក្តីសន្និដ្ឋាន** ........ ៣៩
**ឧបសម្ព័ន្ធ** ........ ៤០

# ១. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតយន្តការសម្របសម្រួលកិច្ចការពារកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីដោះស្រាយបញ្ហាមុខសញ្ញានីមួយៗសម្រាប់គាំទ្រដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ យន្តការសម្របសម្រួលកិច្ចការពារកុមារនៅថ្នាក់ជាតិមាន៖ ១.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ២.ក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័ន ៣.គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ ៤.គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ៥.គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច ៦.គណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ៧.គណៈកម្មការការពារកុមារថ្នាក់ជាតិ ៨.គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និង៩.គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម។ ចំណែកឯយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ក្រោមជាតិមាន៖ ១.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានីខេត្ត ២.គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររាជធានីខេត្ត ៣.គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ក្រុង ស្រុក ខណ្ឌ ៤.គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ ៥.គណៈកម្មការប្រឆាំងពលកម្មកុមាររាជធានីខេត្ត ៦.គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី(គ.រ.ប.ជ) គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត(គ.ខ.ប.ជ) និង៧.យន្តការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ក្រោមជាតិ។

យន្តការសម្របសម្រួលដែលបានបង្កើតខាងលើគឺដើម្បីអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ អនុសញ្ញានិងពិធីសាររបស់អង្គការសហប្រជាជាតិពាក់ព័ន្ធ និងមាត្រា ៤៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មានដូចជាការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក) ធ្វើជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការងារទាក់ទងនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព និងការចូលរួមចំណែករបស់កុមារ។ បន្ថែមពីនេះគឺត្រូវធ្វើការផ្សព្វផ្សាយ និងពិនិត្យតាមដានការអនុវត្តសិទ្ធិរបស់កុមារ និងធ្វើរបាយការណ៍ស្តីពីស្ថានភាពកុមារជូនរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ។ ដោយពិនិត្យឃើញវិលាសភាពនៃកិច្ចការពារកុមារពាក់ព័ន្ធជាពហុវិស័យ ទើប ក.ជ.ក. បានបង្កើតគណៈកម្មការការពារកុមារថ្នាក់ជាតិ ដើម្បីសម្របសម្រួលនិងសហការជាមួយក្រសួងស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍពាក់ព័ន្ធ និងផ្នែកឯកជនក្នុងគោលបំណងពង្រឹងប្រព័ន្ធការពារកុមារ ដើម្បីបង្កាទប់ស្កាត់ ការពារ និងលុបបំបាត់រាល់ទម្រង់នៃការរំលោភបំពានផ្សេងៗ និងអំពើហិង្សាលើកុមារសំដៅបម្រើឧត្តមប្រយោជន៍កុមារ។ ចំណែកឯយន្តការពាក់ព័ន្ធផ្សេងទៀតគឺដើម្បីទទួលខុសត្រូវលើមុខសញ្ញាជាក់លាក់ដូចជា ប្រឆាំងពលកម្មកុមារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម។ល។

ទោះបីជាមានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងគណៈកម្មការការពារកុមារថ្នាក់ជាតិដែលដើរតួនាទីក្នុងការត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ និងសម្របសម្រួលកិច្ចការពារកុមារជាមួយនឹងក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលនានា ប៉ុន្តែយន្តការទាំងនេះមិនទាន់មានលទ្ធភាពក្នុងប្រមូលព័ត៌មាននិងទិន្នន័យស្តីពីកិច្ចការពារកុមារដើម្បីធ្វើរបាយការណ៍ស្តីពីស្ថានភាពកុមារជូនរាជរដ្ឋាភិបាលនិងអង្គការសហប្រជាជាតិ។ បន្ថែមពីនេះទៀតមិនទាន់មានប្រព័ន្ធសម្របសម្រួលជាពហុវិស័យ ជាមួយអ្នកពាក់ព័ន្ធនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងខ្វះនីតិវិធីក្នុងប្រមូលព័ត៌មានស្តីពីស្ថានភាពការអនុវត្តសិទ្ធិនិងកិច្ចការពារកុមារ រួមទាំងការវិភាជថវិការបស់រដ្ឋមានកម្រិតធ្វើឱ្យយន្តការដែលបានបង្កើតឡើងមិនអាចបំពេញតួនាទីភារកិច្ចរបស់ខ្លួន។

## ១.១. គោលបំណង

គោលបំណងនៃការសិក្សាបឋមលើយន្តការសម្របសម្រួលកិច្ចការពារកុមារមានបច្ចុប្បន្ន ដើម្បីកំណត់និងវិភាគសម្រាប់ផ្តល់ជាជម្រើសធ្វើការកែលម្អឱ្យកាន់តែមានប្រសិទ្ធភាពនិងមាននិរន្តរភាព។ គោលបំណងជាក់លាក់ក្នុងការសិក្សាគឺ៖

- ពិនិត្យមើលលិខិតបទដ្ឋានគតិយុត្ត និងធ្វើផែនទីយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីកំណត់វិសាលភាពការងារ និងអត្តសញ្ញាណមន្ត្រីជាន់ខ្ពស់ ដើម្បីដឹកនាំយន្តការសម្របសម្រួលកិច្ចការពារកុមារជាពហុវិស័យ។
- ផ្តល់ជម្រើសពីរទៅបីសម្រាប់កែលម្អយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដោយផ្អែកលើយន្តការមានស្រាប់។
- ផ្តល់ការគាំទ្រដល់យន្តការដែលបានជ្រើសរើសដើម្បីឱ្យមានលទ្ធភាពសម្របសម្រួល ពិនិត្យតាមដាន និងប្រមូលព័ត៌មានស្តីពីការអនុវត្តសិទ្ធិកុមារសម្រាប់រៀបចំរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំ និងជាទិន្នន័យសម្រាប់តស៊ូមតិបង្កើនកម្លាំងសេវាសង្គម ការវិភាជថវិកាជាតិ និងកៀរគរជំនួយទាំងថវិកា និងបច្ចេកទេសសម្រាប់គាំទ្រវិស័យកិច្ចការពារកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ១.២. វិធីសាស្ត្រ

ការសិក្សាបឋមនេះបានប្រើវិធីសាស្ត្របីប្រភេទគឺ៖ ១.ពិនិត្យឯកសារពាក់ព័ន្ធយន្តការសម្របសម្រួលកិច្ចការពារកុមារ ២.ចុះជួបអ្នកពាក់ព័ន្ធដើម្បីប្រមូលព័ត៌មាន និង៣.រៀបចំសិក្ខាសាលានៅថ្នាក់ក្រោមជាតិនិងនៅថ្នាក់ជាតិ រួមទាំងការប្រជុំក្រុមការងារ។

### ១.២.១.ការពិនិត្យឯកសារពាក់ព័ន្ធ

ការពិនិត្យឯកសារផ្តោតលើ ក).ព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្តីសម្រេចពាក់ព័ន្ធនឹងការបង្កើតយន្តការសម្របសម្រួលកិច្ចការពារកុមារ ខ).សូចនាករ និងឯកសារពាក់ព័ន្ធ និងគ).ប្រភពធនធានគាំទ្រដល់យន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### ១.២.២.ការប្រមូលព័ត៌មាន

ក្រុមសិក្សាស្រាវជ្រាវបានចុះជួបប្រជុំ និងពិភាក្សាជាមួយ ក.ជ.ក និង គ.ក.ស.ក ខេត្តចំនួន៩ រួមមាន៖ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តត្បូងឃ្មុំ ខេត្តរតនៈគីរី ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តស្វាយរៀង ស្មើនឹង៣៦ភាគរយ នៃរាជធានីខេត្តទាំង២៥ ដែលមានសមាជិកចូលរួមចំនួន២០៣នាក់។ ក្រុមការងារបានជួបសម្ភាសន៍ផ្ទាល់ជាមួយអ្នកពាក់ព័ន្ធចំនួន៣៥នាក់ ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៅតាមក្រសួងស្ថាប័ន និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងបរទេស។

*តារាងទី១៖ ចំនួនអ្នកចូលរួមប្រជុំពិភាក្សានៅតាមខេត្តគោលដៅ*

| ល.រ | ឈ្មោះខេត្ត | ក.ជ.ក | | គ.ក.ស.ក | | សរុបរួម នាក់ | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | | |
| ១ | បាត់ដំបង | ១០ | ៥ | ១០ | ៧ | **២០** | ប្រជុំផ្សេងគ្នា |
| ២ | បន្ទាយមានជ័យ | ២៩ | ១២ | ៩ | ៧ | **៣៨** | ប្រជុំផ្សេងគ្នា |
| ៣ | សៀមរាប | ១៦ | ៩ | | | **១៦** | ប្រជុំរួមគ្នា តំណាងទាំងពីរ |
| ៤ | ត្បូងឃ្មុំ | ១៥ | ៤ | | | **១៥** | ប្រជុំរួមគ្នា តំណាងទាំងពីរ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | រតនគីរី | ១៣ | ៥ | | | **១៣** | ប្រជុំរួមគ្នា តំណាងទាំងពីរ |
| ៦ | ព្រះសីហនុ | ២៥ | ១០ | ៩ | ៤ | **៣៤** | ប្រជុំផ្សេងគ្នា |
| ៧ | កំពត | ៣៥ | ១៤ | | | **៣៥** | ប្រជុំផ្សេងគ្នា តំណាងទាំងពីរ |
| ៨ | កំពង់ស្ពឺ | ១៦ | ៦ | | | **១៦** | ប្រជុំផ្សេងគ្នា តំណាងទាំងពីរ |
| ៩ | ស្វាយរៀង | ១៦ | ១១ | | | **១៦** | ប្រជុំផ្សេងគ្នា តំណាងទាំងពីរ |
| សរុប | | | | | | **២០៣** | |

### ១.២.៣.ការរៀបចំសិក្ខាសាលា និងកិច្ចប្រជុំក្រុមការងារ

អគ្គលេខាធិការដ្ឋាន ក.ជ.ក. បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិស្តីពីការសិក្សាបឋមលើយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ នៅសណ្ឋាគារខេមរាអង្គរខេត្តសៀមរាប ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ ដើម្បីពិនិត្យ និងកែសម្រួលសេចក្តីព្រាងទី១ មានអ្នកចូលរួមចំនួន១១៤នាក់ (ស្រី៥៦នាក់) ដែលជាប្រធាន ក.ជ.ក. ប្រធាន គ.ក.ស.ក. ប្រធាន/អនុប្រធានមន្ទីរ ស.អ.យ ទូទាំង២៥រាជធានីខេត្តនិងមន្ត្រីអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ។ រៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ដើម្បីពិនិត្យ និងកែសម្រួលសេចក្តីព្រាងទី២ មានអ្នកចូលរួមចំនួន៧៧នាក់ (ស្រី៣៣នាក់) ដែលជាប្រធាន អនុប្រធាន សមាជិកគណៈកម្មការការពារកុមារថ្នាក់ជាតិ ក្រសួង ស្ថាប័ន និងអង្គការមិនមែនរដ្ឋាបាលពាក់ព័ន្ធ។ ក្រុមកាងាររៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងកែសម្រួលសេចក្តីព្រាងទី២ ដាក់ជូនថ្នាក់ដឹកនាំ ក.ជ.ក. ដើម្បីពិនិត្យ និងសម្រេច។

## ១.៣. ដែនកំណត់

ការសិក្សានេះផ្តោតលើយន្តការកិច្ចការពារកុមារនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលមានសុពលភាពនាពេលបច្ចុប្បន្ននៅថ្នាក់ជាតិមានៈ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អគ្គលេខាធិការដ្ឋាន អនុគណៈកម្មការទាំងបួន ក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន រួមទាំងគណៈកម្មការ និងគណៈកម្មាធិការពាក់ព័ន្ធ។ នៅថ្នាក់ក្រោមជាតិមានៈក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានីខេត្ត គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ (គ.ក.ស.ក) រាជធានីខេត្ត គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ (គ.ក.ស.ក) ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ (គ.ក.ន.ក) និងគណៈកម្មការប្រឆាំងពលកម្មកុមាររាជធានីខេត្ត គណៈកម្មាធិការរាជធានីខេត្ត គរបជ/គខបជ និងយន្តការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ ក្រោមជាតិ។ ទិន្នន័យនៃការសិក្សានេះផ្តោតលើព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស សេចក្តីសម្រេចនិងឯកសារពាក់ព័ន្ធនិងប្រមូលព័ត៌មានពីសមាជិក ក.ជ.ក និងគ.ក.ស.ក រាជធានីខេត្តអ្នកពាក់ព័ន្ធនានា និងការផ្តល់ធាតុចូលពីអ្នកចូលរួមសិក្ខាសាលានៅខេត្តសៀមរាប និងរាជធានីភ្នំពេញ ចន្លោះខែមិថុនា និងខែកញ្ញា ឆ្នាំ២០១៩។

# ២. បរិបទនៃការបង្កើតយន្តការសម្របសម្រួលកិច្ចការពារកុមារ

សេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមារដែលប្រកាសឡើងដោយសេចក្តីសម្រេចចិត្តលេខ១៣៨៦(XIV)របស់មហាសន្និបាតអង្គការសហប្រជាជាតិចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ហើយដែលកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ មាត្រា៤៨ រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិ

ទទួលបានការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានភាពមានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ។ រដ្ឋគាំពារប្រឆាំងនឹងកាងារទាំងឡាយណាដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។

ដើម្បីអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនិងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានរៀបចំបង្កើតច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយមួយចំនួនពាក់ព័ន្ធសិទ្ធិកុមារ និងបានបង្កើតយន្តការសម្របសម្រួលកិច្ចការពារកុមារទាំងនៅថ្នាក់ជាតិនិងនៅថ្នាក់ក្រោមជាតិ។[1] យន្តការនៅថ្នាក់ជាតិមានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលមានអគ្គលេខាធិការដ្ឋាន និងអនុគណៈកម្មការ ចំណែកនៅតាមក្រសួង ស្ថាប័ន បានបង្កើតក្រុមការងារដើម្បីកុមារ រួមទាំងគណៈកម្មាធិការមួយចំនួន។ ទន្ទឹមនឹងនេះនៅថ្នាក់ក្រោមជាតិ បានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក) រាជធានីខេត្ត គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ(គ.ក.ស.ក) រាជធានី ខេត្ត គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារ(គ.ក.ស.ក) ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារ (គ.ក.ន.ក) ឃុំសង្កាត់ ហើយក៏បានបង្កើតគណៈកម្មការប្រឆាំងពលកម្មកុមាររាជធានីខេត្ត គណៈកម្មាធិការរាជធានីខេត្ត គរបជ/គខបជ និងយន្តការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ក្រោមជាតិ ដែលជាខ្សែបណ្តោយរបស់គណៈកម្មាធិការនៅថ្នាក់ជាតិ។

*រូបភាពទី១៖ គំនូសបំព្រួញយន្តការសម្របសម្រួលកិច្ចការពារកុមារនៅកម្ពុជា*




[1] មាត្រា ៤៤ អនុសញ្ញាស្តីពីសិទ្ធិកុមារ បញ្ជាក់ថារដ្ឋភាគីត្រូវរាយការណ៍ពីស្ថានភាពសិទ្ធិកុមារជូនគណៈកម្មាធិការ អង្គការសហប្រជាជាតិ។

## ៣. ការធ្វើផែនទីយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ

## ៣.១. យន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ

### ៣.១.១. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក) នៅឆ្នាំ១៩៩៥[2] ហើយនៅចុងឆ្នាំ ២០០៩បានកែសម្រួលរចនាសម្ព័ន្ធ[3] និងសមាសភាពជាបន្តបន្ទាប់[4]។ សមាសភាព ក.ជ.ក មានសម្តេចនាយករដ្ឋមន្ត្រី ជាប្រធានកិត្តិយស និងឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធានក.ជ.ក ដោយឡែក អនុប្រធាន សមាជិក ក.ជ.ក. ជារដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ មកពីក្រសួងស្ថាប័នពាក់ព័ន្ធ។ ក.ជ.ក មាន អង្គភាពជំនាញជាសេនាធិការដូចជា៖ ១.អគ្គលេខាធិការដ្ឋាន ២.ក.ជ.ក រាជធានីខេត្ត ៣.ក្រុមការងារដើម្បីកុមារ ក្រសួង ស្ថាប័ន និងមានអនុគណៈកម្មការដូចជា៖ ១.អនុគណៈកម្មការពលកម្មកុមារនិងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗ ទៀតលើកុមារ ២.អនុគណៈកម្មការប្រឆាំងការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ៣.អនុគណៈកម្មការតាក់តែង ច្បាប់ដែលពាក់ព័ន្ធនឹងកុមារ និង៤.អនុគណៈកម្មការអភិវឌ្ឍន៍កុមារតូច។ អនុគណៈកម្មការទាំង៤ត្រូវបានប្រែក្លាយ ទៅជាគណៈកម្មាធិការដឹកនាំដោយក្រសួង ស្ថាប័នពាក់ព័ន្ធ។

*រូបភាពទី២៖ អង្គការលេខរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ*




[2] អនុក្រឹត្យលេខ៨៣ អនក្រ.បក ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក.ក

[3] ព្រះរាជក្រឹត្យលេខនស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

[4] អនុក្រឹត្យលេខ ៣៨២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤ ស្តីពីការតែងសមាសភាព ក.ជ.ក និងអនុក្រឹត្យលេខ ៤១៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

*តារាងទី២៖សមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ*[5]

| ល.រ | ក្រសួង-ស្ថាប័ន | មុខតំណែង | តួនាទីនៅក្នុង ក.ជ.ក |
|---|---|---|---|
| ១ | សម្តេចប្រមុខរាជរដ្ឋាភិបាលកម្ពុជា | នាយករដ្ឋមន្ត្រី | ប្រធានកិត្តិយស |
| ២ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | រដ្ឋមន្ត្រី | ប្រធាន ក.ជ.ក |
| ៣ | កិច្ចការនារី | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤ | មហាផ្ទៃ | រដ្ឋលេខាធិការ | អនុប្រធាន |
| ៥ | សុខាភិបាល | រដ្ឋលេខាធិការ | អនុប្រធាន |
| ៦ | អប់រំ យុវជន និងកីឡា | រដ្ឋលេខាធិការ | អនុប្រធាន |
| ៧ | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | រដ្ឋលេខាធិការ | អនុប្រធាន |
| ៨ | សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | រដ្ឋលេខាធិការ | អនុប្រធាន |
| ៩ | ទីស្តីការគណៈរដ្ឋមន្ត្រី | អនុរដ្ឋលេខាធិការ | សមាជិក |
| ១០ | ការពារជាតិ | អនុរដ្ឋលេខាធិការ | សមាជិក |
| ១១ | ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុរដ្ឋលេខាធិការ | សមាជិក |
| ១២ | សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៣ | ពាណិជ្ជកម្ម | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៤ | ផែនការ | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៥ | យុត្តិធម៌ | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៦ | អភិវឌ្ឍន៍ជនបទ | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៧ | វប្បធម៌ និងវិចិត្រសិល្បៈ | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៨ | សាធារណការ និងដឹកជញ្ជូន | អនុរដ្ឋលេខាធិការ | សមាជិក |
| ១៩ | បរិស្ថាន | អនុរដ្ឋលេខាធិការ | សមាជិក |
| ២០ | ប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុរដ្ឋលេខាធិការ | សមាជិក |
| ២១ | ឧស្សាហកម្ម និងសិប្បកម្ម | អនុរដ្ឋលេខាធិការ | សមាជិក |
| ២២ | រ៉ែ និងថាមពល | អនុរដ្ឋលេខាធិការ | សមាជិក |
| ២៣ | ទេសចរណ៍ | អនុរដ្ឋលេខាធិការ | សមាជិក |
| ២៤ | ព័ត៌មាន | អនុរដ្ឋលេខាធិការ | សមាជិក |
| ២៥ | ធម្មការ និងសាសនា | អនុរដ្ឋលេខាធិការ | សមាជិក |
| ២៦ | គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | សមាជិក | សមាជិក |
| ២៧ | អគ្គលេខាធិការដ្ឋានកាកបាទក្រហមកម្ពុជា | អគ្គលេខាធិការ | សមាជិក |
| ២៨ | អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | អគ្គលេខាធិការរង | សមាជិក |
| ២៩ | អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន | អគ្គលេខាធិការរង | សមាជិក |
| ៣០ | អគ្គលេខាធិការដ្ឋាន ក.ជ.ក | អគ្គលេខាធិការ | សមាជិកអចិន្ត្រៃយ៍ |

[5] អនុក្រឹត្យលេខ ៤១៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ក.ជ.ក មានភារកិច្ច សម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលសម្រាប់ការងារពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធនឹងបញ្ហាកុមារ ពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ចូលរួមពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងកុមារ និងផ្តល់អនុសាសន៍ស្របនឹងអនុសញ្ញានិងបទដ្ឋានអន្តរជាតិផ្សេងៗស្តីពីកុមារ និងដឹកនាំអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។[6] មាត្រា ១៣ នៃព្រះរាជក្រឹត្យស្តីពីការបង្កើត ក.ជ.ក មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ដោយឡែក ក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួង ស.អ.យ និងមានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិមនុស្សធម៌ដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗ។

### ៣.១.២. អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

អគ្គលេខាធិការដ្ឋាន ក.ជ.ក[7] មាន៖ ១.ផ្នែករដ្ឋបាលផែនការ និងហិរញ្ញវត្ថុ ២.ផ្នែកការពារកុមារនិងពិនិត្យតាមដាន និង៣.ផ្នែកអប់រំផ្សព្វផ្សាយ និងអភិវឌ្ឍធនធានមនុស្ស មានភារកិច្ចរៀបចំ និងអនុវត្តផែនការ សម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារនានា ពិនិត្យតាមដានស្ថានភាពកុមារ ជំរុញការផ្សព្វផ្សាយខ្លឹមសារអនុសញ្ញាស្តីពីសិទ្ធិកុមារ សិក្សាស្រាវជ្រាវច្បាប់ជាតិ អន្តរជាតិ និងលិខិតបទដ្ឋានគតិយុត្ត សហប្រតិបត្តិការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ តំណាងកុមារ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសព្រមទាំងដៃគូអភិវឌ្ឍ។ រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក មើលរូបភាពទី១.អង្គការលេខរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

### ៣.១.៣. អនុគណៈកម្មការចំណុះក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបង្កើតអនុគណៈកម្មការចំនួនបួនគឺ៖ ១.អនុគណៈកម្មការពលកម្មកុមារ និងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតលើកុមារ[8] ២.អនុគណៈកម្មការប្រឆាំងការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ[9] ៣.អនុគណៈកម្មការតាក់តែងច្បាប់ដែលពាក់ព័ន្ធនឹងកុមារ[10] និង៤.អនុគណៈកម្មការអភិវឌ្ឍន៍កុមារតូច[11]។ អនុគណៈកម្មការទាំងបួននេះមិនបានអនុវត្តភារកិច្ចដូចមានចែងនៅក្នុងសេចក្តីសម្រេចទេ ប៉ុន្តែរាជរដ្ឋាភិបាលក៏បានបង្កើតគណៈកម្មាធិការមួយចំនួនដែលដឹកនាំ និងសម្របសម្រួលដោយក្រសួង ស្ថាប័នផ្ទាល់ដូចមានចែងនៅចំណុច ៣.១.៥.គណៈកម្មាធិការដឹកនាំ និងសម្របសម្រួលដោយក្រសួងពាក់ព័ន្ធ។

### ៣.១.៤. ក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន

ក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន[12]ដឹកនាំដោយរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការជាប្រធាន អគ្គនាយក១រូបជាអនុប្រធាន និងសមាជិកជាប្រធាន ឬអនុប្រធាននាយកដ្ឋានពាក់ព័ន្ធដើរតួនាទីជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារលើការងារពិគ្រោះយោបល់ និងពិនិត្យតាមដានវាយតម្លៃលើការអនុវត្តសិទ្ធិកុមារ ផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារ គោលនយោបាយ និងលិខិតដ្ឋានគតិយុត្ត

---

[6] មាត្រា៨ នៃព្រះរាជក្រឹត្យស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារឆ្នាំ២០០៩

[7] អនុក្រឹត្យលេខ០២ ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន ក.ជ.ក

[8] សេចក្តីសម្រេចលេខ៨៣ ក.ជ.ក.ក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការបង្កើតអនុគណៈកម្មការជាតិពលកម្មកុមារនិងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតលើកុមារ

[9] សេចក្តីសម្រេចលេខ១៣៩ ក.ជ.ក.ក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតអនុគណៈកម្មការប្រឆាំងការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

[10] សេចក្តីសម្រេចលេខ១៤០ ក.ជ.ក.ក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតអនុគណៈកម្មការតាក់តែងច្បាប់

[11] សេចក្តីសម្រេចលេខ១២៨ ក.ជ.ក.ក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០២ ស្តីពីការបង្កើតអនុគណៈកម្មការអភិវឌ្ឍកុមារតូច

[12] សេចក្តីសម្រេចលេខ១២៧ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័ន

នានារបស់រាជរដ្ឋាភិបាល និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ រៀបចំផែនការ កម្មវិធីនិងសកម្មភាពផ្សេងៗដើម្បីឧត្តមប្រយោជន៍របស់កុមារ និងបញ្ជ្រាបការងារកុមារទៅក្នុងកម្មវិធីរបស់ក្រសួងស្ថាប័ន និងធ្វើទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេសដែលមានគម្រោងការងារពាក់ព័ន្ធនឹងកុមារនៅក្នុងក្រសួងស្ថាប័ន ស្វែងរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ ទស្សនៈរីកចម្រើនដែលទាក់ទងនឹងគោលដៅរួមក្នុងការកែសម្ភស្ថានភាពកុមារ។ រៀបចំទិន្នន័យស្តីពីស្ថានភាពកុមារ និងចាត់ចែងអនុវត្តរាល់គោលការណ៍ និងផែនការសកម្មភាពរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

### ៣.១.៥. គណៈកម្មាធិការពាក់ព័ន្ធដឹកនាំ និងសម្របសម្រួលដោយក្រសួង ស្ថាប័ន

រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មាធិការមួយចំនួន រួមមាន៖ **ក**.គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ"គ.ជ.ព"[13] ដែលដឹកនាំនិងសម្របសម្រួលដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបានបង្កើតអគ្គលេខាធិការដ្ឋាននៃគ.ជ.ព[14] ធ្វើជាសេនាធិការ **ខ**.គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស"គ.ជ.ប.ជ"[15] ដែលដឹកនាំសម្របសម្រួលដោយក្រសួងមហាផ្ទៃនិងបានបង្កើតអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ[16] ធ្វើជាសេនាធិការ **គ**.គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច"គ.ជ.គ.ក"[17] ដែលដឹកនាំនិងសម្របសម្រួលដោយក្រសួងអប់រំ យុវជន និងកីឡា និងបានបង្កើតអគ្គលេខាធិការដ្ឋាននៃ គ.ជ.គ.ក[18]ធ្វើជាសេនាធិការ **ឃ**.គណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ[19] ដែលដឹកនិងសម្របសម្រួលដោយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា និងបានបង្កើតក្រុមការងារបច្ចេកទេសចំនួនបី រួមមាន៖១.ក្រុមការងារលើកកម្ពស់ការយល់ដឹង និងទប់ស្កាត់អំពើហិង្សាលើកុមារ ២.ក្រុមការងារផ្តល់សេវានិងអនុវត្តច្បាប់ និង៣.ក្រុមការងារសិក្សាលើបទដ្ឋានគតិយុត្ត ពិនិត្យតាមដាន និងធ្វើរបាយការណ៍ **ង**.គណៈកម្មការការពារកុមារថ្នាក់ជាតិ[20] ដឹកនាំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ **ច**.គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាដែលដឹកនាំ និងសម្របសម្រួលដោយទីស្តីការគណៈរដ្ឋមន្ត្រី[21] និង**ឆ**.គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម "គ.ជ.ប.ទ."[22] ដឹកនាំនិងសម្របសម្រួលដោយក្រសួងមហាផ្ទៃ និងបានបង្កើតលេខាធិការដ្ឋានធ្វើជាសេនាធិការ[23] ។

---

[13] ព្រះរាជក្រឹត្យលេខ នស/រកត/១១១៦/១០៤៤ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើត គ.ជ.ព

[14] អនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃ គ.ជ.ព

[15] ព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើត គ.ជ.ប.ជ

[16] អនុក្រឹត្យលេខ ២៧៣ អនក្រ.បក ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ

[17] ព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣១៧ ចុះថ្ងៃទី៤ មេសា ឆ្នាំ២០១៣ ស្តីពីការបង្កើត គ.ជ.គ.ក

[18] អនុក្រឹត្យលេខ ១៩០ អនក្រ.បក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្យទៅរបស់អគ្គលេខាធិការនៃ គ.ជ.គ.ក

[19] សេចក្តីសម្រេចលេខ ១៨៧ ស.អ.យ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មការដឹកនាំអនុវត្តផែនការ VAC

[20] សេចក្តីសម្រេចលេខ ១០៥ ក.ជ.ក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មការការពារកុមារថ្នាក់ជាតិ

[21] ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៣៦ ចុះថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា និង អនុក្រឹត្យលេខ៥៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

[22] ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៧/៦១៩ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ ស្តីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម "គ.ជ.ប.ទ"

[23] អនុក្រឹត្យលេខ២៨ អនក្រ.បក ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន នៃ គ.ជ.ប.ទ.

### ក.គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ"គ.ជ.ព"

គ.ជ.ព បង្កើតឡើងដោយព្រះរាជក្រឹត្យនៅឆ្នាំ២០១៦ ជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើសកម្មភាពជាបន្ទាន់សម្រាប់លប់បំបាត់លើទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ គ.ជ.ក ដែលមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាប្រធាន និងមានអគ្គលេខាធិការដ្ឋានជាសេនាធិការ ហើយបានបង្កើតគណៈកម្មការប្រឆាំងពលកម្មកុមាររាជធានី ខេត្ត។ មាត្រា ១៣ នៃព្រះរាជក្រឹត្យ បញ្ជាក់ថា គ.ជ.ក មានប្រភពធនធានពីថវិកាជាតិ ថវិកាដៃគូ និងប្រភពផ្សេងទៀតនៅក្នុងក្របខ័ណ្ឌថវិកា របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ ចំពោះប្រភពធនធានរបស់គណៈកម្មការប្រឆាំងពលកម្មកុមាររាជធានី ខេត្តមិនបានកំណត់ច្បាស់លាស់នៅក្នុងព្រះរាជក្រឹត្យទេ។

*រូបភាពទី៣៖ អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ព*




គោលដៅអភិវឌ្ឍន៍សកលប្រកបដោយចីរភាព(២០១៥-២០៣០) ដែលចែងអំពីការបញ្ចប់ពលកម្មកុមារនៅឆ្នាំ២០២៥ រាជរដ្ឋាភិបាលកម្ពុជា បន្តពង្រឹងយន្តការអនុវត្តច្បាប់និងអធិការកិច្ចការងារ និងសហការជាមួយអង្គការនិយោជិត និយោជក ដើម្បីដោះស្រាយករណីវិវាទពលកម្មកុមារ និងសុវត្ថិភាពការងារឱ្យបានទាន់ពេលវេលា ជាពិសេសជំរុញនិយោជកគោរពបទដ្ឋានការងារនិងការដាក់ពិន័យកម្រិតធ្ងន់សម្រាប់សហគ្រាស គ្រឹះស្ថាន ដែលប្រើប្រាស់ពលកម្មកុមារ។ ពង្រីកកិច្ចសហការអន្តរវិស័យនិងស្វែងរកដំណោះស្រាយសមស្របចំពោះបញ្ហាពលកម្មកុមារដែលមានចរិតលក្ខណៈពហុវិស័យ ដើម្បីជានាឧត្តមប្រយោជន៍របស់កុមារកម្ពុជា និងកសាងមូលធនមនុស្សស្របតាមបរិបទការងារសមរម្យ។ ជំរុញឱ្យគ្រប់ភាគីពាក់ព័ន្ធសហការគ្នា ដើម្បីធានាសុវត្ថិភាពការងារសម្រាប់កម្មករនិយោជិតវ័យក្មេងនិងអំពាវនាវសាធារណៈជនរាយការណ៍អំពីករណីពលកម្មកុមារនៅកន្លែងធ្វើការ។ ទន្ទឹមនឹងនេះ ការណែនាំដល់អាណាព្យាបាលនិងនិយោជកករណីរំលោភបំពានពលកម្មកុមារ ជាពិសេស កុមារបម្រើការងារក្នុងផ្ទះ គឺជាបទល្មើសព្រហ្មទណ្ឌដើម្បីកាត់បន្ថយការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។ ស្វែងរកការគាំទ្រធនធាននិងបច្ចេកទេស ដើម្បីស្រាវជ្រាវ និងចងក្រងប្រកាសពាក់ព័ន្ធនឹងពលកម្មកុមារនៃសកម្មភាពសេដ្ឋកិច្ចដែលវិវត្តន៍ថ្មីៗ និងយុទ្ធនាការឆ្ពោះទៅបញ្ចប់ពលកម្មកុមារនៅកម្រិតថ្នាក់ឃុំសង្កាត់។ ដើម្បីឆ្លើយតបទៅនឹងការលុបបំបាត់គ្រប់ទម្រង់នៃពលកម្មកុមារ តម្រូវឱ្យ គ.ជ.ព. ចាត់វិធានការ[24] ដូចតទៅ៖

- គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ(គ.ជ.ព.) ត្រូវបន្តសម្របសម្រួលអនុវត្តអនុសញ្ញាអន្តរជាតិ និងគោលនយោបាយជាតិពាក់ព័ន្ធនឹងពលកម្មកុមារ ជាពិសេស សហការជាមួយអន្តរក្រសួងស្ថាប័ន

[24] លោកជំទាវ ស៊ើង សរសុចិត្តា រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្លែងនៅក្នុងឱកាសទិវាកុមារអន្តរជាតិ ១មិថុនា ឆ្នាំ២០១៩ និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៩

ដើម្បីជំរុញអនុវត្តផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ឆ្នាំ២០១៦-២០២៥។

- អគ្គលេខាធិការដ្ឋាន គ.ជ.ព. និងនាយកដ្ឋានជំនាញត្រូវខិតខំពង្រឹងវិធានការអធិការកិច្ចការងារឱ្យមានប្រសិទ្ធភាព ទប់ស្កាត់គ្រោះថ្នាក់ការងារ និងភាពងាយរងគ្រោះផ្នែកសុខភាព សម្រាប់កម្មករនិយោជិតវ័យក្មេង ដើម្បីលុបបំបាត់ពលកម្មកុមារ ជាពិសេសពង្រីកវិសាលភាពការងារវិស័យសេដ្ឋកិច្ចមិនរៀបរយដូចជា កម្មករការងារផ្ទះ សិប្បកម្ម និងសេវាកម្មដទៃទៀត។
- បន្តបណ្តុះបណ្តាលពង្រឹងសមត្ថភាពគ្រប់ភាគីពាក់ព័ន្ធ និងកៀរគរធនធានហិរញ្ញវត្ថុ និងស្វែងរកការគាំទ្រពីសាធារណៈជនចូលរួមប្រឆាំងពលកម្មកុមារ។
- ពង្រីកការផ្សព្វផ្សាយ និងយុទ្ធនាការប្រឆាំងពលកម្មកុមារ និងការងារដោយបង្ខំទៅដល់មូលដ្ឋាន និងសហគមន៍នានា ដើម្បីទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ។
- ពង្រឹងកិច្ចអន្តរាគមន៍ស្ទួល ដើម្បីសង្គ្រោះពលកម្មកុមារ និងហាមឃាត់ការងារដោយបង្ខំទៅតាមប្រភេទមុខរបរ និងបង្កើនកិច្ចសហប្រតិបត្តិការក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធ ក្នុងការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារពីគ្រប់ទម្រង់។

## ខ.គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច"គ.ជ.គ.ក"

**គ.ជ.គ.ក** បង្កើតឡើងដោយព្រះរាជក្រឹត្យនៅឆ្នាំ២០១៣ ដើម្បីជាយន្តការអនុវត្តច្បាប់ស្តីពីការអប់រំ និងគោលនយោបាយជាតិស្តីពីការគាំពារនិងការអភិវឌ្ឍន៍កុមារតូច។ គ.ជ.គ.ក មានសម្តេចនាយករដ្ឋមន្ត្រីជាប្រធានកិត្តិយស រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡាជាប្រធាន និងសមាជិកមកពីក្រសួងពាក់ព័ន្ធ ដែលមានអគ្គលេខាធិការដ្ឋានជាសេនាធិការ និងបានបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសកុមារតាមវិស័យព្រមទាំងប្រើប្រាស់ គ.ក.ស.ក និង គ.ក.ន.ក។ មាត្រា១០ នៃព្រះរាជក្រឹត្យបានបញ្ជាក់ពីការចំណាយសម្រាប់ដំណើរការរបស់ គ.ជ.គ.ក ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងថវិការបស់ក្រសួងអប់រំយុវជន និងកីឡា។

*រូបភាពទី៤៖ អង្គការលេខរបស់អគ្គលេខាធិការដ្ឋាន គ.ជ.គ.ក*




អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច( គ.ជ.គ.ក.) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងចុងក្រោយផែនការសកម្មភាពជាតិស្តីពីការគាំពារ និងអភិវឌ្ឍន៍កុមារតូច ឆ្នាំ២០១៩-

២០២៣ ក្នុងគោលបំណងប្រមូលធាតុចូលពីក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍពាក់ព័ន្ធសម្រាប់បញ្ចូលក្នុងសេចក្តីព្រាងចុងក្រោយនៅខេត្តសៀមរាបថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៩។[25]

### គ.គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស"គ.ជ.ប.ជ"

គ.ជ.ប.ជ បង្កើតឡើងដោយព្រះរាជក្រឹត្យនៅឆ្នាំ២០១៤ ជាយន្តការអន្តរស្ថាប័នថ្នាក់ជាតិដែលមានតួនាទីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការដឹកនាំ និងសម្របសម្រួល ប្រមូលផ្តុំការចូលរួមកិច្ចសហការ និងការគាំទ្រពីក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការសហប្រជាជាតិ ដៃគូជាតិ អន្តរជាតិ ផ្នែកឯកជន រួមទាំងយន្តការក្នុងតំបន់ និងបណ្តាប្រទេសពាក់ព័ន្ធទាំងឡាយសម្រាប់ការងារប្រយុទ្ធប្រឆាំងនឹងរាល់ទម្រង់នៃអំពើជួញដូរ និងអំពើធ្វើអាជីវកម្មកេងប្រវ័ញ្ចលើមនុស្សគ្រប់រូបភាព ជាពិសេសលើស្ត្រីនិងកុមារ ដែលកើតមាននៅក្នុងដែនដី និងនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ គ.ជ.ប.ជ.[26] ដឹកនាំដោយសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ដែលមានក្រសួង ២១ និងអង្គភាពជំនាញ ៥ ជាសមាជិក និងចែកជា៦ក្រុមការងារអន្តរក្រសួង៖ ១.ក្រុមការងារបង្ការ ទប់ស្កាត់ ដឹកនាំដោយក្រសួងអប់រំយុវជន និងកីឡា ២.ក្រុមការងារការពារជនរងគ្រោះ ដឹកនាំដោយក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា ៣.ក្រុមការងារអនុវត្តច្បាប់ ដឹកនាំដោយអគ្គស្នងការនគរបាលជាតិ ៤.ក្រុមការងារកិច្ចសហប្រតិបត្តិការអន្តរជាតិ ដឹកនាំដោយក្រសួងកិច្ចការនារី ៥.ក្រុមកាងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ៦.ក្រុមការងារទេសន្តរប្រវេសន៍ជីនាំ ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងគណៈកម្មាធិការរាជធានីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.រ.ប.ជ) និងគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) មានរចនាសម្ព័ន្ធដល់ថ្នាក់ ខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់។

គ.ជ.ប.ជ. មានភារកិច្ច[27] ជំរុញ និងលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីការការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពិធីសារស្តីពីការទប់ស្កាត់ ការបង្ក្រាបនិងដាក់ទណ្ឌកម្ម ការជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងឧក្រិដ្ឋឆ្លង ដែនដែលមានអង្គការចាត់តាំង ឬលិខិតគុបករណ៍ និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀតទាក់ទងនឹងអំពើជួញដូរមនុស្ស។ តាមដានត្រួតពិនិត្យ និងវាយតម្លៃសភាពការណ៍ប្រែប្រួលនៃបទល្មើសជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងបទល្មើសពាក់ព័ន្ធដទៃទៀត ដោយយកចិត្តទុកដាក់លើភាពរងគ្រោះរបស់ប្រជាពលរដ្ឋទាំងស្ត្រី បុរស ជាពិសេសកុមារនិងយុវវ័យ។ ជំរុញឱ្យមានមជ្ឈមណ្ឌលគំរូ ដែលអនុវត្តតាមបទដ្ឋានបានត្រឹមត្រូវ សម្រាប់ការស្តារនីតិសម្បទាជនរងគ្រោះមាតុភូមិនិវត្តន៍ មុននឹងធ្វើសមាហរណកម្មទៅគ្រួសារ ឬសហគមន៍វិញ។

---

[25] សិក្ខាសាលាប្រព្រឹត្តទៅក្រោមអធិបតីភាព លោកជំទាវ គឹម សេដ្ឋានី រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា និងជាអនុប្រធានប្រចាំការគណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច។

[26] មាត្រា ១២ នៃព្រះរាជក្រឹត្យបញ្ជាក់ថា គ.ជ.ប.ប មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិដែលជាកញ្ចប់ថវិកាដោយឡែកនៅក្នុងឧបសម្ព័ន្ធនៃកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃ។ ចំពោះថវិកាសម្រាប់ការងាររបស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិគឺជាថវិកា ឧបសម្ព័ន្ធរបស់រាជធានី ខេត្ត។

[27] សង្ខេបមាត្រា៤ នៃព្រះរាជក្រឹត្យស្តីពីការបង្កើត គ.ជ.ប.ជ

*រូបភាពទី៥៖ អង្គការលេខរបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ*




## ឃ.គណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ

គណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារត្រូវ បានបង្កើតឡើងនៅឆ្នាំ២០១៩ ដែលជាយន្តការអន្តរក្រសួងសម្រាប់ដឹកនាំ សម្របសម្រួល ជំរុញ និងត្រួតពិនិត្យ តាមដានការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ សំដៅកាត់បន្ថយអំពើហិង្សាលើកុមារនៅកម្ពុជា និងរួមចំណែកសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងគោលដៅពាក់ព័ន្ធកិច្ចការពារកុមារ។ គណៈកម្មការនេះមានរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាប្រធាន និងបានបង្កើតក្រុមការងារបច្ចេកទេសចំនួនបីរួមមាន៖១.ក្រុមការងារលើកកម្ពស់ការយល់ដឹងនិងទប់ស្កាត់អំពើហិង្សាលើកុមារ ២.ក្រុមការងារផ្តល់សេវានិងអនុវត្តច្បាប់ និង៣.ក្រុមការងារសិក្សាលើបទដ្ឋានគតិយុត្ត ពិនិត្យតាមដាន និងធ្វើរបាយការណ៍។ ប្រការ៤ នៃសេចក្តីសម្រេចបានបញ្ជាក់ថា គណៈកម្មការមានប្រភពធនធានពីថវិកាជាតិ តាមរយៈការដាក់បញ្ចូលទៅក្នុងថវិកាកម្មវិធីប្រចាំឆ្នាំរបស់ក្រសួង ស្ថាប័នសាមី។ គណៈកម្មការមានសិទ្ធិទទួលគ្រប់គ្រង ចាត់ចែងនិងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវមូលនិធិដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងប្រភពផ្សេងៗទៀត។

គណៈកម្មារដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារមានភារកិច្ចសម្របសម្រួលការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារឆ្នាំ២០១៧-២០២១ ដើម្បីចូលរួមជាមួយចលនាសកលសំដៅបញ្ចប់អំពើហិង្សាលើកុមារ ដូចមានបញ្ជាក់នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងផែនការសកម្មភាពរបស់អាស៊ានឆ្នាំ២០១៥ ស្តីពីការលុបបំបាត់អំពើហិង្សាលើកុមារ និងយុទ្ធសាស្ត្រចំនួនប្រាំពីរសម្រាប់បញ្ចប់អំពើហិង្សាលើកុមារ (INSPIRE) ចលនាសកល ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ។ ផែនការសកម្មភាពបានកំណត់អន្តរាគមន៍ជាយុទ្ធសាស្ត្រសំខាន់ៗចំនួន៥ រួមមាន៖ ១).កិច្ចសម្របសម្រួលនិងសហប្រតិបត្តិការ

២).ការទប់ស្កាត់បឋម ៣).សេវាឆ្លើយតបពហុវិស័យសម្រាប់កិច្ចការពារកុមារ ៤).ការតាក់តែងច្បាប់ គោលនយោបាយ និងវិសោធនកម្ម និង៥).ការពិនិត្យតាមដាន និងវាយតម្លៃ ដែលនឹងត្រូវអនុវត្តនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស។

*រូបភាពទី៦៖ អង្គការលេខរបស់គណៈកម្មការទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ*




### ង.គណៈកម្មការការពារកុមារថ្នាក់ជាតិ

គណៈកម្មការការពារកុមារថ្នាក់ជាតិបង្កើតឡើងនៅឆ្នាំ២០១៥ ដើម្បីសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បរទេស ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ និងផ្នែកឯកជន ក្នុងគោលបំណងពង្រឹងប្រព័ន្ធការពារកុមារ ដើម្បីទប់ស្កាត់ ការពារ និងលប់បំបាត់រាល់ទម្រង់នៃការរំលោភបំពានផ្សេងៗ និងអំពើហិង្សាលើកុមារសំដៅបម្រើឧត្តមប្រយោជន៍របស់កុមារនិងបំពេញមុខងារជាក្រុមការងារថ្នាក់ជាតិក្នុងការការពារកុមារពីការរំលោភបំពានគ្រប់រូបភាព។ គណៈកម្មការដឹកនាំដោយអនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បី កុមារដែលមានផ្នែកការការពារកុមារ និងពិនិត្យតាមដានជាលេខាធិការដ្ឋាន។ សេចក្តីសម្រេចមិនបានបញ្ជាក់ពីប្រភពថវិកាទេ គឺគ្រាន់តែបញ្ជាក់ថាលេខាធិការដ្ឋានសម្របសម្រួលលើគម្រោង និងទូទាត់ថវិកាចំណាយរបស់គណៈកម្មការការពារកុមារថ្នាក់ជាតិ។

### ច.គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា "គ.ស.ម.ក"

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាបង្កើតឡើងនៅឆ្នាំ២០០០ និងបានកែសម្រួលជាបន្តបន្ទាប់រហូតដល់ឆ្នាំ២០១៣ ដើម្បីការពារ លើកស្ទួយ អភិវឌ្ឍសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ត្រួតពិនិត្យរាល់ការរំលោភសិទ្ធិមនុស្ស និងពាក្យបណ្តឹងតវ៉ានានា។ ស្រាវជ្រាវអង្កេតករណីនានា ឬធ្វើការវាយតម្លៃការស្រាវជ្រាវ អង្កេតរបស់សមត្ថកិច្ច ឬសហការស្រាវជ្រាវអង្កេតជាមួយសមត្ថកិច្ច ហើយធ្វើសំណុំឯកសារ ផ្សព្វផ្សាយជូនសារណៈជន ជូននាយករដ្ឋមន្ត្រី ជូនតុលាការ និងជូនសមត្ថកិច្ចនោះវិញ។ កសាងភ្នាក់ងារ និងមន្ត្រីឃ្លាំមើលសិទ្ធិមនុស្សស្ម័គ្រចិត្តរបស់ខ្លួននៅតាមស្ថាប័នរដ្ឋ ឯកជន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ភូមិ។ ផ្តល់យោបល់និងលើកសំណើជូនរាជរដ្ឋាភិបាលអំពីសភាពការណ៍សិទ្ធិមនុស្ស សំដៅធ្វើការកែលម្អ និងធ្វើយ៉ាងណាឱ្យស្របរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ។ សហការជាមួយ**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ** និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលជាស្ថាប័នទទួលខុសត្រូវលើសិទ្ធិកុមារ និងសិទ្ធិនារី និងស្ថាប័នសិទ្ធិមនុស្សនានារបស់រដ្ឋដើម្បីជំរុញការអភិវឌ្ឍសិទ្ធិមនុស្សតាមផ្នែកនិមួយៗឱ្យបានល្អ និងរៀបចំរបាយការណ៍ជាតិជូនរាជរដ្ឋាភិបាលស្តីពីការអនុវត្តលិខិតបទដ្ឋានអន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងវិស័យសិទ្ធិមនុស្សនឹងរបាយការណ៍បំភ្លឺនានាសម្រាប់សាធារណមតិជាតិ និងអន្តរជាតិ។

**ធ.គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម**

គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម "គ.ជ.ប.ទ." បង្កើតឡើងនៅឆ្នាំ២០១៧ ធ្វើជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើការងារប្រឆាំងទារុណកម្ម អំពើឃោឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម និងត្រួតពិនិត្យយ៉ាងទៀងទាត់នូវប្រព្រឹត្តកម្មលើជន ដែលត្រូវបានដកហូតសិទ្ធិសេរីភាពនៅតាមកន្លែងឃុំឃាំងនានាដើម្បីការពារជនទាំងនោះ។ អប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលស្តីពីអនុសញ្ញា និងពិធីសារបន្ថែមប្រឆាំងទារុណកម្មជាសាធារណៈ និងតាមមុខសញ្ញានិមួយៗ។ ធ្វើទំនាក់ទំនងជាមួយអនុគណៈកម្មាធិការបង្ការរបស់អង្គការសហប្រជាជាតិ ដើម្បីផ្តល់លទ្ធភាពឱ្យអនុគណៈកម្មាធិការនេះ អាចបំពេញអាណត្តិការងាររបស់ខ្លួនបានស្រមតាមមាត្រា២០នៃពិធីសារបន្ថែម។

គ.ជ.ប.ទ ជំរុញ និងលើកកម្ពស់ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ឱ្យប្រព្រឹត្តលើជន ដែលត្រូវបានសង្ស័យ ឬជនដែលត្រូវបានដកហូតសិទ្ធិសេរីភាពដោយគោរពឱ្យបានត្រឹមត្រូវតាមនីតិវិធីច្បាប់ពាក់ព័ន្ធ និងផ្តល់អនុសាសន៍ដើម្បីកែលម្អប្រព្រឹត្តកម្មលើជនដែលត្រូវដកហូតសិទ្ធិសេរីភាព។ ចុះធ្វើទស្សនកិច្ចត្រួតពិនិត្យ ពន្ធនាគារ ឬមជ្ឈមណ្ឌលអប់រំកែប្រែទាំងពិរុទ្ធជននិងទណ្ឌិត មណ្ឌលឃុំខ្លួនអនីតិជន កន្លែងឃុំខ្លួនបណ្តោះ អាសន្នរបស់នគរបាលយុត្តិធម៌ មន្ទីរពេទ្យវិកលចរិត មណ្ឌលសុខភាពផ្លូវចិត្ត មជ្ឈមណ្ឌលស្តារនីតិសម្បទាសង្គមកិច្ច មជ្ឈមណ្ឌលបន្សាបគ្រឿងញៀន ឬមណ្ឌលអប់រំផ្សេងទៀតទូទាំងប្រទេស។ រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញា និងពិធីសារបន្ថែមប្រឆាំងទារុណកម្ម អំពើឃោឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចមុននឹងផ្ញើទៅជូនអង្គការសហប្រជាជាតិ។

*រូបភាពទី៧៖ អង្គការលេខរបស់ គ.ជ.ប.ទ*




គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ"គ.ជ.ព" គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច "គ.ជ.គ.ក" គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស"គ.ជ.ប.ជ" បង្កើតឡើងដោយព្រះរាជក្រឹត្យ និងមានអគ្គលេខា ធិការដ្ឋានបង្កើតឡើងដោយអនុក្រឹត្យ រួមទាំងបង្កើតយន្តការនៅថ្នាក់ក្រោមជាតិ ដែលមានស្ថានភាពដូចជាក្រុមប្រឹក្សា ជាតិកម្ពុជាដើម្បីកុមារដែរ។ ចំណែកឯគណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារបង្កើតឡើងដោយសេចក្តីសម្រេចរបស់ក្រសួង ស.អ.យ។ ដូច្នេះគណកម្មាធិការ និងគណៈ កម្មការទាំងប្រាំនេះជាយន្តការដាច់ដោយឡែកពី ក.ជ.ក លើកលែងតែគណៈកម្មកាការពារកុមារថ្នាក់ជាតិស្ថិតក្រោម ការដឹកនាំរបស់ ក.ជ.ក។

*តារាងទី៣៖សង្ខេបយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ*

| ល.រ | ឈ្មោះយន្តការ | កម្រិតគតិយុត្ត | តួនាទី និងភារកិច្ច |
|---|---|---|---|
| ១ | ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ "ក.ជ.ក" | ព្រះរាជក្រឹត្យ ២០០៩ | ជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនរាជរដ្ឋាភិបាលលើការងារទាក់ទងនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព និងការចូលរួមចំណែករបស់កុមារ។ ផ្សព្វផ្សាយ និងតាមដានត្រួតពិនិត្យការអនុវត្តសិទ្ធិរបស់កុមារ និងធ្វើរបាយការណ៍ស្តីពីស្ថានភាពកុមារជូនរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ។ |
| | អគ្គលេខាធិការដ្ឋាន"ក.ជ.ក" | អនុក្រឹត្យ ២០១០ | ជាសេនាធិការឱ្យ ក.ជ.ក. |
| | ក្រុមការងារដើម្បីកុមារ នៅតាមក្រសួង ស្ថាប័ន | សេចក្តីសម្រេច ក.ជ.ក. ២០១០ | សម្របសម្រួលនិងផ្តល់យោបល់ជូន ក.ជ.ក លើការងារពិគ្រោះយោបល់ និងពិនិត្យតាមដានវាយតម្លៃលើការអនុវត្តសិទ្ធិកុមារ ផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារ គោលនយោបាយ និងលិខិតដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល និង ក.ជ.ក |
| ២ | គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ "គ.ជ.ព" | ព្រះរាជក្រឹត្យ ២០១៦ | ការពិនិត្យ តាមដាននិងវាយតម្លៃលើការអនុវត្តអនុសញ្ញានៃអង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ អនុសញ្ញាលេខ១៣៨ ស្តីពីអាយុអប្បបរមាអាចចូលធ្វើការបាន អនុសញ្ញាលេខ២៩ ស្តីពីការងារដោយបង្ខំ ឬជាកតព្វកិច្ច និងចូលរួមអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ |
| | អគ្គលេខាធិការដ្ឋាន"គ.ជ.ព" | អនុក្រឹត្យ ២០១៨ | ជាសេនាធិការឱ្យ គ.ជ.ព |
| ៣ | គណៈកម្មាធិការជាតិគាំពារ និងអភិវឌ្ឍន៍កុមារតូច "គ.ជ.គ.ក" | ព្រះរាជក្រឹត្យ ២០១៣ | ជំរុញក្រសួងស្ថាប័ននិងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានា ដើម្បីអនុវត្តតួនាទីភារកិច្ច ដែលមានចែងក្នុងគោលនយោបាយជាតិស្តីពីការគាំពារ និងការអភិវឌ្ឍន៍កុមារតូចឱ្យមានប្រសិទ្ធភាពរួមទាំងពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តគ្រប់កម្មវិធីគាំពារនិងអភិវឌ្ឍន៍កុមារតូច |
| | អគ្គលេខាធិការដ្ឋាន គ.ជ.គ.ក | អនុក្រឹត្យ ២០១៣ | ជាសេនាធិការឱ្យ គ.ជ.គ.ក |
| ៤ | គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស "គ.ជ.ប.ជ" | ព្រះរាជក្រឹត្យ ២០១៤ | ជំរុញ និងលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីការបង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេស ស្ត្រីនិងកុមារ ដែលបំពេញបន្ថែម លើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង ឬលិខិតតុបករណ៍ និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀតទាក់ទងនឹងអំពើជួញដូរមនុស្ស |
| | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | អនុក្រឹត្យ ២០១៤ | ជាសេនាធិការឱ្យ គ.ជ.ប.ជ |

| | | | |
|---|---|---|---|
| ៥ | គណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ | សេចក្ដីសម្រេច ស.អ.យ. ២០១៩ | ដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ យុទ្ធសាស្ត្រចំនួនប្រាំពីរ សម្រាប់បញ្ចប់អំពើហិង្សាលើកុមារ (INSPIRE) ចលនាសកល ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងភាពជាដៃគូសកល |
| | លេខាធិការដ្ឋាននៅក្នុង នា.សុខុមាលភាពកុមារ នៃក្រសួង ស.អ.យ | ប្រការ ៥ នៃ សេចក្ដីសម្រេច ស.អ.យ | ជាអង្គភាពប្រតិបត្តិ "ការិយាល័យកិច្ចការពារកុមារ" ឱ្យគណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាព ដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ |
| ៦ | គណៈកម្មកាការពារកុមារថ្នាក់ជាតិ | សេចក្ដីសម្រេច ក.ជ.ក. ២០១៥ | សម្របសម្រួលក្នុងការពិនិត្យ និងបំពេញបន្ថែមភាពខ្វះចន្លោះក្នុងក្របខ័ណ្ឌច្បាប់ គោលនយោបាយ ផែនការជាតិ និងក្របខ័ណ្ឌនៃការអនុវត្ត ផ្ដល់បច្ចេកទេសនិងជំរុញការអនុវត្តសកម្មភាពការការពារកុមារ លើកកម្ពស់ការយល់ដឹងពីការការពារកុមារ សហការ និងជំរុញការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការការពារកុមារ |
| | លេខាធិការដ្ឋានមានផ្នែកការការពារកុមារ និងពិនិត្យតាមដាន នៃអគ្គលេខាធិការដ្ឋាន ក.ជ.ក | ប្រការ ៥ នៃ សេចក្ដីសម្រេច ក.ជ.ក | ជាសេនាធិការឱ្យគណៈកម្មការការពារកុមារថ្នាក់ជាតិ |
| ៧ | គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា | ព្រះរាជក្រឹត្យ ២០១៣ | ការពារ លើកស្ទួយ អភិវឌ្ឍសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ត្រួតពិនិត្យរាល់ការរំលោភសិទ្ធិមនុស្ស និងពាក្យបណ្ដឹងតវ៉ានានា។ ស្រាវជ្រាវអង្កេតករណីនានា ឬធ្វើការវាយតម្លៃការស្រាវជ្រាវ អង្កេតរបស់សមត្ថកិច្ច ឬសហការស្រាវជ្រាវអង្កេតជាមួយសមត្ថកិច្ច ហើយធ្វើសំណុំឯកសារផ្សព្វផ្សាយជូនសារណៈជន ជូននាយករដ្ឋមន្ត្រី ជូនតុលាការ និងជូនសមត្ថកិច្ចនោះវិញ |
| ៨ | គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម "គ.ជ.ប.ទ" | ព្រះរាជក្រឹត្យ ២០១៧ | ប្រឆាំងទារុណកម្ម អំពើឃោឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម និងត្រួតពិនិត្យយ៉ាងទៀងទាត់នូវប្រព្រឹត្តកម្មលើជន ដែលត្រូវបានដកហូតសិទ្ធិសេរីភាពនៅតាមកន្លែងឃុំឃាំងនានា ដើម្បីការពារជនទាំងនោះ។ រៀបចំរបាយការណ៍ស្ដីពីការអនុវត្ត អនុសញ្ញា និងពិធីសារបន្ថែមប្រឆាំងទារុណកម្ម អំពើឃោឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចមុននឹងផ្ញើទៅអង្គការសហប្រជាជាតិ |
| | លេខាធិការដ្ឋាន គ.ជ.ប.ទ | អនុក្រឹត្យ ២០១៧ | ជាសេនាធិការ |

## ៣.២.ការរកឃើញ និងអនុសាសន៍សម្រាប់យន្តការថ្នាក់ជាតិ

៣.២.១.ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មិនបានប្រជុំជាទៀងទាត់ដូចមានចែងក្នុងមាត្រា៤ នៃព្រះរាជក្រឹត្យកន្លងមក ទើបនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ក.ជ.ក បានរៀបចំកិច្ចប្រជុំដើម្បីប្រកាសសមាសភាពថ្មី និងពិនិត្យសម្រេចលើផែនការយុទ្ធសាស្ត្រស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ ២០១៩-២០២៣។ ក.ជ.ក គួរតែរៀបចំប្រតិទិនកិច្ចប្រជុំសាមាញ្ញ ដូចមានចែងក្នុងមាត្រា ៣ នៃព្រះរាជក្រឹត្យ ដើម្បីពិនិត្យលទ្ធផលកាងារ និងដោះស្រាយបញ្ហាសិទ្ធិរបស់កុមារ និងរៀបចំកិច្ចប្រជុំវិសាមញ្ញ ១ ឬ ២ដងក្នុងមួយឆ្នាំតាមស្ថានភាពជាក់ស្តែង។

៣.២.២.អគ្គលេខាធិការដ្ឋាន ក.ជ.ក មិនទាន់មានអង្គភាពថវិកា និងថវិកាគាំទ្រសកម្មភាពប្រចាំឆ្នាំនូវមានកម្រិត ពីព្រោះចង្កោមសកម្មភាពទី១.២.២.ពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងរបាយការណ៍ស្តីពីស្ថានភាពកុមារ[28] ស្ថិតនៅក្នុងអនុកម្មវិធីទី១.២.ការអភិវឌ្ឍសុខុមាលភាពកុមារ និងយុវនីតិសម្បទានៃកម្មវិធីទី១.ការបង្កើនប្រសិទ្ធភាពសេវាសុខុមាលភាពសង្គម ពុំមានវិសាលភាពគ្រប់គ្រាន់ដើម្បីបង្កើនថវិកាប្រចាំឆ្នាំ។ យោងមាត្រា១៣ នៃព្រះរាជក្រឹត្យ ក.ជ.ក មានប្រភពធនធានផ្តត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ដោយឡែកក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួង ស.អ.យ។ អគ្គលេខាធិការដ្ឋានគួរស្នើសុំបង្កើតអនុកម្មវិធី "ការអភិវឌ្ឍកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ" ដែលមានចង្កោមសកម្មភាព៖ ទី១.ពង្រឹងកិច្ចការពារនិងពិនិត្យតាមដានការលើកកម្ពស់សិទ្ធិកុមារ ២.បង្កើនការអប់រំផ្សព្វផ្សាយនិងអភិវឌ្ឍន៍ធនធានមនុស្ស ទី៣.ពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍភាពជាដៃគូ។ ដើម្បីឱ្យអគ្គលេខាធិការដ្ឋានមានដំណើរការប្រកបដោយប្រសិទ្ធភាព គួរតែស្នើសុំបង្កើតអង្គភាពថវិកាដើម្បីអនុវត្ត តួនាទី និងភារកិច្ចដូចមានចែងក្នុងព្រះរាជក្រិត្យ អនុក្រឹត្យ និងពង្រឹងសមត្ថភាពជំនាញរបស់មន្ត្រីគ្រប់ផ្នែក។

៣.២.៣.ក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័ន បានបង្កើតចំនួន៩ ក្រសួងរួមមាន៖ក្រសួងអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១១ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលឆ្នាំ២០១០ ក្រសួងសុខាភិបាលឆ្នាំ២០១១ ក្រសួងមហាផ្ទៃឆ្នាំ២០១១ ក្រសួងព័ត៌មានឆ្នាំ២០១១ ក្រសួងផែនការឆ្នាំ២០១១ ក្រសួងទេសចរណ៍ឆ្នាំ២០១១ ក្រសួងការពារជាតិឆ្នាំ២០១១ ក្រសួងកិច្ចការនារីឆ្នាំ២០១២។ ក្រុមការងារដើម្បីកុមារក្រសួងទាំង៩ មិនទាន់ធ្វើបច្ចុប្បន្នភាពនិងមានដំណើការតិចតួចក្នុងការអនុវត្តមុខងារ[29]ដោយថវិកាគាំទ្រមានកម្រិតឬគ្មានថវិកា[30]។

ចំណែកឯក្រសួងស្ថាប័នមួយចំនួនទៀតមិនទាន់បានបង្កើតក្រុមការងារដើម្បីកុមារនៅឡើយ។ ក្រសួងទាំង៩ ដែលបានបង្កើត ក្រុមការងារដើម្បីកុមារគួរតែធ្វើបច្ចុប្បន្នភាព និងវិភាជថវិកាគាំទ្រដល់សកម្មភាព ដោយឡែកក្រសួងដែលមិនទាន់បង្កើតក្រុមការងារដើម្បីកុមារ គួរតែបង្កើតក្រុមការងារ ឬកំណត់អង្គភាពចំណុះក្រសួង "មន្ត្រីបង្គោល" និងវិភាជថវិកាដើម្បីគាំទ្រសកម្មភាពដូចមានចែងនៅក្នុងសេចក្តីសម្រេចលេខ១២៧ ក.ជ.ក។

៣.២.៤.អនុគណៈកម្មការចំណុះ ក.ជ.ក មាន៖១.អនុគណៈកម្មការពលកម្មកុមារនិងទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតលើកុមារ ២.អនុគណៈកម្មការប្រឆាំងការជួញដូរនិងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ៣.អនុគណៈកម្មការតាក់តែងច្បាប់ដែលពាក់ព័ន្ធនឹងកុមារ និង៤.អនុគណៈកម្មការអភិវឌ្ឍន៍កុមារតូច។ អនុគណៈកម្មការទាំងបួននេះមិនទាន់ដំណើរការដូចមានចែងនៅក្នុងសេចក្តីសម្រេចទេតាំងពីបង្កើត ក.ជ.ក។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានបង្កើតគណៈកម្មាធិការមួយចំនួនហាក់បីដូចជាជំនួសអនុគណៈកម្មាការទាំងបួនខាងលើមានដូចជាគ.ជ.ព គ.ជ.គ.ក និង គ.ជ.ប.ជ ដែលដឹកនាំដោយក្រសួងជាសមាជិកក.ជ.ក។

---

[28] ថវិកាកម្មវិធីវិភាជប្រចាំឆ្នាំ២០១៩ សម្រាប់គាំទ្រសកម្មភាពអគ្គលេខាដ្ឋាន ក.ជ.ក ចំនួន...

[29] សេចក្តីសម្រេចលេខ ១២៧ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមការងារដើម្បីកុមារនៅតាមក្រសួងស្ថាប័ន

[30] សេចក្តីសម្រេចលេខ ១២៧ ក.ជ.ក មិនបានបញ្ជាក់ពីប្រភពថវិកាសម្រាប់គាំទ្រក្រុមការងារដើម្បីកុមារនៅតាមក្រសួង ស្ថាប័នទេ

៣.២.៥. គណៈកម្មាធិការ និងគណៈកម្មការពាក់ព័ន្ធដឹកនាំដោយក្រសួងស្ថាប័ន៖ ដើម្បីធានាបាននូវឧត្តមប្រយោជន៍របស់កុមារ និងសម្របសម្រួលកិច្ចការពារកុមារឱ្យកាន់តែមានប្រសិទ្ធភាព រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការ ឬគណៈកម្មការមួយចំនួនដើម្បីទទួលខុសត្រូវលើមុខសញ្ញាដូចជា៖

- គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ"គ.ជ.ព" បង្កើតឡើងដោយព្រះរាជក្រឹត្យដែលដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន សមាជិក មកពីក្រសួងពាក់ព័ន្ធ[31] និងបានបង្កើតអគ្គលេខាធិការដ្ឋានដោយអនុក្រឹត្យ រួមទាំងបានបង្កើតគណៈកម្មការ ឬអនុគណៈកម្មការជំនាញតាមវិស័យ និងគណៈកម្មការប្រឆាំងពលកម្មកុមាររាជធានី ខេត្ត។ ភារកិច្ចចម្បងរបស់ គ.ជ.ព គឺធ្វើការពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តអនុសញ្ញានៃអង្គការអន្តរជាតិខាងការងារលេខ១៨២ ស្តីពីការហាមប្រាម និងសកម្មភាពបន្ទាន់សម្រាប់ការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ អនុសញ្ញាលេខ១៣៨ ស្តីពីអាយុអប្បបរមាអាចចូលធ្វើការបាន អនុសញ្ញាលេខ២៩ ស្តីពីការងារដោយបង្ខំ ឬជាកតព្វកិច្ច និងចូលរួមអនុវត្តអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារជាមួយក.ជ.ក។ រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនឹងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ។
- គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច "គ.ជ.គ.ក" បង្កើតឡើងដោយព្រះរាជក្រឹត្យដែលមានសម្តេចនាយករដ្ឋមន្ត្រី ជាប្រធានកិត្តិយស ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ជាប្រធាន អនុប្រធាន សមាជិក មកពីក្រសួងពាក់ព័ន្ធ[32] និងបានបង្កើតអគ្គលេខាធិការដ្ឋានដោយអនុក្រឹត្យ រួមទាំងបង្កើតគណៈកម្មការសម្របសម្រួលបច្ចេកទេសកុមារតូចតាមវិស័យ និងយន្តការថ្នាក់ក្រោមជាតិមាន គ.ក.ស.ក រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង គ.ក.ន.ក។ ភារកិច្ចចម្បងគឺជំរុញក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធនានាដើម្បីអនុវត្តតួនាទី និងភារកិច្ចដែលមានចែងក្នុងគោលនយោបាយជាតិស្តីពីគាំពារ និងអភិវឌ្ឍន៍កុមារតូចឱ្យមានប្រសិទ្ធភាព។ ពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តគ្រប់កម្មវិធីគាំពារ និងអភិវឌ្ឍន៍កុមារតូច និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។
- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស "គ.ជ.ប.ជ" បង្កើតឡើងដោយព្រះរាជក្រឹត្យដែលដឹកនាំដោយឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុប្រធាន និងសមាជិក មកពីក្រសួងពាក់ព័ន្ធ[33] និងបានបង្កើតអគ្គលេខាធិការដ្ឋាននៃ គ.ជ.ប.ជ ដោយអនុក្រឹត្យ រួមទាំងបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន និងគណៈកម្មាធិការរាជធានី ខេត្ត គរបជ/គខបជ។ ភារកិច្ចចម្បងគឺជំរុញ និងលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីការបង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង ឬលិខិតតុបករណ៍ និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀតទាក់ទងនឹងអំពើជួញដូរមនុស្ស។ រៀបចំរបាយការណ៍ស្តីពីស្ថានភាព និងការងារប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទជូនរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិតាមការកំណត់។
- គណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ បង្កើតឡើងដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងស.អ.យ ដែលដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រី ជាប្រធាន អនុប្រធាន សមាជិក មកពីក្រសួងស្ថាប័នពាក់ព័ន្ធ និងបានបង្កើតក្រុមបច្ចេកទេសចំនួនបីរួមមាន៖ ១.ក្រុមការងារលើកកម្ពស់ការយល់ដឹង និងទប់ស្កាត់អំពើហិង្សាលើកុមារ ២.ក្រុមការងារផ្តល់សេវា និងអនុវត្តច្បាប់

[31] មាត្រា ២ នៃរាជក្រឹត្យលេខ នស/រកត/១១១៦/១០៤៤ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើត គ.ជ.ព

[32] មាត្រា ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤១២/៣១៧ ចុះថ្ងៃទី៤ មេសា ឆ្នាំ២០១៣ ស្តីពីការបង្កើត គ.ជ.គ.ក

[33] មាត្រា ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៨០៨ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើត គ.ជ.ប.ជ

និង៣.ក្រុមការងារសិក្សាលើបទដ្ឋានគតិយុត្ត ពិនិត្យតាមដាន និងធ្វើរបាយការណ៍។ ភារកិច្ចចម្បងគឺដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់ និងឆ្លើយតបអំពើហិង្សាលើកុមារ យុទ្ធសាស្ត្រចំនួនប្រាំពីរសម្រាប់បញ្ចប់អំពើហិង្សាលើកុមារ (INSPIRE) ចលនាសកល ដើម្បីបញ្ចប់អំពើហិង្សាលើកុមារ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងភាពជាដៃគូសកល។ គណៈកម្មការនេះមានលេខាធិការដ្ឋាន ស្ថិតនៅក្នុងនាយកដ្ឋានសុខុមាលភាពកុមារក្រសួងស.អ.យ។

- គណៈកម្មកាការពារកុមារថ្នាក់ជាតិបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធាន ក.ជ.ក ដែលដឹកនាំដោយរដ្ឋលេខាធិកាក្រសួង ស.អ.យ ជាអនុប្រធាន ក.ជ.ក ជាប្រធានគណៈកម្មការ អនុប្រធាន សមាជិក មកពីក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធ[34] ដែលមានផ្នែកការការពារកុមារ និងពិនិត្យតាមដាន នៃអគ្គលេខាធិការដ្ឋាន ក.ជ.ក លេខាធិការដ្ឋាន។ ភារកិច្ចចម្បងគឺ៖១.សម្របសម្រួលក្នុងការពិនិត្យ និងបំពេញបន្ថែមភាពខ្វះចន្លោះក្នុងក្របខ័ណ្ឌច្បាប់ គោលនយោបាយ ផែនការជាតិ និងក្របខ័ណ្ឌនៃការអនុវត្ត ២.សម្របសម្រួលផ្តល់បច្ចេកទេស និងជំរុញការអនុវត្តសកម្មភាពការការពារកុមារ ៣.សម្របសម្រួលលើកកម្ពស់ការយល់ដឹងពីការការពារកុមារ ៤.សម្របសម្រួល សហការនិងជំរុញការពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការការពារកុមារ។
- គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា "គ.ស.ម.ក" បង្កើតឡើងដោយព្រះរាជក្រឹត្យ និងអនុក្រឹត្យសម្រាប់ការរៀបចំ និងការប្រព្រឹត្តទៅ។ គ.ស.ម.ក មានភារកិច្ចការពារ លើកស្ទួយ អភិវឌ្ឍសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ត្រួតពិនិត្យរាល់ការរំលោភសិទ្ធិមនុស្ស និងពាក្យបណ្តឹងតវ៉ានានា។ ស្រាវជ្រាវអង្កេតករណីនានា ឬធ្វើការវាយតម្លៃការស្រាវជ្រាវ អង្កេតរបស់សមត្ថកិច្ច ឬសហការស្រាវជ្រាវអង្កេតជាមួយសមត្ថកិច្ច ហើយធ្វើសំណុំឯកសារ ផ្សព្វផ្សាយជូនសារណៈជន ជូននាយករដ្ឋមន្ត្រី ជូនតុលាការ និងជូនសមត្ថកិច្ចនោះវិញ។
- គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម "គ.ជ.ប.ទ" បង្កើតឡើងដោយព្រះរាជក្រឹត្យ និងលេខាធិការដ្ឋានបង្កើតឡើងដោយអនុក្រឹត្យ។ គ.ជ.ប.ទ មានភារកិច្ចប្រឆាំងទារុណកម្ម អំពើឃោឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម និងត្រួតពិនិត្យយ៉ាងទៀងទាត់នូវប្រព្រឹត្តកម្មលើជន ដែលត្រូវបានដកហូតសិទ្ធិសេរីភាពនៅតាមកន្លែងឃុំឃាំងនានា ដើម្បីការពារជនទាំងនោះ។ រៀបចំរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញា និងពិធីសារបន្ថែមប្រឆាំងទារុណកម្ម អំពើឃោឃៅ អំពើអមនុស្សធម៌ អំពើធ្វើទុក្ខបុកម្នេញ ឬទណ្ឌកម្ម ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចមុននឹងផ្ញើទៅអង្គការសហប្រជាជាតិ។

## ៣.៣. ជម្រើសយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ

### ៣.៣.១.ជម្រើសទី១.ពង្រឹងសមត្ថភាពផ្នែកការការពារកុមារ និងពិនិត្យតាមដាន

ប្រការ ៣ នៃប្រកាសលេខ ៦១៧ ស.អ.យ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះអគ្គលេខាធិការដ្ឋាន ក.ជ.ក ត្រង់ចំណុច ខ ផ្នែកការការពារកុមារនិងត្រួតពិនិត្យតាមដាន **ខ២.ការិយាល័យពិនិត្យតាមដាន និងរបាយការណ៍** មានភារកិច្ច៖ រៀបចំនិងកំណត់សូចនាករដើម្បីតាមដានការអនុវត្តអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមាររបស់ អ.ស.ប សម្រាប់រៀបចំរបាយការណ៍ស្ថានភាពកុមារជូនរាជរដ្ឋាភិបាល និងផ្ញើជូនគណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប។[35] តាមដានការអនុវត្តអនុសាសន៍របស់គណៈកម្មា

[34] ប្រការ ៣ នៃសេចក្តីសម្រេចលេខ ១០៥ ក.ជ.ក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មការការពារកុមារថ្នាក់ជាតិ

[35] មាត្រា ៤៤ នៃ អ.ស.ក តម្រូវឱ្យប្រទេស ហត្ថលេខីផ្តល់របាយការណ៍វឌ្ឍនភាពស្តីពីកុមារ ជូនគណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប។

ធិការសិទ្ធិកុមារនៃ អ.ស.ប និងប្រមូលព័ត៌មានពីក្រសួង ស្ថាប័នពាក់ព័ន្ធដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យស្តីពីសិទ្ធិកុមារនិងតាមដានស្ថានភាពកុមារ។ **ខ៣.ការិយាល័យស្រាវជ្រាវនិងស្ថិតិ** មានភារកិច្ចៈ សហការជាមួយក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធដែលធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្លាស់ប្តូរបទពិសោធន៍ស្តីពីវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ។ រៀបចំបញ្ចូលសូចនាករពាក់ព័ន្ធនឹងសិទ្ធិកុមារទៅក្នុងប្រព័ន្ធព័ត៌មានកម្ពុជា (Caminfo) និងគ្រប់គ្រងប្រព័ន្ធមូលដ្ឋានទិន្នន័យស្តីពីសិទ្ធិកុមារ។ ប្រមូលចងក្រងរបាយការណ៍ពីការសិក្សាស្រាវជ្រាវតាម ក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធដើម្បីយល់ដឹងពីស្ថានភាពកុមារ និងដើម្បីរៀបចំផែនការទាក់ទាញមតិគាំទ្រ។

តាមស្ថានភាពជាក់ស្តែង ការិយាល័យទាំងពីរនេះ មិនទាន់បានបំពេញភារកិច្ចពេញលេញដូចបានរៀបរាប់ខាងលើនេះនៅឡើយទេដោយខ្វះចំនួនមន្ត្រីបំពេញមុខងារ សមត្ថភាពជំនាញរបស់មន្ត្រីមានកម្រិត និងថវិកាគាំទ្រសកម្មភាពមានកម្រិត។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋាន ក.ជ.ក មិនទាន់មានប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងវិធីសាស្ត្រសម្រាប់ប្រមូលពត៌មាន និងទិន្នន្ន័យនៃការអនុវត្តសិទ្ធិកុមារគ្រប់ជ្រុងជ្រោយនៅឡើយ។

ជម្រើសទី១ តម្រូវឱ្យអគ្គលេខាធិការដ្ឋាន ក.ជ.ក ពង្រឹងសមត្ថភាពផ្នែកការការពារកុមារ និងពិនិត្យតាមដានដោយធ្វើការបន្ថែមចំនួនមន្ត្រីតាមតម្រូវការអនុវត្តមុខងារ បំពាក់ជំនាញដល់មន្ត្រី បង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ រៀបចំវិធីសាស្ត្រប្រមូលព័ត៌មាន ទិន្នន័យការអនុវត្តសិទ្ធិកុមារ និងវិភាជថវិការដ្ឋដើម្បីគាំទ្រផែនការសកម្មភាព។ កំណត់មន្ត្រីបង្គោលសម្រាប់ទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធដូចរូបភាពទី៨ ដើម្បីប្រមូលព័ត៌មាន និងទិន្នន័យស្តីពីសិទ្ធិកុមារសម្រាប់បញ្ចូលប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងធ្វើរបាយការណ៍ស្តីពីស្ថានភាពកុមារជូនរាជរដ្ឋាភិបាល និងផ្ញើទៅជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ។

*រូបភាពទី៨៖គំនូសបំព្រួញពង្រឹងសមត្ថភាពផ្នែកការការពារកុមារ និងពិនិត្យតាមដានជម្រើសទី១*




[1] នាយកដ្ឋានសុខុមាលភាពកុមារ "ការិយាល័យកិច្ចការពារកុមារ" ស.អ.យ
[2] ផ្នែកការការពារកុមារ និងពិនិត្យតាមដាន នៃអគ្គលេខាធិការដ្ឋាន ក.ជ.ក

សំគាល់៖
ទំនាក់ទំនងប្រមូលព័ត៌មាន និងទិន្នន័យ
ទំនាក់ទំនងផ្ទាល់ក្នុងស្ថាប័នតែមួយ

### ៣.៣.២.ជម្រើសទី២.បង្កើតក្រុមការងារកិច្ចការពារកុមារ

អគ្គលេខាធិការដ្ឋាន ក.ជ.ក បង្កើតក្រុមការងារកិច្ចការពារកុមារដឹកនាំដោយអគ្គលេខាធិការ ជាប្រធាន អគ្គលេខាធិការរង ១នាក់ ជាអនុប្រធាន សមាជិកមកពីផ្នែកទាំង៣ លេខាធិការ ១នាក់ និងស្នើសុំទីប្រឹក្សាបច្ចេកទេស

ពីអង្គការមិនមែនរដ្ឋាភិបាល។ ក្រុមការងារនេះជាយន្តការអន្តរកាលដែលផ្នែកការការពារកុមារ និងពិនិត្យតាមដានមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ដើម្បីបំពេញមុខងារ។ ក្រុមការងារនេះមានភារកិច្ចៈ

- ធ្វើការកែសម្រួលសូចនាករសិទ្ធិកុមារទាំងអស់ឱ្យបានច្បាស់ និងកំណត់ប្រភពផ្តល់ទិន្នន័យ
- បង្កើតឧបករណ៍សម្រាប់ប្រមូលព័ត៌មាន និងទិន្នន័យការអនុវត្តសិទ្ធិកុមារ និងរៀបចំគំរូរបាយការណ៍
- រៀបចំបង្កើតវិធីសាស្ត្រ និងប្រព័ន្ធប្រមូលព័ត៌មាន និងទិន្នន័យការអនុវត្តសិទ្ធិកុមារពីអ្នកពាក់ព័ន្ធ
- ប្រមូលព័ត៌មាន និងទិន្នន័យការអនុវត្តសិទ្ធិកុមារពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា
- បញ្ចូលទិន្នន័យការអនុវត្តសិទ្ធិកុមារទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ
- ធ្វើរបាយការណ៍ស្ថានភាពកុមារជូនរាជរដ្ឋាភិបាល និងធ្វើជូនគណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប
- ពង្រឹងសមត្ថភាពមន្ត្រីផ្នែកការការពារកុមារ និងពិនិត្យតាមដាន និងលេខាធិការដ្ឋាន ក.ជ.ក រាជធានី ខេត្ត

ជម្រើសទី២ នេះគឺតម្រូវឱ្យអគ្គលេខាធិការដ្ឋាន ក.ជ.ក ជ្រើសរើសមន្ត្រីដែលមានឆន្ទៈការងារបញ្ចូលក្នុងក្រុមការងារនិងជ្រើសរើសទីប្រឹក្សាបច្ចេកទេសដើម្បីគាំទ្រ។ រៀបចំផែនការសកម្មភាពផ្អែកលើភារកិច្ចខាងលើដោយកំណត់សូចនាករ និងពេលវេលាច្បាស់លាស់សម្រាប់សម្រេចគោលដៅ។ ធ្វើការទាក់ទងជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ដើម្បីកៀរគរធនធានទាំងបច្ចេកទេស និងថវិកា រួមទាំងស្នើសុំការវិភាជថវិការដ្ឋបន្ថែមសម្រាប់គាំទ្រផែនការសកម្មភាព មើលរូបភាពទី៩។

*រូបភាពទី៩៖គំនូសបំព្រួញក្រុមការងារកិច្ចការពារកុមារជម្រើសទី២*




[1] នាយកដ្ឋានសុខុមាលភាពកុមារ "ការិយាល័យកិច្ចការពារកុមារ" ស.អ.យ
[2] ផ្នែកការការពារកុមារ និងពិនិត្យតាមដាន នៃអគ្គលេខាធិការដ្ឋាន ក.ជ.ក

ជម្រើសទាំងពីរដែលស្នើឡើងខាងលើគឺដើម្បីពង្រឹងសមត្ថភាពផ្នែកការការពារកុមារនិងពិនិត្យតាមដាន នៃអគ្គលេខាធិការដ្ឋាន ក.ជ.ក សម្រាប់អនុវត្តតួនាទី និងភារកិច្ចដូចមានចែងនៅក្នុងប្រការ៣នៃប្រកាសលេខ២៦១៧ ស.អ.យ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះអគ្គលេខាធិការដ្ឋាន ក.ជ.ក។ ចំណែក ក.ជ.ក ស្នើឱ្យទៅជាយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ ដែលមានសម្តេចនាយករដ្ឋមន្ត្រីជាប្រធានកិត្តិយស ក.ជ.ក ឬតំណាងជាឧបនាយករដ្ឋមន្ត្រីមានភារកិច្ចដឹកនាំ និងសម្របសម្រួលយន្តការកិច្ចការពារកុមារថ្នាក់ជាតិ(មើលរូបភាពទី១០)និងឯកឧត្តមរដ្ឋមន្ត្រី ក្រសួង ស.អ.យ. ជាប្រធាន ក.ជ.ក អនុប្រធាន សមាជិក

ក.ជ.ក មកពីក្រសួង ស្ថាប័ន ចំនួន៣០នាក់ដូចមានចែងនៅមាត្រា ១ នៃអនុក្រឹត្យលេខ៤១៦ អនក្រ.តត ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងអនុវត្តតួនាទី និងភារកិច្ច ដូចមានចែងនៅមាត្រា ៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

*រូបភាពទី១០៖គំនូសបំព្រួញយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ*




## ៣.៣.៣.ជម្រើសទី៣.ស្នើសុំថ្នាក់ដឹកនាំជាន់ខ្ពស់១រូបដឹកនាំយន្តការកិច្ចការពារកុមារថ្នាក់ជាតិ

នៅឆ្នាំ២០១៥ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបង្កើតគណៈកម្មការការការពារកុមារថ្នាក់ជាតិ ដើម្បីសម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ និងផ្នែកឯកជន ក្នុងគោលបំណងពង្រឹងប្រព័ន្ធការពារកុមារ ដើម្បីទប់ស្កាត់ ការពារ និងលប់បំបាត់រាល់ទម្រង់នៃការរំលោភបំពានផ្សេងៗ និងអំពើហិង្សាលើកុមារ សំដៅបម្រើឧត្តមប្រយោជន៍របស់កុមារ និងបំពេញមុខងារជាក្រុមការងារថ្នាក់ជាតិក្នុងការការពារកុមារពីការរំលោភបំពានគ្រប់រូបភាព។ គណៈកម្មការការការពារកុមារថ្នាក់ជាតិនេះ ដឹកនាំដោយលោកជំទាវអនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងមានផ្នែកការការពារកុមារ និងពិនិត្យតាមដាន នៃអគ្គលេខាធិការដ្ឋាន ក.ជ.ក. ធ្វើជាលេខាធិការដ្ឋាន។[36]

---

[36] សេចក្តីសម្រេចលេខ ១០៥ ក.ជ.ក ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការបង្កើតគណៈកម្មការការការពារកុមារថ្នាក់ជាតិ

ដើម្បីឱ្យគណៈកម្មការការការពារកុមារថ្នាក់ជាតិក្លាយជាយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ ស្នើសុំឧបនាយករដ្ឋមន្ត្រី១រូប ដើម្បីដឹកនាំយន្តការនេះ សម្រាប់សម្របសម្រួលកិច្ចការពារកុមារជាពហុវិស័យ ដែលមានគណៈកម្មការ និងគណៈកម្មាធិការពាក់ព័ន្ធដូចជា៖១.គណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ "គ.ជ.ព" ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២.គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស"គ.ជ.ប.ជ" ដែលដឹកនាំដោយសម្តេចឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ៣.គណៈកម្មាធិការជាតិគាំពារនិងអភិវឌ្ឍន៍កុមារតូច "គ.ជ.គ.ក" ដែលដឹកនាំសម្របសម្រួលដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ៤.គណៈកម្មការដឹកនាំអនុវត្តផែនការសកម្មភាពដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះអំពើហិង្សាលើកុមារ ដែលដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួង ស.អ.យ. ៥.គណៈកម្មការសិទ្ធិមនុស្សកម្ពុជាដឹកនាំដោយថ្នាក់ដឹកនាំជាន់ខ្ពស់នៅក្នុងទីស្តីការគណៈរដ្ឋមន្ត្រី និង៦.គណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម អំពើឃោរឃៅអំពើអមនុស្សធម៌ អំពើទុក្ខបុកម្នេញ ឬទណ្ឌកម្ម "គ.ជ.ប.ទ" ដឹកនាំដោយថ្នាក់ដឹកនាំជាន់ខ្ពស់នៅក្នុងក្រសួងមហាផ្ទៃ។ គណៈកម្មាធិការនីមួយៗទទួលខុសត្រូវ ឆ្លើយតប និងដោះស្រាយបញ្ហារបស់មុខសញ្ញា គ្រប់គ្រងព័ត៌មាន និងទិន្នន័យសូមនាករដែលពាក់ព័ន្ធកិច្ចការពារកុមារ។

ជម្រើសទី៣ ត្រូវស្នើសុំគោលការណ៍ពីសម្តេចនាយករដ្ឋមន្ត្រី ដើម្បីរៀបចំព្រះរាជក្រឹត្យ ឬអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ ជំនួសឱ្យគណៈកម្មការការពារកុមារថ្នាក់ជាតិ ដែលបង្កើតឡើងដោយសេចក្តីសម្រេចរបស់ប្រធាន ក.ជ.ក និងកំណត់យកផ្នែកការពារកុមារ និងពិនិត្យតាមដាន នៃអគ្គលេខាធិការដ្ឋាន ក.ជ.ក. ឬបង្កើតលេខាធិការដ្ឋានថ្មី ជាសេនាធិការ ដើម្បីធ្វើការសម្របសម្រួលការងារជាមួយអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋាននៃគណៈកម្មាធិការដូចរូបភាពទី១១។ ជម្រើសនេះត្រូវធ្វើវិសោធនកម្មសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការការពារកុមារថ្នាក់ជាតិ។

*រូបភាពទី១១៖គំនូសបំព្រួញយន្តការសម្រួលកិច្ចការពារកុមារថ្នាក់ជាតិជម្រើសទី៣*



## ៤. ការធ្វើផែនទីយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ក្រោមជាតិ

### ៤.១. យន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ក្រោមជាតិ

#### ៤.១.១. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី ខេត្ត

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានីខេត្ត[37] ដែលមានអភិបាលរាជធានី ខេត្តជាប្រធានកិត្តិយស អភិបាលរងរាជធានីខេត្តជាប្រធាន អនុប្រធាន សមាជិក មើលតារាងទី៤។ ប្រការ ៩ នៃសេចក្តីសម្រេចបញ្ជាក់ថា ក.ជ.ក រាជធានីខេត្តមានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិជាកញ្ចប់ដោយឡែក ក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់មន្ទីរ ស.អ.យ រាជធានីខេត្ត និងមានសិទ្ធិទទួលនិងគ្រប់គ្រងមូលនិធិមនុស្សធម៌ ដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗសម្រាប់បំពេញការងាររបស់ខ្លួន។

*តារាងទី៤៖សមាសភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រាជធានី ខេត្ត*

| ល.រ | សមាសភាព | តួនាទី |
|---|---|---|
| ១ | អភិបាលរាជធានី ខេត្ត | ប្រធានកិត្តិយស |
| ២ | អភិបាលរង រាជធានី ខេត្ត | ប្រធាន |
| ៣ | ប្រធានមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធានទី១ |
| ៤ | ប្រធានមន្ទីរ កិច្ចការនារី | អនុប្រធាន |
| ៥ | ប្រធានមន្ទីរ សុខាភិបាល | អនុប្រធាន |
| ៦ | ប្រធានមន្ទីរ អប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៧ | ប្រធានមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៨ | ស្នងការ នៃស្នងការដ្ឋាននគរបាល រាជធានី ខេត្ត | អនុប្រធាន |
| ៩ | អនុប្រធានមន្ទីរ សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិកអចិន្ត្រៃយ៍ |
| ១០ | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង រាជធានី ខេត្ត | សមាជិក |
| ១១ | មេបញ្ជាការកងរាជអាវុធហត្ថ រាជធានី ខេត្ត | សមាជិក |
| ១២ | នាយករដ្ឋបាលសាលា រាជធានី ខេត្ត | សមាជិក |
| ១៣ | អនុប្រធានមន្ទីរ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៤ | អនុប្រធានមន្ទីរ ពាណិជ្ជកម្ម | សមាជិក |
| ១៥ | អនុប្រធានមន្ទីរ ផែនការ | សមាជិក |
| ១៦ | អនុប្រធានមន្ទីរ អភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៧ | អនុប្រធានមន្ទីរ វប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៨ | អនុប្រធានមន្ទីរ សាធារណការ និងដឹកជញ្ជូន | សមាជិក |
| ១៩ | អនុប្រធានមន្ទីរ បរិស្ថាន | សមាជិក |
| ២០ | អនុប្រធានមន្ទីរ ប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២១ | អនុប្រធានមន្ទីរ ឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ២២ | អនុប្រធានមន្ទីរ ទេសចរណ៍ | សមាជិក |

[37] សេចក្តីសម្រេចលេខ ២១៦ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០១០ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រាជធានី ខេត្ត

| | | |
|---|---|---|
| ២៣ | អនុប្រធានមន្ទីរ ព័ត៌មាន | សមាជិក |
| ២៤ | អនុប្រធានមន្ទីរ ធម្មការ និងសាសនា | សមាជិក |
| ២៥ | អនុប្រធានមន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២៦ | តំណាងសាខាកាកបាទក្រហម រាជធានី ខេត្ត | សមាជិក |

ក.ជ.ក រាជធានី ខេត្ត ជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូន ក.ជ.ក លើការងារសម្របសម្រួល ពិនិត្យតាមដានវាយតម្លៃ ផ្សព្វផ្សាយច្បាប់ អនុសញ្ញាស្តីពីសិទ្ធិកុមារ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត នានារបស់រាជរដ្ឋាភិបាល និង ក.ជ.ក បំផុសចលនាគាំទ្រ ការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព។ រៀបចំផែនការ កម្មវិធីដើម្បីឧត្តមប្រយោជន៍របស់កុមារ និងធ្វើទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាល ក្នុងស្រុកនិងបរទេស ដែលមានគម្រោងការងារពាក់ព័ន្ធនឹងកុមារ ដើម្បីស្វែងរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ ទស្សនៈ រីកចម្រើនដែលទាក់ទងនឹងគោលដៅរួមក្នុងការកែលម្អស្ថានភាពកុមារ។ រៀបចំទិន្នន័យស្តីពីស្ថានភាពកុមារ ធ្វើរបាយការណ៍ផ្ទៀងផ្ទាត់នឹងគោលដៅសូចនាករកិច្ចការពារកុមារ និងចាត់ចែងអនុវត្តរាល់គោលការណ៍ ផែនការសកម្មភាព របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។[38]

### ៤.១.២. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររា "គ.ក.ស.ក" រាជធានី ខេត្ត

ក្រុមប្រឹក្សារាជធានី ខេត្ត បានបង្កើត គ.ក.ស.ក ដែលមានសិទ្ធិនិងមានភារកិច្ច[39] ផ្តល់យោបល់ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សារាជធានីខេត្ត គណៈអភិបាលរាជធានីខេត្ត អភិបាលរាជធានីខេត្ត និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សារាជធានីខេត្ត លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារដែលស្ថិតនៅក្នុងអំណាចមុខងារនិងភារកិច្ចរបស់ក្រុមប្រឹក្សារាជធានីខេត្ត។

*តារាងទី៥៖សមាសភាពគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមាររាជធានី ខេត្ត*

| ល.រ | សមាសភាព | តួនាទី |
|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សាជាស្ត្រីជ្រើសរើសដោយក្រុមប្រឹក្សា | ប្រធាន |
| ២ | សមាជិកក្រុមប្រឹក្សាជ្រើសរើសដោយក្រុមប្រឹក្សា | អនុប្រធាន |
| ៣ | អភិបាលរងជាស្ត្រី០១រូប | អនុប្រធាន |
| ៤ | ប្រធាន ឬអនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៥ | ប្រធាន ឬអនុប្រធានមន្ទីរកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| ៦ | នាយករងរដ្ឋបាល០១រូប | សមាជិក |
| ៧ | ប្រធាន ឬអនុប្រធានមន្ទីរផែនការ | សមាជិក |
| ៨ | ប្រធាន ឬអនុប្រធានមន្ទីរសុខាភិបាល | សមាជិក |
| ៩ | ប្រធាន ឬអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១០ | ប្រធាន ឬអនុប្រធានមន្ទីរអប់រំ យុវជន និងកីឡា | សមាជិក |
| ១១ | ប្រធាន ឬអនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១២ | ប្រធាន ឬអនុប្រធានមន្ទីរកសិកម្ម | សមាជិក |
| ១៣ | ស្នងការ ឬតំណាងស្នងការដ្ឋាននគរបាល | សមាជិក |

[38] ប្រការ ៣ នៃសេចក្តីសម្រេចលេខ លេខ ២១៦ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០១០ ស្តីពីការបង្កើត ក.ជ.ក រាជធានី ខេត្ត

[39] មាត្រា ១២៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ២០០៨

| | | |
|---|---|---|
| ១៤ | នាយក ឬនាយករងទីចាត់ការអន្តរវិស័យ | សមាជិក |
| ១៥ | ប្រធាន ឬអនុប្រធានសមាគមក្រុមប្រឹក្សាឃុំ សង្កាត់ | សមាជិក |
| ១៦ | តំណាងពីស្ថាប័ន ឬអង្គភាពផ្សេងៗទៀតតាមការចាំបាច់ | សមាជិក |

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ មានមុខងារចម្បងដូចជា៖ ចូលរួមក្នុង ការកសាងចក្ខុវិស័យជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងដើម្បីធ្វើឱ្យសម្រេចបាននូវសមភាពយេនឌ័រ និងការផ្តល់សេវាផ្សេងៗដែលពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារ។ ប្រមូល និងវិភាគព័ត៌មាននិងទិន្នន័យដែលទាក់ទងនឹងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ដើម្បីដាក់បញ្ចូលព័ត៌មានទាំងនេះ ទៅក្នុងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ក្រុមប្រឹក្សារាជធានីខេត្ត។ ស្វែងរកការគាំទ្រពីក្រុមប្រឹក្សា គណៈអភិបាល និងគណៈកម្មាធិការផ្សេងទៀតនៃក្រុមប្រឹក្សារាជធានីខេត្ត ដើម្បីលើកផែនការសកម្មភាពសម្រាប់ដោះស្រាយបញ្ហាសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានីខេត្ត។ សហការ និងផ្តល់ការគាំទ្រដល់ គ.ក.ស.ក ប្រភេទផ្សេងទៀតក្នុងការដោះស្រាយបញ្ហា ឬសំណូមពរឬសំណើនានា ដែលគណៈកម្មាធិការរបស់ក្រុមប្រឹក្សាប្រភេទផ្សេងនោះមិនអាចដោះស្រាយបានក្នុងការអនុវត្តមុខងាររបស់ខ្លួន។ លើកសំណើ និងផ្តល់យោបល់ជូនក្រុមប្រឹក្សាខេត្ត ឬគណៈអភិបាលខេត្តអំពីវិធានការសមស្របនានា ដើម្បីជំរុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការដោះស្រាយ និងទប់ស្កាត់នូវបញ្ហាដែលកើតមានឡើងពាក់ព័ន្ធនឹងស្ត្រី យុវវ័យនិងកុមារ។ ជំរុញការលើកកម្ពស់ការយល់ដឹងអំពីច្បាប់ និងគោលនយោបាយទាក់ទងនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារដល់សហគមន៍នានានៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត។ ជំរុញឱ្យមានការប្រមូលព័ត៌មានរបស់សហគមន៍អំពីបញ្ហាដែលបានកើតមានជាប្រចាំពាក់ព័ន្ធនឹងសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារនិងមានវិធានការដើម្បីឆ្លើយតប។ ពិនិត្យមើលលើការអនុវត្តគោលនយោបាយសមភាពយេនឌ័រ និងស្ថានភាពរបស់ស្ត្រី យុវវ័យ និងកុមារ ជាពិសេសដើម្បីកំណត់រកគម្លាតផ្សេងៗនៅក្នុងការទទួលបានសេវានានា និងដើម្បីលើកអនុសាសន៍ក្នុងការដោះស្រាយបញ្ហាទាំងនេះ។ រាយការណ៍ជូនក្រុមប្រឹក្សាលើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រ ការបង្កើនសមត្ថភាពដល់ស្ត្រី និងបញ្ហារបស់យុវវ័យ និងកុមារ។ គាំទ្រគ្រប់កិច្ចខិតខំប្រឹងប្រែងដើម្បីកៀរគរមូលនិធិសម្រាប់ការងារសមភាពយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ។

### ៤.១.៣. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ "គ.ក.ស.ក" ក្រុង ស្រុក ខណ្ឌ

ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ បានបង្កើត គ.ក.ស.ក ដែលមានសិទ្ធិ និងមានភារកិច្ចផ្តល់យោបល់ និងលើកអនុសាសន៍ជូនក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ គណៈអភិបាលស្រុក ក្រុង ខណ្ឌ អភិបាលក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការដទៃទៀតរបស់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ លើបញ្ហាពាក់ព័ន្ធនឹងសមភាពយេនឌ័រ បញ្ហាស្ត្រី យុវវ័យ និងកុមារដែលស្ថិតនៅក្នុងអំណាច មុខងារ និងភារកិច្ចរបស់ក្រុមប្រឹក្សា ក្រុង ស្រុក ខណ្ឌ។ ចំពោះមុខងារចម្បងៗមិនខុសពី គ.ក.ស.ក រាជធានី ខេត្តឡើយ គឺគ្រាន់តែមានវិសាលភាពក្នុងដែនសមត្ថកិច្ចក្រុង ស្រុក ខណ្ឌ តែប៉ុណ្ណោះ។

*តារាងទី៦៖សមាសភាពគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុង ស្រុក ខណ្ឌ*

| ល.រ | សមាសភាព | តួនាទី |
|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សាជាស្ត្រីជ្រើសរើសដោយក្រុមប្រឹក្សា | ប្រធាន |
| ២ | សមាជិកក្រុមប្រឹក្សាជ្រើសរើសដោយក្រុមប្រឹក្សា | អនុប្រធាន |
| ៣ | អភិបាលរងជាស្ត្រី០១រូប | អនុប្រធាន |
| ៤ | ប្រធាន ឬអនុប្រធានការិយាល័យ ស.អ.យ | អនុប្រធាន |

| | | |
|---|---|---|
| ៥ | ប្រធាន ឬអនុប្រធានការិយាល័យកិច្ចការនារី | អនុប្រធានអចិន្ត្រៃយ៍ |
| ៦ | នាយករងរដ្ឋបាល០១រូប | សមាជិក |
| ៧ | ប្រធាន ឬអនុប្រធានការិយាល័យផែនការ | សមាជិក |
| ៨ | ប្រធាន ឬអនុប្រធានការិយាល័យសុខាភិបាល | សមាជិក |
| ៩ | ប្រធាន ឬអនុប្រធានការិយាល័យអភិវឌ្ឍន៍ជនបទ(បើមាន) | សមាជិក |
| ១០ | ប្រធាន ឬអនុប្រធានការិយាល័យអប់រំ យុវជន និងកីឡា | សមាជិក |
| ១១ | ប្រធាន ឬអនុប្រធានការិយាល័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ(បើមាន) | សមាជិក |
| ១២ | ប្រធាន ឬអនុការិយាល័យកសិកម្ម | សមាជិក |
| ១៣ | អធិការ ឬតំណាងអធិការដ្ឋាននគរបាល | សមាជិក |
| ១៤ | ប្រធាន ឬអនុប្រធានការិយាល័យពាក់ព័ន្ធនៃសាលាក្រុង | សមាជិក |
| ១៤ | អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារសង្កាត់ចំណុះ | សមាជិក |
| ១៥ | តំណាងពីស្ថាប័ន ឬអង្គភាពផ្សេងៗទៀតតាមការចាំបាច់ | សមាជិក |

### ៤.១.៤. គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ "គ.ក.ន.ក"

ផ្អែកលើបទពិសោធន៍នៃការអនុវត្តកម្មវិធីសិទ្ធិកុមារសាកល្បងនៅឃុំចំនួន៤២២ នៃខេត្តចំនួន៦ ដែលជាឃុំគោលដៅរបស់អង្គការយូនីសេហ្វបានបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ នៅឆ្នាំ ២០០៤ គណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានចេញសេចក្តីណែនាំលេខ ០៨២ ស.ណ.ន/គ.ជ.វ.វ ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេសដើម្បីឱ្យឃុំសង្កាត់ទាំងអស់រៀបចំ និងបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់។

***តារាងទី៧៖សមាសភាពគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់***

| ល.រ | សមាសភាព | តួនាទី |
|---|---|---|
| ១ | មេឃុំ ចៅសង្កាត់ | ប្រធាន |
| ២ | ជំទប់ទី២ ឬចៅសង្កាត់រងទី២ | អនុប្រធាន |
| ៣ | អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤ | ស្មៀនឃុំ សង្កាត់ | សមាជិក |
| ៥ | នាយ ឬនាយរងប៉ុស្តិ៍នគរបាលឃុំ សង្កាត់១រូប | សមាជិក |
| ៦ | នាយកសាលា ឬតំណាង១រូប | សមាជិក |
| ៧ | ប្រធានមណ្ឌលសុខភាព ឬតំណាង១រូប | សមាជិក |
| ៨ | មេភូមិ ឬអនុប្រធានប្រធានភូមិ១រូប គ្រប់ភូមិ | សមាជិក |

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ មានមុខងារចម្បងៗដូចជា៖ រៀបចំផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានយល់ដឹងអំពីច្បាប់ គោលនយោបាយនានារបស់រដ្ឋពាក់ព័ន្ធសិទ្ធិនារី និងបំផុសចលនាសហគមន៍លើវិស័យសុខភាព អប់រំកិច្ចការពារ ការអភិវឌ្ឍកុមារ ចុះបញ្ជីអត្រានុកូលដ្ឋានជូនទារកនិងកុមារ។ ទាក់ទាញការគាំទ្រដើម្បីឱ្យនារីបានចូលរួមធ្វើសេចក្តីសម្រេចលើការអភិវឌ្ឍនៅ

មូលដ្ឋាន បង្កើននិងពង្រឹងនូវការប្រាស្រ័យទាក់ទងកិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកផ្តល់សេវាកម្ម និងអ្នកភូមិដែលធ្វើសកម្មភាពជួយនារីនិងកុមារ។ ប្រមូល វិភាគព័ត៌មាន ទិន្នន័យពាក់ព័ន្ធនឹងបញ្ហា និងតម្រូវការរបស់នារីនិងកុមារ ដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់។ ចូលរួមអនុវត្ត ពិនិត្យតាមដាននិងវាយតម្លៃផែនការសកម្មភាព ស្ថានភាពនារី និងកុមារ និងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាឃុំ សង្កាត់។

ទន្ទឹមនឹងអនុវត្តមុខងារចម្បងខាងលើ គ.ក.ន.ក ចូលរួមអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាពដែលចាប់ផ្តើមអនុវត្តតាំងពីឆ្នាំ២០១០ កន្លងមក គឺជាយន្តការមួយដើម្បីកាត់បន្ថយបទល្មើសនៅថ្នាក់មូលដ្ឋានទូទាំងប្រទេស រួមមានអំពើចោរកម្មជាអាទិ៍លួចឆក់ ប្លន់ អំពើហិង្សាក្នុងគ្រួសារ ការជួញដូរមនុស្ស គ្រឿងញៀន ល្បែងស៊ីសង សកម្មភាពទំនើង និងការប្រើប្រាស់អាវុធខុសច្បាស់ជាដើម ។ល។

គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព

១. គ្មានសកម្មភាពលួច ឆក់ ប្លន់គ្រប់ប្រភេទ

២. គ្មានការដាំដុះ ការផលិត ការចរាចរ ការជួញដូរការចែកចាយ និងការប្រើប្រាស់គ្រោះងញៀនខុសច្បាប់

៣. គ្មានអំពើអាណាចារ្យ ការជួញដូរស្ត្រីនិងកុមារ និងអំពើហិង្សាក្នុងគ្រួសារ

៤. គ្មានក្មេងទំនើង

៥. គ្មានការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការប្រើប្រាស់អាវុធខុសច្បាប់ និងបទល្មើសគ្រប់ប្រភេទ

៦. គ្មានគ្រោះថ្នាក់ចរាចរណ៍

៧. គ្មានគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

៨. មានវិធានការការទប់ស្កាត់ គ្រប់គ្រង និងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព

៩. គ្មានការត្រួតពិនិត្យខុសច្បាប់

គ.ក.ន.ក ចូលរួមអនុវត្តសេចក្តីសម្រេចលេខ១៩៥៦ សសរ ចុះថ្ងៃទីចុះថ្ងៃទី២ ឧសភា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំសង្កាត់។ សៀវភៅណែនាំនេះបានបញ្ជាក់ពីបញ្ហាសេវាសង្គមមួយចំនួននៅឃុំ សង្កាត់មានដូចជា សុខភាពមាតា ទារកនិងអាហារូបត្ថម្ភ អនាម័យ និងទឹកស្អាត កិច្ចការពារកុមារ ការអប់រំកុមារតូច និងភាពងាយរងគ្រោះជាដើម។ បញ្ហាទាំងនោះសុទ្ធសឹងជាអាទិភាពតម្រូវឱ្យក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រុមប្រឹក្សា ឃុំ សង្កាត់ និង គ.ក.ន.ក បង្កើនការយកចិត្តទុកដាក់ក្នុងការផ្តល់សេវាសង្គមឱ្យកាន់តែមានប្រសិទ្ធភាព តម្លាភាព និងសមធម៌។

*តារាងទី៨៖សូចនាករសេវាសង្គមដែលឃុំ សង្កាត់យកចិត្តទុកដាក់*

| ល.រ | សូចនាករ | បញ្ហាសេវាសង្គម |
|---|---|---|
| ១ | ខ្នងផ្ទះស្ត្រីមានផ្ទៃពោះមិនបានទៅពិនិត្យផ្ទៃពោះមុនពេលសម្រាល | បញ្ហាសុខភាពមាតា ទារក និងអាហារូបត្ថម្ភ |
| ២ | ខ្នងផ្ទះស្ត្រីមានផ្ទៃពោះមិនបានសម្រាលកូននៅមូលដ្ឋានសុខាភិបាល | |
| ៣ | ខ្នងផ្ទះមានកុមារអាយុ ១២-២៣ខែដែលមិនបានចាក់ថ្នាំបង្ការគ្រប់ | |
| ៤ | ខ្នងផ្ទះមានកុមារស្គមស្គាំងនៅអាយុក្រោម៥ឆ្នាំ | |
| ៥ | ខ្នងផ្ទះគ្មានបង្គន់អនាម័យប្រើប្រាស់ | បញ្ហាទឹក និងអនាម័យ |
| ៦ | ខ្នងផ្ទះមិនបរិភោគទឹកមានសុវត្ថិភាព | |
| ៧ | ខ្នងផ្ទះដែលមានកុមារធ្លាប់ទទួលរងអំពើហិង្សា | បញ្ហាកិច្ចការពារកុមារ |
| ៨ | ខ្នងផ្ទះមានកុមារងាយរងគ្រោះចំពោះការបំបែកចេញពីគ្រួសារ | |

| | | |
|---|---|---|
| ៩ | ខ្នងផ្ទះមានកុមារវិលត្រលប់មកពីមណ្ឌលកុមារកំព្រារស់នៅជាមួយ | |
| ១០ | ខ្នងផ្ទះមានសមាជិកគ្រួសារដែលគ្មានសំបុត្រកំណើត ឬបញ្ជាក់កំណើត | |
| ១១ | ខ្នងផ្ទះមានកុមារអាយុ៣-៥ឆ្នាំមិនបានទទួលការអប់រំគ្រប់ទម្រង់នៃការអប់រំកុមារតូច | បញ្ហាការអប់រំកុមារតូច |
| ១២ | ខ្នងផ្ទះមានកុមាររៀននៅបឋមសិក្សា ហើយអាណាព្យាបាលមិនដែល បាន ជួនជាមួយតំណាងសាលា ឬគ្រូ | |
| ១៣ | ខ្នងផ្ទះមានអត្តសញ្ញាណកម្មគ្រួសារក្រីក្រ(ប័ណ្ណក្រីក្រ)មានសុពលភាព | បញ្ហាភាពងាយរងគ្រោះ |
| ១៤ | ខ្នងផ្ទះមានសមាជិកមានពិការភាព | |

*រូបភាពទី១២៖ គំរូផែនទីសេវាសង្គមសម្រាប់ភូមិនីមួយៗ*




គ្រប់ភូមិនៅក្នុងឃុំសង្កាត់នីមួយៗ បានរៀបចំផែនទីសេវាសង្គមតាមខ្នងផ្ទះដោយកំណត់ពីបញ្ហា និងតម្រូវការរបស់ប្រជាពលរដ្ឋដូចរូបភាពទី៩។ ដើម្បីកំណត់សូចនាករសេវាសង្គម គ.ក.ន.ក បានធ្វើការប្រមូលទិន្នន័យពីមណ្ឌលសុខភាព និងប៉ុស្តិ៍នគរបាល ឬប្រភពផ្សេងទៀតពីគ្រប់ភូមិ។

*តារាងទី៩៖ ទិន្នន័យសម្រាប់រៀបចំផែនទីសេវាសង្គម*

| ល.រ | ឈ្មោះភូមិ | មណ្ឌលសុខភាព | | | | ប៉ុស្តិ៍នគរបាល និងប្រភពផ្សេងៗ | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| | | ស្ត្រីមានផ្ទៃពោះមិនបានទៅពិនិត្យផ្ទៃពោះមុនពេលសម្រាល | ស្ត្រីមានផ្ទៃពោះមិនបានសម្រាលកូននៅមូលដ្ឋានសុខាភិបាល | កុមារអាយុ១២-២៣ខែដែលមិនបានចាក់ថ្នាំបង្ការគ្រប់ | កុមារស្គមស្គាំងនៅអាយុក្រោម៥ឆ្នាំ | ពលកម្មកុមារ | កុមារចំណាកស្រុក | ការជួញដូរកុមារ | ការរំលោភបំពានរាងកាយនិងការរំលោភបំពានផ្លូវភេទ | បញ្ហាផ្សេងៗ --------- | |
| ១ | | | | | | | | | | | |
| ២ | | | | | | | | | | | |
| ៣ | | | | | | | | | | | |
| ៤ | | | | | | | | | | | |
| ៥ | | | | | | | | | | | |
| សរុប | | | | | | | | | | | |

### ៤.១.៥. យន្តការសម្របសម្រួលកិច្ចការពារកុមារពាក់ព័ន្ធថ្នាក់ក្រោមជាតិ

ក្រៅពី ក.ជ.ក រាជធានីខេត្ត គ.ក.ស.ក រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និង គ.ក.ន.ក ក៏នៅមានយន្តការសម្របសម្រួលកិច្ចការពារកុមារផ្សេងៗទៀត ជាខ្សែបណ្ដោយយន្តការថ្នាក់ជាតិដែលមានតួនាទីភារកិច្ចដូចមានចែងនៅក្នុងតារាងទី៩ ហើយយន្តការទាំងនោះរួមមាន៖

- គណៈកម្មការប្រឆាំងពលកម្មកុមាររាជធានីខេត្ត នៃ គ.ជ.ព។
- យន្តការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ក្រោមជាតិមាន គ.ក.ស.ក រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង គ.ក.ន.ក នៃ គ.ជ.គ.ក
- គណៈកម្មាធិការរាជធានី ខេត្ត (គរបជ/គខបជ) នៃ គ.ជ.ប.ជ

យន្តការទាំងបីខាងលើនេះមានអភិបាលរាជធានីខេត្តជាប្រធាន អនុប្រធានជាថ្នាក់ដឹកនាំ រាជធានីខេត្ត និងសមាជិកមកពីមន្ទីរ និងអង្គភាពពាក់ព័ន្ធ ដែលភាគច្រើននៃតំណាងទាំងនោះជាសមាជិក ក.ជ.ក និង គ.ក.ស.ក រាជធានី ខេត្ត។

ទោះបីក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានីខេត្ត គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមាររាជធានីខេត្ត និងយន្តការថ្នាក់ក្រោមជាតិនៃគណៈកម្មាធិការ ឬគណៈកម្មការដទៃទៀត មានមុខងារទទួលខុសត្រូវដាច់ដោយឡែកក៏ដោយ ប៉ុន្តែឯកឧត្តមអភិបាលរាជធានី ខេត្ត ជាថ្នាក់ដឹកនាំជាន់ខ្ពស់សម្រាប់ដឹកនាំ និងសម្របសម្រួលយន្តការទាំងនោះ។

*រូបភាពទី១៣៖យន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ក្រោមជាតិ*



*តារាងទី១០៖សង្ខេបយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ក្រោមជាតិ*

| ល.រ | ឈ្មោះយន្តការ | កម្រិតគតិយុត្ត | តួនាទី និងភារកិច្ច |
|---|---|---|---|
| ១ | ក.ជ.ក រាជធានី ខេត្ត | សេចក្តីសម្រេច អភិបាលរាជធានីខេត្ត | សម្របសម្រួល ពិនិត្យតាមដានវាយតម្លៃការអនុវត្ត អនុសញ្ញាស្តីពីសិទ្ធិកុមារ និងផ្សព្វផ្សាយច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល និងក.ជ.ក បំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព |
| | លេខាធិការដ្ឋាន មន្ទីរ ស.អ.យ | សេចក្តីសម្រេច ប្រធាន ក.ជ.ក | ជាសេនាធិការឱ្យ ក.ជ.ក |
| ២ | គ.ក.ស.ក រាជធានី ខេត្ត | សេចក្តីសម្រេច អភិបាលរាជធានីខេត្ត | ប្រមូល និងវិភាគព័ត៌មាន ទិន្នន័យដែលទាក់ទងនឹងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ដើម្បីដាក់បញ្ចូលព័ត៌មានទាំងនេះទៅក្នុងផែនការអភិវឌ្ឍន៍។ ជំរុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការដោះស្រាយនិងទប់ស្កាត់បញ្ហា ដែលកើតមានឡើងពាក់ព័ន្ធនឹងកិច្ចការស្ត្រី យុវវ័យ និងកុមារ។ រាយការណ៍ជូនក្រុមប្រឹក្សារាជធានី ខេត្ត លើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រ ការបង្កើនសមត្ថភាពដល់ស្ត្រី និងបញ្ហារបស់យុវវ័យ និងកុមារ |
| | ក្រុមការងារ គ.ក.ស.ក មន្ទីរ កិច្ចការនារី | សេចក្តីសម្រេច មន្ទីរកិច្ចការនារី | ជាសេនាធិការឱ្យ គ.ក.ស.ក |
| ៣ | គ.ក.ស.ក ក្រុង ស្រុក ខណ្ឌ | សេចក្តីសម្រេច អភិបាល ក្រុងស្រុក ខណ្ឌ | ប្រមូល និងវិភាគព័ត៌មាន ទិន្នន័យដែលទាក់ទងនឹងយេនឌ័រ និងតម្រូវការស្ត្រី យុវវ័យ និងកុមារ ដើម្បីដាក់បញ្ចូលព័ត៌មានទាំងនេះទៅក្នុងផែនការអភិវឌ្ឍន៍។ ជំរុញឱ្យមានការចូលរួមពីសមត្ថកិច្ចពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងការដោះស្រាយនិងទប់ស្កាត់នូវបញ្ហា ដែលកើតមានឡើងពាក់ព័ន្ធនឹងកិច្ចការស្ត្រី យុវវ័យ និងកុមារ។ រាយការណ៍ជូនក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌលើបញ្ហាដែលទាក់ទងនឹងសមភាពយេនឌ័រការ បង្កើនសមត្ថភាពដល់ស្ត្រី និងបញ្ហារបស់យុវវ័យ និងកុមារនៅក្នុងដែនសមត្ថកិច្ច ក្រុង ស្រុក ខណ្ឌ។ |
| ៤ | គ.ក.ន.ក ឃុំ សង្កាត់ | ដីកា ឬ សេចក្តីសម្រេច ឃុំ សង្កាត់ | អប់រំផ្សព្វផ្សាយអំពីច្បាប់ គោលនយោបាយពាក់ព័ន្ធសិទ្ធិនារី និងអប់រំពលរដ្ឋពីសុខភាព កិច្ចការពារ ការអភិវឌ្ឍកុមារ ចុះបញ្ជីអគ្រានុកូលដ្ឋានជូនទារកនិងកុមារ។ ប្រមូលវិភាគ ព័ត៌មានទិន្នន័យពាក់ព័ន្ធនឹងបញ្ហានិងតម្រូវការរបស់នារី និងកុមារដើម្បីដាក់បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ជាពិសេសគាំទ្រ |

| | | | |
|---|---|---|---|
| | | | ដល់ការអនុវត្តសកម្មភាពសេវាសង្គម[40]។ ចូលរួមអនុវត្តពិនិត្យតាមដាន និងវាយតម្លៃផែនការសកម្មភាពស្ថានភាពនារី និងកុមារ និងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ |
| ៥ | គណៈកម្មការប្រឆាំងពលកម្មកុមាររាជធានីខេត្ត | សេចក្តីសម្រេចអភិបាលរាជធានីខេត្ត | ពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តអនុសញ្ញានៃអង្គការអន្តរជាតិខាងការងារ និងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារនៅថ្នាក់ក្រោមជាតិ |
| ៦ | យន្តការគាំពារនិងអភិវឌ្ឍន៍កុមារតូចថ្នាក់ក្រោមជាតិ | សេចក្តីសម្រេចអភិបាលរាជធានីខេត្ត | អនុវត្តគោលនយោបាយជាតិស្តីពីការគាំពារ និងការអភិវឌ្ឍកុមារតូច និងពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តគ្រប់កម្មវិធីគាំពារ និងអភិវឌ្ឍកុមារតូចនៅថ្នាក់ក្រោមជាតិ |
| ៧ | គណៈកម្មាធិការរាជធានីខេត្ត គរបជ/គខបជ | សេចក្តីសម្រេចអភិបាលរាជធានីខេត្ត | ជំរុញនិងលើកកម្ពស់ការអនុវត្តច្បាប់ស្តីពីការបង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ដែលមានអង្គការចាត់តាំង ឬលិខិតតុបករណ៍ និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងៗទៀតទាក់ទងនឹងអំពើជួញដូរមនុស្សនៅថ្នាក់ក្រោមជាតិ |

## ៤.២. ការរកឃើញ និងអនុសាសន៍សម្រាប់យន្តការថ្នាក់ក្រោមជាតិ

៤.២.១.រាជធានី ខេត្តទាំង២៤ បានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នៅចន្លោះឆ្នាំ២០១០-២០១៣ បន្ទាប់ពី ក.ជ.ក ចេញសេចក្តីសម្រេចលេខ ២១៦ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី ខេត្ត មើលតារាងទី៩។ ក.ជ.ក រាជធានីខេត្ត ភាគច្រើនមិនមានដំណើរការតាំងពីបង្កើតមក[41] គឺបណ្តាលមកពីគ្មានថវិកាគាំទ្រ សមត្ថភាពលេខាធិការដ្ឋានមានកម្រិត និងប្រធាន ឬអនុប្រធាន និងសមាជិកមានការផ្លាស់ប្តូរតួនាទី ឬចូលនិវត្តន៍មិនទាន់ធ្វើបច្ចុប្បន្នភាព។ សមាជិក ក.ជ.ក និងលេខាធិការដ្ឋានមិនទទួលបានការបណ្តុះបណ្តាលស្តីពីការអនុវត្តតួនាទីភារកិច្ច ជាពិសេសមិនទាន់មានឧបករណ៍ដូចជាបែបបទ ទម្រង់ និងនីតិវិធីសម្រាប់ប្រមូលព័ត៌មាន និងទិន្នន័យការអនុវត្តសិទ្ធិកុមារ។

ដើម្បីដោះស្រាយបញ្ហាដូចបានរៀបរាប់ខាងលើគឺ អគ្គលេខាធិការដ្ឋាន ជួយជំរុញឱ្យរាជធានីខេត្តទាំង២៥ ធ្វើបច្ចុប្បន្នភាព ក.ជ.ក និងលេខាធិការដ្ឋាន (ឧបសម្ព័ន្ធ១.គំរូសេចក្តីសម្រេច)។ សមាសភាព ក.ជ.ក រាជធានី ខេត្តស្នើបញ្ចូលសមាជិកបន្ថែម ជាតំណាងតុលាការ(ចៅក្រមឬព្រះរាជអាជ្ញា)។ ការស្នើសុំបញ្ចូលសមាសភាពមកពីតុលាការនេះពីព្រោះមានករណីកុមារមួយចំនួនកកស្ទះនៅតុលាការ ដោយមិនមានអ្នកជួយជំរុញនីតិវិធីឱ្យបានឆាប់។ មានករណីខ្លះដោយសារតែនីតិវិធីយឺតយូរខ្លាំងពេកធ្វើឱ្យជនល្មើសមានឱកាសរត់គេចខ្លួនបាត់។ លេខាធិការដ្ឋាន ក.ជ.ក រាជធានី ខេត្ត គួរបន្ថែមសមាសភាពជាមន្ត្រីជំនាញមកពីមន្ទីរដែលជាអនុប្រធាន ក.ជ.ក និងតំណាងអង្គការចូលជា

---

[40] សេចក្តីសម្រេចលេខ ១៩៥៦ សសរ ចុះថ្ងៃទី២ ឧសភា ឆ្នាំ២០១៨ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តសកម្មភាពសេវាសង្គមឃុំ សង្កាត់

[41] ក.ជ.ក ខេត្តមួយចំនួនបាត់ត្រា ដោយសារមិនដែលប្រើ ឬមានផ្លាស់ប្តូរប្រធានមន្ទីរ និងមន្ត្រីជំនាញពាក់ព័ន្ធ

សមាជិកលេខាធិការដ្ឋាន។ គួររៀបចំបង្កើតបែបបទ ទម្រង់ និងនីតិវិធីសម្រាប់ប្រមូលព័ត៌មាន និងទិន្នន័យការអនុវត្តសិទ្ធិកុមារ។

អគ្គលេខាធិការដ្ឋាន គួររៀបចំផែនការបណ្តុះបណ្តាលស្តីពីការអនុវត្តតួនាទីភារកិច្ច ក.ជ.ក រាជធានី ខេត្ត លេខាធិការដ្ឋាន ក.ជ.ក និងបង្កើតបែបបទ ទម្រង់ និងនីតិវិធីប្រមូលព័ត៌មាន និងទិន្នន័យការអនុវត្តសិទ្ធិកុមារគ្រប់ជ្រុងជ្រោយ។ រកវិធីសាស្ត្រដែលអាចឱ្យមន្ទីរ ស.អ.យ លើកថវិកាបញ្ចូលទៅក្នុងផែនការថវិកាកម្មវិធីប្រចាំឆ្នាំសម្រាប់ជាកញ្ចប់ថវិកា[42] គាំទ្រសកម្មភាព ក.ជ.ក រាជធានី ខេត្ត។

*តារាងទី១១៖ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រាជធានី ខេត្តដែលបានបង្កើតកន្លងមក*

| ល.រ | ក.ជ.ក រាជធានី ខេត្ត | ឆ្នាំបង្កើត | ល.រ | ក.ជ.ក រាជធានី ខេត្ត | ឆ្នាំបង្កើត |
|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | ២០១១ | ១៤ | ភ្នំពេញ | ២០១១ |
| ២ | បាត់ដំបង | ២០១១ | ១៥ | ពោធិសាត់ | ២០១១ |
| ៣ | កំពង់ចាម | ២០១១ | ១៦ | ព្រះសីហនុ | ២០១១ |
| ៤ | កំពង់ឆ្នាំង | ២០១០ | ១៧ | ព្រៃវែង | ២០១១ |
| ៥ | កណ្តាល | ២០១១ | ១៨ | ព្រះវិហារ | ២០១១ |
| ៦ | កែប | ២០១១ | ១៩ | រតនគីរី | ២០១២ |
| ៧ | កោះកុង | ២០១៣ | ២០ | សៀមរាប | ២០១១ |
| ៨ | កំពត | ២០១១ | ២១ | ស្ទឹងត្រែង | ២០១៣ |
| ៩ | កំពង់ធំ | ២០១១ | ២២ | ស្វាយរៀង | ២០១១ |
| ១០ | ក្រចេះ | ២០១២ | ២៣ | តាកែវ | ២០១១ |
| ១១ | កំពង់ស្ពឺ | ២០១២ | ២៤ | ឧត្តរមានជ័យ | ២០១១ |
| ១២ | មណ្ឌលគីរី | ២០១១ | ២៥ | ត្បូងឃ្មុំ | |
| ១៣ | ប៉ៃលិន | ២០១១ | | | |

៤.២.២.គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅខេត្តគោលដៅ បានទទួលថវិកាបន្ថែមប្រមាណ ២០០០ ទៅ៣០០០ ដុល្លាអាមេរិក ពីអង្គការយូនីសេហ្វ ដើម្បីរៀបចំកិច្ចប្រជុំប្រចាំខែ ចុះត្រួតពិនិត្យតាមដានការងារស្ត្រី និងកុមារ ពិគ្រោះយោបល់ គ្រប់គ្រងករណី និងអន្តរាគមន៍ ការផ្តល់សេវាដល់មុខសញ្ញា។ ដោយឡែក គ.ក.ស.ក ខេត្តមួយចំនួនទៀតបានទទួលថវិកាវិភាជពីសាលាខេត្ត សម្រាប់រៀបចំកិច្ចប្រជុំប្រចាំខែដើម្បីដោះស្រាយបញ្ហារបស់ស្ត្រីនិងកុមារ និងចុះធ្វើអន្តរាគមន៍។

តាមមតិយោបល់ គ.ក.ស.ក និង ក.ជ.ក. ខេត្តទាំង៩ យល់ឃើញថា យន្តការទាំងពីរមាន ភារកិច្ចដាច់ដោយឡែកពីគ្នា គឺ ក.ជ.ក. មានមុខងារត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិរបស់កុមារ ចំណែកឯ គ.ក.ស.ក.មានមុខងារធ្វើអន្តរាគមន៍ និងសម្របសម្រួលការផ្តល់សេវា។ តាមស្ថានភាពជាក់ស្តែង គ.ក.ស.ក. និង ក.ជ.ក. អាចបំពេញមុខងារបន្ថែមឱ្យគ្នាទៅវិញទៅមក។ គ.ក.ស.ក.បានបង្កើតក្រុមការងារ គ.ក.ស.ក មានសមាសភាពលេខារបស់ គ.ក.ស.ក មន្ត្រីមន្ទីរកិច្ចការនារី ជាក្រុមការងារ ក.ជ.ក ជាសេនាធិការ ដើម្បីជួយរៀបចំកិច្ចប្រជុំ និងសម្របសម្រួលជាមួយមន្ទីរ និងអង្គភាពពាក់ព័ន្ធដើម្បីដោះស្រាយបញ្ហានិងឆ្លើយតបតម្រូវការរបស់ស្ត្រីនិងកុមារ។ ចំណែក ក.ជ.ក រាជធានី ខេត្ត បានបង្កើតលេខាធិការដ្ឋានដឹកនាំដោយអនុប្រធានមន្ទីរ ស.អ.យ ដែលទទួលបន្ទុកសុខុមាលភាពកុមារ និងការិយាល័យ

[42] ប្រការ ៩ នៃសេចក្តីសម្រេចលេខ លេខ ២១៦ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ២០១០ ស្តីពីការបង្កើត ក.ជ.ក រាជធានី ខេត្ត

សុខុមាលភាពកុមារជាសេនាធិការ ដើម្បីពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ។ ដើម្បីឱ្យក្រុមការងារ គ.ក.ស.ក និង លេខាធិការដ្ឋាន បំពេញមុខងារសម្របសម្រួលកិច្ចការពារកុមារ ត្រូវធ្វើការពង្រឹងសមត្ថភាព និងរៀបចំទម្រង់របាយការណ៍រួមសម្រាប់ប្រមូលលទ្ធផលសូចនាករការអនុវត្តសិទ្ធិកុមារ និងប្រព័ន្ធទំនាក់ទំនងការងាររវាងលេខាធិការដ្ឋាន ក.ជ.ក រាជធានី ខេត្ត និងក្រុមការងារ គ.ក.ស.ក រាជធានីខេត្ត ជាពិសេសត្រូវចាត់ឱ្យប្រធានលេខាធិការដ្ឋាន គ.ក.ស.ក ជាអនុប្រធាន គ.ក.ស.ក។

៤.២.៣.ការសិក្សានេះមិនបានជួបសម្ភាសន៍ជាមួយ គណៈកម្មការប្រឆាំងពលកម្មកុមាររាជធានីខេត្តនៃគ.ជ.ព យន្តការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ក្រោមជាតិមាន គ.ក.ស.ក រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង គ.ក.ន.ក នៃ គ.ជ.គ.ក. គណៈកម្មាធិការរាជធានី ខេត្ត គរបជ/គខបជ នៃ គ.ជ.ប.ជ និង គ.ក.ស.ក ក្រុង ស្រុក និង គ.ក.ន.ក ឃុំ សង្កាតទេ ប៉ុន្តែបានទទួលព័ត៌មានពីប្រធាន និងសមាជិក គ.ក.ស.ក និង ក.ជ.ក ដែលបានបញ្ជាក់ថាយន្តការទាំងនោះជួបប្រទះបញ្ហាថវិកា និងសមត្ថភាពជំនាញផងដែរសម្រាប់បំពេញមុខងាររបស់ខ្លួន។

## ៤.៣. ជម្រើសសម្រាប់យន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ក្រោមជាតិ

### ៤.៣.១.ជម្រើសទី១. ពង្រឹងសមត្ថភាពលេខាធិការដ្ឋាន ក.ជ.ក រាជធានី ខេត្ត

ប្រការ ៧ នៃសេចក្តីសម្រេចលេខ ២១៦ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជារាជរាជី ខេត្ត បញ្ជាក់ថា ក.ជ.ក រាជធានី ខេត្ត ត្រូវប្រើប្រាស់ការិយាល័យសុខុមាលភាពកុមារ នៃ មន្ទីរ ស.អ.យ រាជធានីខេត្តជាលេខាធិការដ្ឋាន និងប្រការ ៨ លេខាធិការដ្ឋាន ក.ជ.ក រាជធានី ខេត្ត ដឹកនាំ ដោយអនុប្រធានមន្ទីរ ស.អ.យ ដែលទទួលបន្ទុកការងារសុខុមាលភាពកុមារ។ ចំណែកឯកការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន ក.ជ.ក ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន ក.ជ.ក រាជធានីខេត្ត។

កន្លងមកលេខាធិការដ្ឋាន ក.ជ.ក រាជធានី ខេត្ត មិនសូវដំណើរការបានល្អទេតាំងពីបង្កើតមកដោយ មិនបានបញ្ជាក់ពីតួនាទីច្បាស់លាស់ និងដែនសមត្ថកិច្ចមានកម្រិត។ ដើម្បីឱ្យលេខាធិការដ្ឋានមានសមត្ថភាព គ្រប់គ្រាន់ដើម្បីបំពេញមុខងាររបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ក.ជ.ក រាជធានី ខេត្តត្រូវធ្វើការកែសម្រួលលេខាធិការដ្ឋានដោយជ្រើសរើសប្រធាន ឬអនុប្រធានមន្ទីរ ស.អ.យ រាជធានី ខេត្ត ដែលទទួលបន្ទុកសុខុមាលភាពកុមារជាប្រធានលេខាធិការដ្ឋាន(ដែលជាអនុប្រធាន គ.ក.ស.ក)។ លេខាធិការដ្ឋានគួរ តែបន្ថែមសមាសភាពសមាជិកជាមន្ត្រីមកពីមន្ទីរកិច្ចការនារី មន្ទីរអប់រំ យុវជន និងកីឡា មន្ទីរសុខាភិបាល មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមន្ត្រីនគរបាលមកពីស្នងការដ្ឋាននគរបាលខេត្ត។ ត្រូវធ្វើការកំណត់ពីតួនាទីនិងភារកិច្ចរបស់លេខាធិការដ្ឋាន ក.ជ.ក. រាជធានី ខេត្ត ឱ្យបានច្បាស់លាស់ដូចខាងក្រោមៈ

- *រៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំដាក់បញ្ចូលទៅក្នុងកញ្ចប់ថវិការបស់មន្ទីរ ស.អ.យ*
- *រៀបចំកិច្ចប្រជុំ ក.ជ.ក ខេត្ត ២ដងក្នុង១ឆ្នាំ និងកិច្ចប្រជុំវិសាមញ្ញតាមការចាំបាច់*
- *សហការ និងសម្របសម្រួលជាមួយមន្ទីរកិច្ចការនារី "ក្រុមការងារ គ.ក.ស.ក" មន្ទីរ និងអង្គភាពពាក់ព័ន្ធដើម្បីប្រមូលព័ត៌មាន និងទិន្នន័យការអនុវត្តសិទ្ធិកុមារ។*
- *ពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារនៅក្នុងខេត្ត និងរាយការណ៍ជូនប្រធាន ក.ជ.ក ដើម្បីអន្តរាគមន៍*
- *ចូលរួមប្រជុំជាមួយ គ.ក.ស.ក ប្រចាំខែដើម្បីប្រមូលទិន្នន័យ និងឆ្លើយតបចំពោះការអនុវត្តសិទ្ធិកុមារ*
- *រៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពអនុវត្តសិទ្ធិកុមារ*
- *ធ្វើរបាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមារ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនប្រធាន ក.ជ.ក និង ចម្លងជូនអគ្គលេខាធិការដ្ឋាន ក.ជ.ក។*
- *អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធាន ក.ជ.ក. ប្រគល់ជូន។*

ចំពោះការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាន ក.ជ.ក រាជធានី ខេត្ត ដោយបន្ថែមសមាសភាព និងតួនាទីភារកិច្ច អាចចេញជាសេចក្តីសម្រេចរបស់ប្រធាន ក.ជ.ក រាជធានី ខេត្ត ដាច់ដោយឡែក ឬបញ្ចូលជាប្រការមួយនៃសេចក្តីសម្រេចបង្កើត ក.ជ.ក រាជធានី ខេត្តរបស់គណៈអភិបាល។

*រូបភាពទី១៤៖គំនូសបំព្រួញយន្តការសម្របសម្រួលថ្នាក់ក្រោមជាតិជម្រើសទី១*




ដើម្បីអនុវត្តជម្រើសទី១ ប្រធាន ក.ជ.ក រាជធានី ខេត្ត ត្រូវចេញសេចក្តីសម្រេចបង្កើតលេខាធិការដ្ឋាន ឬដាក់បញ្ចូលទៅក្នុងសេចក្តីសម្រេចបង្កើត ក.ជ.ក រាជធានី ខេត្ត ត្រូវបន្ថែមសមាសភាព និងតួនាទី ដូចបានបញ្ជាក់ខាងលើ។ អគ្គលេខាធិការដ្ឋាន ក.ជ.ក ត្រូវរៀបចំវគ្គបណ្តុះបណ្តាលពីការអនុវត្តតួនាទី ភារកិច្ច និងបង្កើតទម្រង់ប្រមូលព័ត៌មាន និងទិន្នន័យការអនុវត្តសូចនាករសិទ្ធិកុមារសម្រាប់ឱ្យលេខាធិការដ្ឋានធ្វើការប្រមូលនៅពេលប្រជុំ គ.ក.ស.ក ប្រចាំខែ និងបង្កើតគំរូរបាយការណ៍ស្តីពីស្ថានភាព និងការអនុវត្តសិទ្ធិកុមារសម្រាប់រាយការណ៍ជូនប្រធាន ក.ជ.ក និងចម្លងជូនអគ្គលេខាធិការដ្ឋាន ក.ជ.ក។ ប្រធាន ឬអនុប្រធានលេខាធិការដ្ឋានត្រូវធ្វើការជាមួយ ក្រុមការងារ គ.ក.ស.ក ជាប្រចាំដើម្បីផ្លាស់ប្តូរព័ត៌មាន និងប្រមូលទិន្នន័យសូចនាករសិទ្ធិកុមារ និងអន្តរាគមន៍ទាន់ពេល។

### ៤.៣.២.ជម្រើសទី២.ស្នើសុំអភិបាលរាជធានី ខេត្តជាប្រធានយន្តការសម្របសម្រួលថ្នាក់ក្រោមជាតិ

ស្នើសុំអភិបាលរាជធានី ខេត្ត ធ្វើជាប្រធានយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ក្រោមជាតិដែលបច្ចុប្បន្ន ក.ជ.ក មានអភិបាលរាជធានីខេត្តជាប្រធានកត្តិយស អភិបាលរងជាប្រធាន ក.ជ.ក. រាជធានីខេត្ត។ គ.ក.ស.ក. ដឹកនាំដោយសមាជិកក្រុមប្រឹក្សាជាប្រធាន រាយការណ៍ជូនអភិបាលរាជធានីខេត្ត គណៈកម្មការប្រឆាំងពលកម្មកុមាររាជធានីខេត្តនៃ គ.ជ.ព យន្តការគាំពារនិងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ក្រោមជាតិមាន គ.ក.ស.ក រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង គ.ក.ន.ក នៃ គ.ជ.គ.ក និង គណៈកម្មាធិការរាជធានី ខេត្ត គរបជ/គខបជ នៃ គ.ជ.ប.ជ មានអភិបាលឬអភិបាលរង រាជធានី ខេត្តជាប្រធាន។ យន្តការទាំងអស់អនុវត្តភារកិច្ចដាច់ដោយឡែកពីគ្នាទៅតាមមុខសញ្ញាដែលទទួលខុសត្រូវ មិនមានប្រធានដឹកនាំសម្របសម្រួលរួមទេ។

*រូបភាពទី១៥៖គំនូសបំព្រួញយន្តការសម្របសម្រួលថ្នាក់ក្រោមជាតិជម្រើសទី២*




ដើម្បីអនុវត្តជម្រើសទី២ អភិបាលរាជធានីខេត្ត គួរចេញសេចក្តីសម្រេចបង្កើតយន្តការសម្របសម្រួលកិច្ចការពារកុមារ ដើម្បីដឹកនាំ និងសម្របសម្រួលអ្នកពាក់ព័ន្ធដូចរូបភាពទី១៤។ យន្តការនេះត្រូវកំណត់យក ក.ជ.ក រាជធានី ខេត្ត ដែលមានលេខាធិការដ្ឋាន ក.ជ.ក ធ្វើជាសេនាធិការ ដើម្បីសម្របសម្រួល និងធ្វើទំនាក់ទំនងការងារជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការនានានៅក្នុងរាជធានីខេត្តដែលអនុវត្តសិទ្ធិកុមារ។

## ៥. សិក្ខាសាលាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

### ៥.១. លទ្ធផលសិក្ខាសាលាថ្នាក់ក្រោមជាតិ

នៅថ្ងៃព្រហស្បតិ៍ ១៤ រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០១៩ នៅសណ្ឋាគារខេមរាអង្គរ ខេត្តសៀមរាប ដោយមានកិច្ចសហការជាមួយអង្គការយូនីសេហ្វ អង្គការភ្លែនអន្តរជាតិកម្ពុជា និងអង្គការសកម្មភាពដើម្បីកុមារ អគ្គលេខាធិការដ្ឋាន ក.ជ.ក. បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការសិក្សាបឋមលើយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលបំណងដើម្បីពិនិត្យកែសម្រួល និងប្រមូលធាតុចូល។[43] សិក្ខាសាលាបានប្រព្រឹត្តទៅក្រោមអធិបតីភាពលោកជំទាវ **ខៀវ ម៉ូរី** រដ្ឋលេខាធិការ ក្រសួង ស.អ.យ អនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ តំណាងឯកឧត្តមប្រធាន ក.ជ.ក និងមានសមាជិកចូលរួមសរុបចំនួន ១១៤នាក់(ស្រី៥៦នាក់) ដែលជាប្រធាន ក.ជ.ក ប្រធាន គ.ក.ស.ក និងប្រធាន ឬអនុប្រធានមន្ទីរ ស.អ.យ ទាំង២៥ រាជធានី ខេត្ត។ បន្ទាប់ពីមតិបើកអង្គសិក្ខាសាលារបស់លោកជំទាវគណៈអធិបតី ក្រុមការងារបានធ្វើបទបង្ហាញស្តីពីបច្ចុប្បន្នភាពក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងរបាយការណ៍ស្តីពីការសិក្សាបឋមលើយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រួមទាំងបើកឱ្យមាននមតិចូលរួម និងបែងចែកក្រុមពិភាក្សាជាបីក្រុម។

[43] ការសិក្សានេះទទួលបានការឯកភាពជាគោលការណ៍ពីឯកឧត្តមរដ្ឋមន្ត្រី ប្រធាន ក.ជ.ក ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០១៩

*រូបភាពទី១៦៖សកម្មភាពសិក្ខាសាលាថ្នាក់ក្រោមជាតិ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩*



បន្ទាប់ពីបទបង្ហាញ និងពិភាក្សាជាក្រុមរយៈពេលមួយថ្ងៃ អង្គសិក្ខាសាលាបានឯកភាពយកជម្រើសទី១ ក្នុងចំណោមជម្រើសយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិទាំង៣ និងយកជម្រើសទី១ ក្នុងចំណោមជម្រើសយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ក្រោមជាតិទាំង២។ ស្នើសុំបន្ថែមសមាសភាពតុលាការមួយរូបជាសមាជិក គ.ជ.ក. រាជធានី ខេត្ត។ ឯកភាពទាំងស្រុងលើគំរូសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើត គ.ជ.ក រាជធានី ខេត្ត ភ្ជាប់នៅឧបសម្ព័ន្ធទី២។ ស្នើសុំបន្ថែមមន្ត្រីជំនាញ១រូប ពីគ្រប់មន្ទីរដែលជាអនុប្រធាន គ.ជ.ក រាជធានី ខេត្ត ចូលរួមជាសមាជិកលេខាធិកាដ្ឋាន គ.ជ.ក រាជធានី ខេត្ត។ ស្នើសុំប្រធាន ឬអនុប្រធានមន្ទីរ ស.អ.យ ដែលជាអនុប្រធាន គ.ក.ស.ក ធ្វើជាប្រធានលេខាធិការដ្ឋាន គ.ជ.ក រាជធានី ខេត្ត។ កំណត់យកសូចនាករនៅក្នុងឧបសម្ព័ន្ធទី៤៖ សូចនាករទី៦ដល់១០, ១៣ដល់១៩, ២១ដល់២៥, ៣០ដល់៣៦, ៣៨,៤០,៤៤,៤៩,៥០, ៥៣ដល់៥៨,៦០,៦២។ កំណត់យកសូចនាករនៅក្នុងឧបសម្ព័ន្ធទី៣៖សូចនាករទី១ដល់ទី៦,៩ដល់១៨, ២៦,២៩,៣២ដល់៣៨, ៤០ដល់៤៨, ៥២ដល់៥៦។ កំណត់យកសូចនាករក្នុងប្រព័ន្ធទិន្នន័យ CDB លើកលែងតែ ចំណុចទី៩ និងទី១០ និងស្នើសុំឱ្យអគ្គលេខាធិការដ្ឋាន គ.ជ.ក ពិនិត្យឡើង វិញនិងកំណត់យកសូចនាករពាក់ព័ន្ធដែលអាចមានទិន្នន័យប្រមូលបាន មានភ្ជាប់នៅឧបសម្ព័ន្ធទី៤ ។

អង្គសិក្ខាសាលាក៏បានឯកភាពលើទម្រង់របាយការណ៍សម្រាប់ គ.ជ.ក រាជធានី ខេត្ត ដើម្បីរាយការណ៍ភ្ជាប់នៅឧបសម្ព័ន្ធទី៥។ គ.ក.ស.ក. ត្រូវធ្វើផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំបញ្ចូលក្នុងផែនការរដ្ឋបាលរាជធានី ខេត្ត ដោយផ្អែកលើតួនាទីនិងភារកិច្ច(ដែលអាចរំលេចចេញក្នុងអនុគណនី) និងត្រូវបង្ហាញនូវសមត្ថភាពសកម្មភាព និងសូចនាករលទ្ធផល។ គ.ជ.ក រាជធានី ខេត្ត ត្រូវរៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំដោយផ្សារភ្ជាប់តួនាទីភារកិច្ច គ.ជ.ក រួមទាំងកណត់សូចនាករច្បាស់លាស់ និងស្នើទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយមានការគាំទ្រពីថ្នាក់ដឹកនាំ គ.ជ.ក ផង។ រៀបចំកិច្ចប្រជុំឱ្យបានទៀងទាត់ជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលមានសកម្មភាពពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិកុមារនៅក្នុងដែនសមត្ថកិច្ច ដើម្បីកៀរគរធនធានទាំងថវិកានិងបច្ចេកទេសគាំទ្រផែនការសកម្មភាពដែលបានឯកភាព។ ជាពិសេសស្នើសុំឱ្យមានការគាំទ្រពីប្រធានក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ប្រកបដោយឆន្ទៈ។

## ៥.២. លទ្ធផលសិក្ខាសាលាថ្នាក់ជាតិ

ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ នៅសណ្ឋាគារភ្នំពេញ ដោយមានកិច្ចសហការជាមួយអង្គការយូនីសេហ្វ អគ្គលេខាធិការដ្ឋាន គ.ជ.ក. បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការសិក្សាមូលដ្ឋានលើយន្តការពារកុមារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក្រោមអធិបតីភាពលោកជំទាវ **ខៀវ ម្ញូរី** រដ្ឋលេខាធិការក្រសួង ស.អ.យ និងជា

អនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ តំណាងឯកឧត្តមប្រធាន ក.ជ.ក។ សិក្ខាសាលារៀបចំឡើងក្នុងគោលបំណង ដើម្បីប្រមូលធាតុចូល ព្រមទាំងពិនិត្យនិងពិភាក្សាលើអនុសាសន៍ដែលបានលើកឡើងក្នុងការសិក្សាស្រាវជ្រាវសេចក្តីព្រាងទី២។ សមាសភាពចូលរួមសរុបចំនួន៧៧នាក់(ស្រី៣៣នាក់) ដែលជាប្រធាន អនុប្រធាន សមាជិក សមាជិកាគណៈកម្មការការពារកុមារថ្នាក់ជាតិ និងជាមន្ត្រីក្រសួងស្ថាប័ន និងអង្គការមិនមែនរដ្ឋាបាលពាក់ព័ន្ធមួយចំនួនទៀត។

ជាកិច្ចចាប់ផ្តើមកម្មវិធីលោកជំទាវ **ញ៉ែម សុភាព** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន ក.ជ.ក បានរាយការណ៍អំពីដំណើរការនៃការសិក្សាមូលដ្ឋានស្តីពីយន្តការសម្របសម្រួលកិច្ចការពារកុមារនៅថ្នាក់ជាតិ និងក្រោមជាតិ ព្រមទាំងលទ្ធផលនាសិក្ខាសាលាថ្នាក់ក្រោមជាតិនៅខេត្តសៀមរាបកាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩។ បន្ទាប់មកលោកស្រី SILVAI Pasti ប្រធានស្តីទី ផ្នែកកិច្ចការពារកុមារ អង្គការយូនីសេហ្វប្រចាំកម្ពុជា បានលើកឡើងថាការសិក្សាស្រាវជ្រាវនេះនឹងរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ៥ឆ្នាំ "២០១៩-២០២៣" របស់ ក.ជ.ក. ផែនការយុទ្ធ៥ឆ្នាំ របស់ក្រសួង ស.អ.យ. និងផែនការកម្មវិធីប្រចាំប្រទេស៥ឆ្នាំ"២០១៩-២០២៣" របស់អង្គការយូនីសេហ្វ។ លោកស្រីបានបញ្ជាក់ទៀតថា យន្តការសម្របសម្រួលកិច្ចការពារកុមារទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មិនទាន់មានដំណើរការពេញលេញនៅឡើយទេ ដោយការវិភាជថវិកាមានកម្រិត ដែលនាំឱ្យគ្មានលទ្ធភាពធ្វើការពិនិត្យតាមដាន និងធ្វើរបាយការណ៍ទៀងទាត់ពីការអនុវត្តកិច្ចការពារកុមារ។ លោកស្រីក៏បានបញ្ជាក់ផងដែរថា អង្គការយូនីសេហ្វនឹងបន្តគាំទ្រសកម្មភាពចំនួនបីគឺៈ ១.គាំទ្រដល់ស្ថាប័នរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល ដើម្បីពង្រឹងគ្រួសារដោយប្រកាន់ខ្ជាប់នូវការចិញ្ចឹមកូនដោយវិជ្ជមាននិងកម្មវិធីការពារកុមារនៅកម្ពុជា ២.គាំទ្រដល់កម្លាំងសេវាសង្គមសម្រាប់ការពារកុមារឱ្យកាន់តែទូលំទូលាយ ដើម្បីកំណត់អត្តសញ្ញាណកុមាររងាយរងគ្រោះ និងផ្តល់សេវាបង្ការនិងឆ្លើយតបដល់ជនរងគ្រោះ ៣.គាំទ្រដល់ការអនុវត្តតុលាការកុមារមេត្រីដើម្បីការការពារអនីតិជនទំនាស់នឹងច្បាប់ និងគាំទ្រដល់ការការពារផ្នែកច្បាប់សម្រាប់ជនរងគ្រោះនិងជម្រើសផ្សេងទៀតក្នុងការឃុំខ្លួនអនីតិជន។

*រូបភាពទី១៧ៈសកម្មភាពសិក្ខាសាលាថ្នាក់ជាតិថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩*



លោកជំទាវ **ខៀវ បូរី** រដ្ឋលេខាធិការក្រសួង ស.អ.យ និងជាអនុប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានថ្លែងសន្ទរកថាបើកសិក្ខាសាលា ដោយលោកជំទាវបានជម្រាបជូនអំពីបុព្វហេតុនៃការបង្កើតក្រុមប្រឹក្សាជាតិម្ពុជា និងការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារថ្នាក់រាជធានីខេត្ត និងបានជម្រាបជូនពីការងារសម្រេចបានកន្លងមក របស់ ក.ជ.ក និងក៏បានគាំទ្រលទ្ធផលសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ដែលបានរាយការណ៍ដោយលោកជំទាវ **ញ៉ៀប សុនាព** អគ្គលេខាធិការ ក.ជ.ក.។ បន្ទាប់ពីបទបង្ហាញបច្ចុប្បន្នភាពរបស់ ក.ជ.ក និងបទបង្ហាញពីរបាយការណ៍ការសិក្សាបឋមលើយន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិរួចមក សមាជិកអង្គសិក្ខាសាលាទាំងមូលបានចូលរួមពិភាក្សាពេញអង្គ ដើម្បីផ្តល់ធាតុចូលលើរបាយការណ៍ និងទទួលបានលទ្ធផលដូចខាងក្រោម៖

- អង្គសិក្ខាសាលាបានឯកភាពគ្នាយកជម្រើសទី១ និងជម្រើសទី២ ក្នុងចំណោមជម្រើសទាំង៣ សម្រាប់យន្តការសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិ គឺពង្រឹងផ្នែកការការពារកុមារនិងពិនិត្យតាមដាន ឬបង្កើតក្រុមការងារកិច្ចការពារកុមារអន្តរកាលដើម្បីដើម្បីបំពេញភារកិច្ចដូចជា៖ ១.ធ្វើការកែសម្រួលសូចនាករសិទ្ធិកុមារទាំងអស់ឱ្យបានច្បាស់និងកំណត់ប្រភពផ្តល់ទិន្នន័យ ២.បង្កើតឧបករណ៍សម្រាប់ប្រមូលព័ត៌មាន និងទិន្នន័យការអនុវត្តសិទ្ធិកុមារ និងរៀបចំគំរូរបាយការណ៍ ៣.រៀបចំបង្កើតវិធីសាស្ត្រ និងប្រព័ន្ធប្រមូលព័ត៌មាន និងទិន្នន័យការអនុវត្តសិទ្ធិកុមារពីអ្នកពាក់ព័ន្ធ ៤.ប្រមូលព័ត៌មាន និងទិន្នន័យការអនុវត្តសិទ្ធិកុមារពីក្រសួង ស្ថាប័ន និងអ្នកពាក់ព័ន្ធនានា ៥.បញ្ចូលទិន្នន័យការអនុវត្តសិទ្ធិកុមារទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ៦.ធ្វើរបាយការណ៍ស្ថានភាពកុមារជូនរាជរដ្ឋាភិបាល និងធ្វើជូនគណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប និង៧. ពង្រឹងសមត្ថភាពមន្ត្រីផ្នែកការការពារកុមារនិងពិនិត្យតាមដាន និងលេខាធិការដ្ឋាន ក.ជ.ក រាជធានី ខេត្ត។ ចំណែកឯយន្តការដឹកនាំសម្របសម្រួលកិច្ចការពារកុមារថ្នាក់ជាតិនៅរក្សាដដែលគឺ ក.ជ.ក ប៉ុន្តែស្នើសុំឱ្យពិនិត្យតួនាទីភារកិច្ចរបស់ ក.ជ.ក តើមានគ្របដណ្តប់ជាពហុវិស័យលើកិច្ចការពារកុមារដែរឬទេ? នៅឆ្នាំ ២០១៥ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានបង្កើតគណៈកម្មការការពារកុមារថ្នាក់ជាតិ ដែលជាផ្នែកមួយនៃជម្រើសទី៣។
- អង្គសិក្ខាសាលា បានឯកភាពគ្នាសម្រេចយកតាមលទ្ធផលនៃតាមលទ្ធផលនៃសិក្ខាសាលាថ្នាក់ក្រោមជាតិ ដែលសម្រេចយកជម្រើសទី១ នៃជម្រើសទាំងពីរ។
- ស្នើសុំឱ្យមានការបង្កើនធនធានថវិការដ្ឋឱ្យស្រមតាមតួនាទីភារកិច្ចរបស់ ក.ជ.ក និងអង្គភាពពាក់ព័ន្ធដើម្បីមានលទ្ធភាពអនុវត្តផែនសកម្មភាព និងគួរកំណត់លេខគណនីមួយដាច់ដោយលែកច្បាស់លាស់មួយក្នុងច្បាប់ថវិកាជាតិ ប្រសើរជាងស្ថិតនៅក្រោមកញ្ចប់ថវិការបស់ក្រសួង ស្ថាប័នណាមួយ។

## ៦. សេចក្តីសន្និដ្ឋាន

យោងតាមការពិនិត្យវិភាគលើឯកសារគតិយុត្តដែលបង្កើតយន្តការសម្របសម្រួលកិច្ចការពារកុមារ និងការប្រមូលព័ត៌មាន និងទិន្នន័យការអនុវត្តសិទ្ធិកុមាពីអ្នកពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បង្ហាញថាក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គឺជាយន្តការសមស្របសម្រាប់អនុវត្តមុខងារនេះ ជាពិសេសលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ និងមាត្រា ៤៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជណាចក្រកម្ពុជា។ ចំណែកយន្តការផ្សេងៗទៀតដែលបង្កើតឡើងដើម្បីទប់ស្កាត់ និងដោះស្រាយបញ្ហាប្រឈមរបស់មុខសញ្ញាជាក់លាក់ ដែលជាផ្នែកមួយនៃការអនុវត្តសិទ្ធិកុមារ។ យន្តការដែលបានបង្កើតឡើងនៅថ្នាក់ជាតិ និងក្រោមជាតិ មានបញ្ជាក់ពីប្រភពធនធានផ្គត់ផ្គង់ច្បាស់លាស់នៅក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ និងប្រកាស ប៉ុន្តែស្ថានភាពជាក់ស្តែងយន្តការខ្លះបានទទួលថវិកាអាចធ្វើសកម្មភាពបាន និងខ្លះទៀតមិនទទួលបានឬទទួលបានតិចតួច អាស្រ័យលើឆន្ទៈរបស់ថ្នាក់ដឹកនាំស្ថាប័នទទួលបន្ទុកផ្ទាល់។ ជម្រើសដែលបានបញ្ជាក់ និងឯកភាពខាងលើគ្រាន់តែជាដំណោះស្រាយផ្នែកបច្ចេកទេស ប៉ុន្តែចំណុចសំខាន់គឺឆន្ទៈថ្នាក់ដឹកនាំស្ថាប័នទទួលបន្ទុកផ្ទាល់ និងសមត្ថភាពជំនាញ និងឆន្ទៈរបស់មន្ត្រីនៅក្នុងយន្តការទាំងនោះ។

------------------

**ឧបសម្ព័ន្ធ**

១. សង្ខេបសិទ្ធិមូលដ្ឋានរបស់កុមារ

២. គំរូសេចក្តីសម្រេចបង្កើត ក.ជ.ក រាជធានី ខេត្តនិងលេខាធិការដ្ឋាន

៣. គំរូរបាយការណ៍ស្តីពីការតាមដាន និងត្រួតពិនិត្យការអនុវត្តសិទ្ធិកុមារ

៤. សេចក្តីព្រាងសូចនាករសិទ្ធិកុមារ រៀបចំដោយ ក.ជ.ក

៥. បញ្ជីសូចនាករតាមក្រសួង ស្ថាប័ន ដែលត្រូវដាក់បញ្ចូលក្នុងប្រព័ន្ធCPMIS

៦. សូចនាករនៅក្នុងប្រព័ន្ធទិន្នន័យ ឃុំ សង្កាត់

## ឧបសម្ព័ន្ធទី១៖សង្ខេបសិទ្ធិមូលដ្ឋានរបស់កុមារ

### សិទ្ធិមូលដ្ឋានទាំង៤របស់កុមារ

នៅក្នុងអតីតកាលកុមារត្រូវបានគេចាត់ទុកគ្រាន់តែជាអ្នករងអំពើ ឬកម្មវត្ថុដែលគេប្រព្រឹត្តលើប៉ុណ្ណោះ។ ប៉ុន្តែក្រោយមកអនុសញ្ញាស្តីពីសិទ្ធិកុមារទទួលស្គាល់កុមារថា ជាមនុស្សដែលមានសិទ្ធិរបស់គេផ្ទាល់ គឺជាសិទ្ធិដែលគេទទួលបានអាស្រ័យដោយគេកើតជាមនុស្ស។ កុមារអាចទាមទារសិទ្ធិរបស់ខ្លួនពីអ្នកមានភារកិច្ចនានាដូចជាឪពុកម្តាយ និងរដ្ឋជាពិសេសមន្ត្រីមានសមត្ថកិច្ចដែលមានភារកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ ក៏ដូចសិទ្ធិមនុស្សមិនអាចបំបែកពីគ្នាបានទេគឺមានទំនាក់ទំនងគ្នា ហើយពុំមានសិទ្ធិណាមួយសំខាន់ជាងសិទ្ធិណាមួយឡើយ។ កុមារត្រូវបានចាត់ទុកជាបុគ្គលដែលកើតមកភ្ជាប់ជាមួយសិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូរស្មើៗគ្នាក្នុងនាមជាមនុស្ស។ មានប្រការខ្លះដែលគួរជៀសវាងដូចជាការប្រកាន់ភេទ ពណ៌សម្បុរ ភាសា ជំនឿសាសនា ដើមកំណើតជាតិ ឋានៈសង្គម ឬស្ថានភាពដទៃ។[44] យោងតាមគោលការណ៍១០យ៉ាងនៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិកុមារ និងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារមានបណ្តុំសិទ្ធិជាមូលដ្ឋានសំខាន់ៗចំនួន៤ដូចខាងក្រោម៖

**សិទ្ធិរស់រានមានជីវិត៖** កុមារត្រូវមានជីវិតរស់នៅ មានសុវត្ថិភាព និងមានអ្វីៗចាំបាច់សម្រាប់រស់នៅ ដូចជាចំណីអាហារមានជីវជាតិ មានឈ្មោះ និងមានសញ្ជាតិ ការបង្ការនិងព្យាបាលសុខភាព សំលៀកបំពាក់ ជម្រកស្នាក់នៅសមរម្យ និងមានជីវភាពគ្រប់គ្រាន់ ព្រមទាំងទទួលបានការថ្នាក់ថ្នមអំពីឪពុកម្តាយ អាណាព្យាបាលនិងសង្គម។ កុមារមិនត្រូវទទួលរងការវាយធ្វើបាបឬទារុណកម្មឡើយ។ ឪពុកម្តាយត្រូវយល់ផងដែរថា សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អាជ្ញាធរជាតិនិងសហគមន៍អន្តរជាតិ ក៏មានចំណែកទទួលខុសត្រូវចំពោះសិទ្ធិរស់រានរបស់កុមារផងដែរ មានន័យថាជីវិតកូនរបស់អ្នកស្ថិតនៅក្រោមកិច្ចការពាររបស់សហគមន៍មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន អាជ្ញាធរអន្តរជាតិ និងសហគមន៍អន្តរជាតិ។ ឪពុកម្តាយ ឬអាណាព្យាបាល អាចរងការប្តឹងពីសហគមន៍ អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធចំពោះអំពើដែលឪពុកម្តាយបានរំលោភលើសិទ្ធិរស់រានរបស់កុមារ។ ឪពុកម្តាយអាចប្តឹងតវ៉ាប្រឆាំងនឹងអាជ្ញាធរមានសមត្ថកិច្ចអំពីការមិនយកចិត្តទុកដាក់ ឬមិនផ្តល់កិច្ចការពារ ឬបានរំលោភលើសិទ្ធិរស់រានរបស់កុមារ។[45]

**រូបភាពទី១៖ សិទ្ធិរស់រានមានជីវិត**




1.1.ការទទួលបានចំណីអាហារ 1.2.ការមានជម្រកសមរម្យ 1.3.ការថែទាំសុខភាព 1.4.ការបានឈ្មោះ និងសញ្ជាតិ

**សិទ្ធិក្នុងការអភិវឌ្ឍ៖**កុមារត្រូវទទួលបាននូវការសិក្សារៀនសូត្រគ្រប់ប្រភេទ គឺការសិក្សានៅសាលារៀន និងនៅតាមផ្ទះ ឬសហគមន៍ដូចជាទទួលការអប់រំ និងផ្តល់ដំបូន្មានល្អៗស្តីពីការរស់នៅ ការលេងកំសាន្តនិងលំហែ ការសម្តែងសិល្បៈវប្បធម៌ ស្រឡាញ់ថ្នាក់ថ្នម ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការថែបំប៉នសុខភាព។[46]

---

[44]United Nation **"Declaration and Convention on the Rights of the child"** 1993 ; ទំព័រ ១០-១២

[45] មានចែងនៅមាត្រា ៦, ៧, ៨, ៩, ១៩, ២០, ២១, ២៣, ២៤, ២៦, ២៧, ៣០, ៣២, ៣៣, ៣៤, ៣៥, ៣៨ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

[46] មានចែងនៅមាត្រា ៥, ៦, ៧, ៩, ១០, ១១, ១២, ១៣, ១៤, ១៥, ១៧, ២៤, ២៨, ២៩, ៣១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

## រូបភាពទី២៖ សិទ្ធិក្នុងការអភិវឌ្ឍ



2.1.ការទទួលបានការអប់រំ



2.2.ការលេងកំសាន្ត និងលំហែ



2.3.ការសម្តែងសិល្បៈ វប្បធម៌



2.4.ការស្រឡាញ់ថ្នាក់ថ្នម

**សិទ្ធិទទួលបាននូវការការពារ៖** ឪពុកម្តាយត្រូវមើលថែរក្សានិងប្រៀនប្រដៅកុមារ ហើយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវចាត់វិធានការជួយកុមារឱ្យរួចផុតពីគ្រោះមហន្តរាយនានាដូចជា គ្រឿងញៀន ល្បែងអបាយមុខ អំពើអនាចារ ការរើសអើង ការសេពកាមគុណលើកុមារ ការធ្វើអាជីកម្មលើកុមារ ការលក់ដូរកុមារនិងអំពើដទៃៗទៀតដែលប៉ះពាល់ដល់ផលប្រយោជន៍ធំបំផុតរបស់កុមារ។ ឪពុកម្តាយត្រូវការពារកូនរបស់ខ្លួន និងចូលរួមចំណែកការពារកុមារឯទៀតៗពីការរំលោភទាំងឡាយដែលអាចកើតមានពីអាជ្ញាធរមូលដ្ឋានឬអាជ្ញាធរជាតិ។ គេអាចបង្កើតសមាគមមាតាបិតានៅក្នុងសហគមន៍មូលដ្ឋានក្នុងគោលបំណងការពារសិទ្ធិកុមារ។ អាជ្ញាធរមូលដ្ឋានក៏មានភារកិច្ចការពារកុមារពីការរំលោភនានាដែលអាចប្រព្រឹត្តដោយឪពុកម្តាយ ឬណាព្យាបាលរបស់កុមារ និងអ្នកមានអំណាចលើកុមារផ្សេងៗទៀតផងដែរ។[47]

## រូបភាពទី៣៖ សិទ្ធិទទួលបាននូវការការពារ



3.1.ការការពារពីការកេងប្រវ័ញ្ចផ្លូវភេទ



3.2.ការការពារអំពីការប្រើប្រាស់គ្រឿងញៀន



3.3.ការការពារអំពីការធ្វើពលកម្មធ្ងន់ធ្ងរ



3.4.ការការពារអំពីអំពើហិង្សាគ្រប់ប្រភេទ

**សិទ្ធិក្នុងការចូលរួម៖** កុមារមានសិទ្ធិចូលរួមបញ្ចេញមតិយោបល់លើបញ្ហា ឬសកម្មភាពដែលមានឥទ្ធិពលដល់ដំណើរជីវិតរបស់ពួកគេ ចូលរួមសកម្មភាពក្នុងសមាគម និងការប្រជុំនានា និងចូលរួមទទួល និងផ្សព្វផ្សាយព័ត៌មាន អានសៀវភៅ កាសែត ទស្សនាវដ្តី ស្តាប់វិទ្យុ មើលទូរទស្សន៍ ដើម្បីពង្រីកការយល់ដឹង និងចេះប្រើវិចារណញ្ញាណរិះគិតចំពោះព្រឹត្តិការណ៍ផ្សេងៗ។[48]

## រូបភាពទី៤៖ សិទ្ធិក្នុងការចូលរួម



4.1.ការបញ្ចេញមតិយោបល់



4.2.ការបង្កើតក្លឹបកុមារ និងសមាគម



4.3.ការចូលរួមផ្សព្វផ្សាយ និងទទួលព័ត៌មាន



4.4.ការយល់ដឹងពី អ.ស.ក

---

[47] មានចែងនៅមាត្រា ២, ៧, ១១, ១៦, ១៩, ២០, ២២, ២៣, ២៥, ៣០, ៣២, ៣៣, ៣៤ ៣៥, ៣៦, ៣៦, ៣៨, ៣៩, ៤០ នៃអនុសញ្ញា CRC

[48] មានចែងនៅមាត្រា ១២, ១៣, ១៥, ១៧, ៤២ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

ឧបសម្ព័ន្ធទី២៖ គំរូសេចក្តីសម្រេចបង្កើត ក.ជ.ក និងលេខាធិការដ្ឋាន

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្ត..........

## អភិបាលខេត្ត............

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៩/១២០១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/..............................ចុះថ្ងៃទ.......................... ស្តីពីការត្រាស់បង្គាប់តែងតាំងជាអភិបាល នៃអភិបាលខេត្ត...............
- បានឃើញអនុក្រឹត្យលេខ ៩១៣ អនក្រ.តត ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការតែងមុខតំណែងមន្ត្រីរាជការ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលស្រុក និងក្រុមប្រឹក្សាគណៈអភិបាលក្រុង
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- បានឃើញសេចក្តីសម្រេចលេខ ២១៦ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រាជធានី ខេត្ត
- បានឃើញតម្រូវការចាំបាច់របស់ខេត្ត។

## សម្រេច

**ប្រការ ១.**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្ត សរសេរអក្សរកាត់ ក.ជ.ក ខេត្ត ដើម្បីជាយន្តការសម្របសម្រួល និងផ្តល់យោបល់ជូនក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក.) លើការងារទាក់ទងនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព និងការចូលរួមចំណែករបស់កុមារក្នុងខេត្ត។ ក.ជ.ក ខេត្តមានសមាសភាពដូចតទៅ៖

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម | អភិបាលខេត្ត | ប្រធានកិត្តិយស |
| ២. | ឯកឧត្តម | អភិបាលរង | ប្រធាន |

| | | |
|---|---|---|
| ៣. លោក | ប្រធានមន្ទីរ ស.អ.យ. | អនុប្រធានទី១ |
| ៤. លោក | ប្រធានមន្ទីរកិច្ចការនារី | អនុប្រធាន |
| ៥. លោក | ប្រធានមន្ទីរអប់រំ យុវជន និងកីឡា | អនុប្រធាន |
| ៦. លោក | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៧. លោក | ប្រធានមន្ទីរសុខាភិបាល | អនុប្រធាន |
| ៨. លោក | ស្នងការនគរបាលខេត្ត | អនុប្រធាន |
| ៩. លោក | អនុប្រធានមន្ទីរ ស.អ.យ | សមាជិកអចិន្ត្រៃយ៍ |
| ១០.លោក | មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង រាជធានី ខេត្ត | សមាជិក |
| ១១.លោក | ចៅក្រម ឬព្រះរាជអាជ្ញា | សមាជិក |
| ១២.លោក | មេបញ្ជាការកងរាជអាវុធហត្ថ រាជធានី ខេត្ត | សមាជិក |
| ១៣.លោក | នាយករដ្ឋបាលសាលា រាជធានី ខេត្ត | សមាជិក |
| ១៤.លោក | អនុប្រធានមន្ទីរ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៥.លោក | អនុប្រធានមន្ទីរ ពាណិជ្ជកម្ម | សមាជិក |
| ១៦.លោក | អនុប្រធានមន្ទីរ ផែនការ | សមាជិក |
| ១៧.លោក | អនុប្រធានមន្ទីរ អភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៨.លោក | អនុប្រធានមន្ទីរ វប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ១៩.លោក | អនុប្រធានមន្ទីរ សាធារណការ និងដឹកជញ្ជូន | សមាជិក |
| ២០.លោក | អនុប្រធានមន្ទីរ បរិស្ថាន | សមាជិក |
| ២១.លោក | អនុប្រធានមន្ទីរ ប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ២២.លោក | អនុប្រធានមន្ទីរ ឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ២៣.លោក | អនុប្រធានមន្ទីរ រ៉ែ និងថាមពល | សមាជិក |
| ២៤.លោក | អនុប្រធានមន្ទីរ ទេសចរណ៍ | សមាជិក |
| ២៥.លោក | អនុប្រធានមន្ទីរ ព័ត៌មាន | សមាជិក |
| ២៦.លោក | អនុប្រធានមន្ទីរ ធម្មការ និងសាសនា | សមាជិក |
| ២៧.លោក | អនុប្រធានមន្ទីរ កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ២៨.លោក | តំណាងសាខាកាកបាទក្រហម រាជធានី ខេត្ត | សមាជិក |

**ប្រការ ២.**

ក.ជ.ក ខេត្ត មានតួនាទី និងភារកិច្ចដូចតទៅៈ

- ពិគ្រោះយោបល់ សម្របសម្រួលសកម្មភាពទាំងឡាយដែលពាក់ព័ន្ធទៅនឹងបញ្ហារបស់កុមារនៅក្នុងខេត្ត
- ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ កម្មវិធីជាតិសម្រាប់កុមារនៅក្នុងខេត្ត និងលើកសំណើរជូន ក.ជ.ក និងបញ្ហាទាំងឡាយដែលជានាឧត្តមប្រយោជន៍របស់កុមារនៅក្នុងខេត្ត
- ធ្វើការផ្សព្វផ្សាយអនុសញ្ញាស្តីពីសិទ្ធិកុមារ ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល និង ក.ជ.ក ពាក់ព័ន្ធនឹងបញ្ហានានារបស់កុមារ និងបំផុសចលនាគាំទ្រការអនុវត្តសិទ្ធិកុមារឱ្យមានប្រសិទ្ធភាព

- រៀបចំផែនការកម្មវិធី និងសកម្មភាពផ្សេងៗ ដើម្បីឧត្តមប្រយោជន៍កុមារ ជាអាទិ៍ការគោរពសិទ្ធិ និងការអនុវត្តសិទ្ធិកុមារ ការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកម្ពស់សុខុមាលភាព ការចូលរួមចំណែករបស់កុមារ ការប្រឆាំងនឹងអំពើហិង្សា ការទប់ស្កាត់ ការលុបបំបាត់ការកេងប្រវ័ញ្ចគ្រប់រូបភាពមកលើកុមារ និងប្រឆាំងនឹងការជួញដូរគ្រឿងញៀន
- ទំនាក់ទំនងជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ដែលមានគម្រោងការងារពាក់ព័ន្ធនឹងកុមារនៅក្នុងខេត្តដើម្បីរកជំនួយឧបត្ថម្ភ និងផ្លាស់ប្តូរព័ត៌មាន បទពិសោធន៍ ទស្សនៈរីកចម្រើនដែលទាក់ទងនឹងគោលដៅរួមក្នុងការកែលម្អស្ថានភាពកុមារ
- រៀបចំមូលដ្ឋានទិន្នន័យពីស្ថានភាពកុមារនៅក្នុងខេត្ត
- រៀបចំទិវាកុមារអន្តរជាតិ១ មិថុនា និងទិវាពិភពលោកប្រឆាំងពលកម្មកុមារ១២ មិថុនា
- ចាត់ចែងអនុវត្តរាល់គោលការណ៍ ផែនការសកម្មភាពរបស់ ក.ជ.ក
- អនុវត្តភារកិច្ចផ្សេងៗទៀតដែល ក.ជ.ក ប្រគល់ជូន។

**ប្រការ ៣.-**

**ក.ជ.ក ខេត្ត** ត្រូវជួបប្រជុំយ៉ាងតិច២(ពីរ)ដងក្នុង១ឆ្នាំ។ ក្នុងករណីចាំបាច់ក.ជ.ក ខេត្ត អាចប្រជុំវិសាមញ្ញ តាមការអញ្ជើញរបស់ប្រធាន។

**ក.ជ.ក ខេត្ត** ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការអនុវត្តសកម្មភាពការងាររៀងរាល់ខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំក្នុងខេត្ត ព្រមទាំងលើកសំណូមពរចាំបាច់មក ក.ជ.ក។

**ប្រការ ៤.-**

**ក.ជ.ក ខេត្ត** មានសិទ្ធិទាក់ទង និងអញ្ជើញមន្ទីរ អង្គភាពពាក់ព័ន្ធនានា តំណាងកុមារ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស ដៃគូអភិវឌ្ឍ ដែលមានគម្រោងការងារក្នុងខេត្ត និងពុំមានចែងក្នុងប្រការ១ និងប្រការ៦ នៃសេចក្តីសម្រេចនេះ។

**ប្រការ ៥.-**

**ក.ជ.ក ខេត្ត** មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក តាមគំរូណែនាំរបស់ ក.ជ.ក។

**ប្រការ ៦.-**

ត្រូវបានបង្កើតលេខាធិការដ្ឋាន ក.ជ.ក ខេត្ត ស្ថិតនៅក្នុងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ដែលមានសមាសភាពដូចតទៅ៖

| | | |
|---|---|---|
| ១. លោក | អនុប្រធានមន្ទីរ ស.អ.យ | ប្រធាន |
| ២. លោក | ប្រធានការិយាល័យសុខុមាលភាពកុមារ | អនុប្រធាន |
| ៣. លោក | មន្ត្រីការិយាល័យសុខុមាលភាពកុមារ | សមាជិកអចិន្ត្រៃយ៍ |
| ៤. លោក | មន្ត្រីមន្ទីរ កិច្ចការនារី | សមាជិក |
| ៥. លោក | មន្ត្រីមន្ទីរ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៦. លោក | មន្ត្រីមន្ទីរ អប់រំ យុវជន និងកីឡា | សមាជិក |
| ៧. លោក | មន្ត្រីមន្ទីរ សុខាភិបាល | សមាជិក |
| ៨. លោក | មន្ត្រីនគរបាល | សមាជិក |
| ៩. លោក | តំណាងអង្គការ | សមាជិក |

លេខាធិការដ្ឋាន ក.ជ.ក មានតួនាទី និងភារកិច្ចដូចតទៅ៖

- រៀបចំផែនការសកម្មភាព និងផែនការថវិកាប្រចាំឆ្នាំដាក់បញ្ចូលទៅក្នុងកញ្ចប់ថវិការបស់មន្ទីរស.អ.យ
- រៀបចំកិច្ចប្រជុំសាមញ្ញ ក.ជ.ក ខេត្ត ២ដងក្នុង១ឆ្នាំ និងកិច្ចប្រជុំវិសាមញ្ញតាមការចាំបាច់
- សហការ និងសម្របសម្រួលជាមួយមន្ទីរកិច្ចការនារី "ក្រុមការងារ គ.ក.ស.ក" មន្ទីរ និងអង្គភាពពាក់ព័ន្ធ ដើម្បីប្រមូលព័ត៌មាន និងទិន្នន័យការអនុវត្តសិទ្ធិកុមារ
- ពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារនៅក្នុងខេត្ត និងរាយការណ៍ជូនប្រធាន ក.ជ.ក ដើម្បីអន្តរាគមន៍
- ចូលរួមប្រជុំជាមួយ គ.ក.ស.ក ប្រចាំខែដើម្បីប្រមូលទិន្នន័យ និងឆ្លើយតបចំពោះការអនុវត្តសិទ្ធិកុមារ
- រៀបចំកិច្ចប្រជុំប្រចាំត្រីមាសជាមួយអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើសកម្មភាពអនុវត្តសិទ្ធិកុមារ
- ធ្វើរបាយការណ៍ស្តីពីការអនុវត្តសិទ្ធិកុមារ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនប្រធាន ក.ជ.ក និងចម្លងជូនអគ្គលេខាធិការដ្ឋាន ក.ជ.ក។
- អនុវត្តភារកិច្ចផ្សេងទៀតដែលប្រធាន ក.ជ.ក. ប្រគល់ជូន។

**ប្រការ ៧.-**

**ក.ជ.ក ខេត្ត** មានប្រភពធនធាន ផ្គត់ផ្គង់ដោយថវិកាជាតិ ដាកញ្ចប់ដោយឡែកនៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

**ក.ជ.ក ខេត្ត** មានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិមនុស្សធម៌ដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗសម្រាប់បំពេញការងាររបស់ខ្លួន។

**ប្រការ ៨.-**

លោកនាយករដ្ឋបាលសាលាខេត្ត លោក លោកស្រីប្រធានមន្ទីរ អង្គភាពជុំវិញខេត្ត លោក លោកស្រីអភិបាល ក្រុង គ្រប់ស្រុក ឯកឧត្តម អស់លោក លោកស្រីដូចមានចែងក្នុងប្រការ ១ និងប្រការ ៦ ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**អភិបាលខេត្ត**

**ប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្ត**

**ចម្លងជូន៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- ដូចប្រការ ១, ៦ និង៨ ដើម្បីអនុវត្ត
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី៣៖គំរូរបាយការណ៍ស្តីពីការតាមដាន និងត្រួតពិនិត្យការអនុវត្តសិទ្ធិកុមារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

Final draft

# របាយការណ៍

## ស្តីពីការតាមដាន និងត្រួតពិនិត្យការអនុវត្តសិទ្ធិកុមារ

## នៅខេត្ត...............

## ប្រចាំត្រីមាសទី១ ឆ្នាំ២០២០

**រៀបចំរបាយការណ៍ដោយលេខាធិការដ្ឋាន**

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្ត.....................**

ថ្ងៃទី ខែ ឆ្នាំ២០២០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្ត**
លេខ:................ក.ជ.ក.ខ/របក

**សូមគោរពជូន**
**លោកជំទាវ អគ្គលេខាធិការ**
**អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**កម្មវត្ថុ** : របាយការណ៍ស្តីពីការត្រួតពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារប្រចាំត្រីមាសទី១ ឆ្នាំ២០២០។

**យោង** : ផែនការយុទ្ធសាស្ត្រកិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារឆ្នាំ២០១៩-២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន**លោកជំទាវអគ្គលេខាធិការ** មេត្តាជ្រាបថា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្ត................ បានចូលរួមប្រជុំប្រចាំខែជាមួយគណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារខេត្ត(គ.ក.ស.ក) និងបានសហការជាមួយក្រុមការងារ គ.ក.ស.ក មន្ទីរ អង្គភាព និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីប្រមូលព័ត៌មាន និងទិន្នន័យស្តីពីការអនុវត្តសិទ្ធិកុមារ។

ផ្អែកលើលទ្ធផលដែលអនុវត្តដោយមន្ទីរ អង្គភាព និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធផ្តល់ឱ្យបង្ហាញថា ការអនុវត្តសិទ្ធិមូលដ្ឋានកុមារមានៈ សិទ្ធរស់រានមានជីវិត សិទ្ធិទទួលបាននូវការការពារ សិទ្ធិក្នុងការអភិវឌ្ឍ និងសិទ្ធិក្នុងការចូលរួម មានវឌ្ឍនភាពដូចបានរៀបរាប់ក្នុងរបាយការណ៍។

អាស្រ័យហេតុនេះសូម**លោកជំទាវអគ្គលេខាធិការ** មេត្តាជ្រាបជាសេចក្តីរាយការណ៍។

សូម **លោកជំទាវអគ្គលេខាធិការ** ទទួលនូវការគោរពរាប់អានអំពីខ្ញុំ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២០៥៦៣
ធ្វើនៅខេត្ត................ថ្ងៃទី.........ខែ..............ឆ្នាំ២០២០
**ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**
**ខេត្ត**............................

**ចម្លងជូន**:
- ឯកឧត្តប្រធានកត្តិយស ក.ជ.ក ខេត្ត
- លោកជំទាវប្រធាន គ.ក.ស.ក ខេត្ត

## ១. សេចក្តីផ្តើម

ដើម្បីឆ្លើយតបនឹងបេសកកម្មដែលរាជរដ្ឋាភិបាលប្រគល់ជូន ក្នុងនាមជាយន្តការសម្របសម្រួលលើការងារអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ ២០១៩-២០២៣[49] ដើម្បីពង្រឹងការសម្របសម្រួល និងពិនិត្យតាមដានការអនុវត្តសិទ្ធិជាមូលដ្ឋានរបស់កុមាររួមមានៈ សិទ្ធិរស់រានមានជីវិត សិទ្ធិអភិវឌ្ឍន៍ សិទ្ធិទទួលបាននូវការការពារ និងសិទ្ធិចូលរួម ដោយផ្តោតលើគោលដៅជាយុទ្ធសាស្ត្រចំនួន៥ គឺៈ១.ពង្រឹងកិច្ចការពារនិងពិនិត្យតាមដានការអនុវត្តសិទ្ធិកុមារ ២.បង្កើនការអប់រំផ្សព្វផ្សាយនិងអភិវឌ្ឍន៍ធនធានមនុស្ស ៣.ពង្រឹងសមត្ថភាពស្ថាប័ននិងអភិវឌ្ឍន៍ភាពជាដៃគូ ៤.ពង្រឹងពង្រីកក្រុមការងារដើម្បីកុមារក្រសួងស្ថាប័ន និង៥.បង្កើនការអប់រំផ្សព្វផ្សាយកិច្ចការពារនិងលើកកម្ពស់សិទ្ធិកុមារ រាជធានី ខេត្ត។

អភិបាលនៃគណៈអភិបាលខេត្ត........................បានចេញសេចក្តីសម្រេចលេខ..........ចុះថ្ងៃទី......ខែ...... ឆ្នាំ២០.... ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្ត............។[50] ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារខេត្តដែលមានលេខាធិការដ្ឋានជាសេនាធិការ បានសហការនិងសម្របសម្រួលជាមួយក្រុមការងារ គ.ក.ស.ក មន្ទីរ អង្គភាពពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីប្រមូលព័ត៌មាននិងទិន្នន័យការអនុវត្តសិទ្ធិកុមាររួមមាន សិទ្ធរស់រានមានជីវិត សិទ្ធិទទួលបាននូវការការពារ សិទ្ធិក្នុងការអភិវឌ្ឍ និងសិទ្ធិក្នុងការចូលរួម និងពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តសិទ្ធិទាំងនោះ ដើម្បីធានាបានឧត្តមប្រយោជន៍របស់កុមារ។ ក.ជ.ក ខេត្តនឹងចូលរួមអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ២០១៩-២០២៣ និងធ្វើរបាយការណ៍ពីវឌ្ឍនភាពតាមកាលកំណត់របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។

### ១.១. ស្ថានភាពភូមិសាស្ត្រ

ខេត្ត..........ទីតាំងស្ថិតនៅទិស............................ពីរាជធានីភ្នំពេញ និងមានចំងាយផ្លូវ..................គ.ម ពីរាជធានីភ្នំពេញនិងមានព្រំប្រទល់ខាងជើងជាប់ជាមួយខេត្ត.................ខាងត្បូងជាមួយខេត្ត.............ខាងកើតជាប់ជាមួយខេត្ត............និងខាងលិចជាប់ជាមួយខេត្ត............។

**តារាងទី១. បញ្ជីឈ្មោះក្រុង ស្រុក ខណ្ឌ និងចំនួនឃុំ សង្កាត់ ភូមិ**

| ល.រ | ឈ្មោះក្រុង ស្រុក ខណ្ឌ | ចំនួនឃុំ សង្កាត់ និងភូមិ | | | | ផ្ទៃដីសរុប គ.ម² |
|---|---|---|---|---|---|---|
| | | ឃុំ | ភូមិ | សង្កាត់ | ភូមិ | |
| 1 | | | | | | |
| 2 | | | | | | |
| 3 | | | | | | |
| | | | | | | |
| | សរុប | | | | | |

ប្រភពទិន្នន័យៈ មន្ទីរផែនការឆ្នាំ.......

[49] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កិច្ចការពារ និងលើកកម្ពស់សិទ្ធិកុមារ ២០១៩ ២០២៣ អនុម័តនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩

[50] សេចក្តីសម្រេចលេខ ២១៦ ក.ជ.ក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី ខេត្ត

## ១.២. ទិន្នន័យប្រជាសាស្ត្រ

តារាងទី២. ចំនួនប្រជាជន និងកុមាររស់នៅតាម ក្រុង ស្រុក ខណ្ឌ

| ល.រ | ឈ្មោះក្រុង ស្រុក ខណ្ឌ | ចំនួនប្រជាជនទូទៅ | | | ចំនួនកុមារ | | |
|---|---|---|---|---|---|---|---|
| | | ប្រុស | ស្រី | សរុប | កុមារា | កុមារី | សរុប |
| 1 | | | | | | | |
| 2 | | | | | | | |
| 3 | | | | | | | |
| 4 | | | | | | | |
| សរុប | | | | | | | |

ប្រភពទិន្នន័យ៖ មន្ទីរផែនការឆ្នាំ.......

## ២. ស្ថានភាពការអនុវត្តសិទ្ធិកុមារនៅក្នុងខេត្ត

### ២.១ សិទ្ធិរស់រានមានជីវិត

### ២.២ សិទ្ធិទទួលបាននូវការការពារ

### ២.៣ សិទ្ធិក្នុងការអភិវឌ្ឍ

### ២.៤ សិទ្ធិក្នុងការចូលរួម

## ៣. លទ្ធផលការអនុវត្តសិទ្ធិមូលដ្ឋានរបស់កុមារ

### ៣.១ សិទ្ធិរស់រានមានជីវិត

- ការទទួលបានចំណីអាហារ
- ការមានជម្រកសមរម្យ
- ការថែទាំសុខភាព
- ការទទួលបានឈ្មោះ និងសញ្ជាតិ

តារាងទី៣. សូចនាករការអនុវត្តសិទ្ធិរស់រានមានជីវិត

| ល.រ | សូចនាករ | ឯកតា | មករា | កុម្ភៈ | មីនា | សរុប |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

### ៣.២ សិទ្ធិទទួលបាននូវការការពារ

- ការការពារពីការកេងប្រវ័ញ្ចផ្លូវ
- ការការពារពីការប្រើប្រាស់គ្រឿងញៀន
- ការការពារពីការធ្វើពលកម្មធ្ងន់ធ្ងរ
- ការការពារពីអំពើហិង្សាគ្រប់ប្រភេទ

តារាងទី៤. សូចនាករការអនុវត្តសិទ្ធិទទួលបាននូវការការពារ

| ល.រ | សូចនាករ | ឯកតា | មករា | កុម្ភៈ | មីនា | សរុប |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

## ៣.៣ សិទ្ធិអភិវឌ្ឍ

- សិទ្ធិទទួលបានការអប់រំ
- ការលេងកំសាន្ត និងលំហែ
- ការសម្តែងសិល្បៈ វប្បធម៌
- ការស្រឡាញ់ថ្នាក់ថ្នម

តារាងទី៥.សូចនាករការអនុវត្តសិទ្ធិក្នុងការអភិវឌ្ឍ

| ល.រ | សូចនាករ | ឯកតា | មករា | កុម្ភៈ | មីនា | សរុប |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

## ៣.៤ សិទ្ធិក្នុងការចូលរួម

- ការបញ្ចេញមតិយោបល់
- ការបង្កើតក្លឹបកុមារ ឬសមាគម
- ការចូលរួមផ្សព្វផ្សាយ និងទទួលព័ត៌មាន
- ការយល់ដឹងពី អ.ស.ក

តារាងទី៦. សូចនាករការអនុវត្តសិទ្ធិក្នុងការចូលរួម

| ល.រ | សូចនាករ | ឯកតា | មករា | កុម្ភៈ | មីនា | សរុប |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

**៤. បញ្ហាប្រឈម និងដំណោះស្រាយ**

**៥ ផែនការសម្រាប់ត្រីមាសទី**........

ថ្ងៃ ខែ ឆ្នាំ ព.ស.២០៥៦៣

ធ្វើនៅខេត្ត................ថ្ងៃទី.........ខែ..............ឆ្នាំ២០២០

**អ្នកធ្វើរបាយការណ៍**

ប្រធានលេខាធិការដ្ឋាន ក.ជ.ក

ឈ្មោះ.......

## ឧបសម្ព័ន្ធទី៤៖ សេចក្តីព្រាងសូចនាករសិទ្ធិកុមាររៀបចំដោយ ក.ជ.ក

| | សេចក្តីព្រាងសូចនាករសិទ្ធិកុមារ<br>DRAFT CHILD RIGHTS INDICATORS | Available sources | Expected sources |
|---|---|---|---|
| | **1 ផ្នែកអប់រំ EDUCATION** | | |
| | *1.1 ការទទួលបានការអប់រំ Access to Education* | | |
| 1 | ចំនួនសាលាមត្តេយ្យសិក្សា<br>Number of Pre-Primary School | EMIS | |
| 2 | ចំនួនសាលាបឋមសិក្សា<br>Number of Primary School | EMIS | |
| 3 | ចំនួនអនុវិទ្យាល័យ<br>Number of College | EMIS | |
| 4 | ចំនួនវិទ្យាល័យ<br>Number of Lycee | EMIS | |
| 5 | សិស្ស និស្សិតពិការទទួលបានការអប់រំពិសេស<br>Students with disabilities receiving special education | | MoSVY |
| 6 | សិស្ស និស្សិតពិការទទួលបានសេវាពិសេស<br>Students with disabilities receive special services | | MoSVY |
| 7 | កុមារពិការទូទាំងប្រទេសទទួលបានសិទ្ធិមូលដ្ឋានទាំងបួនរបស់កុមារ<br>Children with disabilities across the country get the four basic rights of children | | MoSVY |
| | *1.2 ការអប់រំជាមូលដ្ឋាន Basic Education* | | |
| 8 | ភាគរយកុមារអាយុ ៥ ឆ្នាំក្នុងកម្មវិធីអប់រំកុមារតូច<br>Percentage of children age 5 in ECE program | EMIS | |
| 9 | អត្រាពិតនៃការសិក្សានៅបឋមសិក្សា<br>Net Enrolment Rate in Primary Education | EMIS | |
| 10 | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ<br>Gross Enrolment Rate in Lower Secondary Education | EMIS | |
| 11 | សមាមាត្រកុមារអាយុ៦ទៅ១៤ឆ្នាំដែលនៅក្រៅសាលាបែងចែកតាមភេទ<br>Proportion of children aged 6-14 years old out of school by gender | CSEC | |
| 12 | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ<br>Gross Enrolment Rate in Upper Secondary Education | EMIS | |
| 13 | អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា<br>Completion Rate in Primary Education | EMIS | |
| 14 | អត្រាបញ្ចប់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ<br>Completion Rate in Lower Secondary Education | EMIS | |

| | | | |
|---|---|---|---|
| 15 | ចំនួនកុមារពិការនៅបឋមសិក្សា<br>Number of disabled children in Primary Education | EMIS | |
| 16 | ចំនួនសិស្សជាជនជាតិភាគតិចនៅបឋមសិក្សា<br>Number of ethnic minority children in Primary Education | EMIS | |
| 17 | ភាគរយសាលាបឋមសិក្សាអនុវត្តគោលនយោបាយសាលាកុមារមេត្រី<br>Percentage of CFS primary school | EMIS | |
| 18 | ភាគរយសាលារៀនដែលបង្កើតក្រុមប្រឹក្សាកុមារ/យុវជន<br>Percentage of school with children/youth council | EMIS | |
| | *1.3 ការបង្កើនសមត្ថភាព Capacity Building* | | |
| 19 | ភាគរយគ្រូដែលទទួលការបណ្តុះបណ្តាលគរុកោសល្យ<br>Percentage of teachers with pedagogical training | EMIS | |
| | *1.4 សមភាពយេនឌ័រ Gender Parity* | | |
| 20 | ភាគរយគ្រូបង្រៀនជាស្ត្រី<br>Percentage of female teachers | EMIS | |
| 21 | ចំនួនសិស្សស្រីដែលទទួលផលពីកម្មវិធីជំរុញការចូលរៀនរបស់កុមារី<br>Number of female student benefited from Girl Enrolment Programs | EMIS | |
| 22 | សន្ទស្សន៍យុគភាពយេនឌ័រនៃអត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ<br>GPI of GER at Lower Secondary Education | EMIS | |
| 23 | សន្ទស្សន៍យុគភាពយេនឌ័រនៃអត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ<br>GPI of GER at Upper Secondary Education | EMIS | |
| | **2. ផ្នែកអភិបាលកិច្ច** GOVERNANCE | | |
| | *2.1 ការបង្កើនសមត្ថភាព Capacity Building* | | |
| 24 | ច្បាប់ និងគោលនយោបាយប្រឆាំងការរើសអើងចំពោះកុមារ<br>Policies and Laws to combat discrimination against children | | |
| 25 | ចំនួនវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិកុមារដល់ក្រសួងស្ថាប័នដែលធ្វើការងារពាក់ព័ន្ធនឹងសិទ្ធិកុមារ<br>Number of trainings on child rights to relevant ministries/institutions that working with child rights | | |
| | *2.2 ប្រព័ន្ធទិន្នន័យ Data Systems* | | |
| 26 | ចំនួនប្រព័ន្ធទិន្នន័យដែលមានបញ្ចូលសូចនាករកុមារ<br>Number of data collection systems that have child rights indicators | | |
| | *2.3 ការរកចំណូល និងការចំណាយសាធារណៈ Income and public expenditures* | | |
| 27 | ភាគរយនៃចំណាយចរន្តសរុបនៃថវិកាជាតិដែលបានវិភាជជូនក្រសួងស្ថាប័នដែល | Budget law | |

| | | | |
|---|---|---|---|
| | ធ្វើការងារពាក់ព័ន្ធនឹងកុមារ<br>Percentage of the total recurrent budget within the national budget allocated by the government to the ministries/ institutions working on children | and Budget Execution law | |
| 28 | ភាគរយនៃចំណាយចរន្តសរុបរបស់ក្រសួងស្ថាប័នដែលបានវិភាជលើកម្មវិធីសម្រាប់កុមារ<br>Percentage of the total recurrent budget within the total budget of the relevant ministries/institutions allocated for children-related programs | LM Budget ( BSP and Budget) | |
| | *2.4 ច្បាប់ Legal* | | |
| 29 | ចំនួនកុមារនៅក្នុងពន្ធនាគារតាមភេទ និងអាយុ<br>Number of children in prisons by sex and age | MoI | |
| | *2.5 ការចូលរួម Participation* | | |
| 30 | ចំនួនឃុំ សង្កាត់ដែលកុមារបានចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងវិនិយោគឃុំ សង្កាត់<br>Number of commune/sangkat which children participated in the process of commune/sangkat development planning and investment | MoI | |
| 31 | ចំនួនកុមារដែលបានចូលរួមលើកជាបញ្ហា និងការព្រួយបារម្ភរបស់ពួកគេនៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ និងវិនិយោគនៅថ្នាក់ឃុំ/សង្កាត់ដោយបែងចែកតាមភេទ<br>Number of children that raised their issues and concerns in the process of commune/sangkat development planning and investment by sex | MoI | |
| | *2.5 ការកាត់ទោស Prosecution* | | |
| 32 | ចំនួនជនល្មើសដែលបានចាប់ខ្លួន និងកាត់ទោសពីបទប្រព្រឹត្តរាល់ទម្រង់ហិង្សាលើកុមារ<br>Number of perpetrators arrested and convicted for violence against children | | MoJ |
| 33 | ចំនួនជនល្មើសដែលបានចាប់ខ្លួន និងកាត់ទោសពីបទជួញដូរ រំលោភ និង/ឬកេងប្រវ័ញ្ចផ្លូវភេទលើកុមារ<br>Number of perpetrators arrested and convicted for trafficking, rape and/or sexual exploitation of children | | MoJ |
| | *2.6 ការចុះបញ្ជី Registration* | | |
| 34 | ចំនួនកុមារចុះបញ្ជីកំណើតទាន់ពេលវេលាក្នុងរយៈពេល៣០ថ្ងៃក្រោយកំណើត<br>Number of registered children during 30 days after delivery | MoI | |
| 35 | ចំនួនកុមារអាយុក្រោម១៨ឆ្នាំដែលបានចុះបញ្ជីបញ្ជាក់កំណើត | MOI | |

| | | | |
|---|---|---|---|
| | Number of Children under 18 years of age with certified birth | | |
| | *2.7 ភាពរងគ្រោះ Victimization* | | |
| 36 | អត្រាសមាមាត្រនៃគ្រួសារដែលមានអំពើហិង្សាក្នុងគ្រួសារ<br>Proportion of households using domestic violence | CSEC | |
| 37 | ចំនួនកុមារដែលត្រូវបានគេរំលោភផ្លូវភេទដោយបែងចែកតាមភេទ អាយុ និងភូមិសាស្ត្រ<br>Number of children who were  raped by sex age and Geography | CSEC | |
| 38 | ចំនួនកុមារដែលរងគ្រោះដោយការជួញដូរ ដោយបែងចែកតាមភេទ អាយុ និងភូមិសាស្ត្រ<br>Number of trafficked children in the country and outside of the country by sex, age and Geography | MoI | |
| | **3. សុខភាព និងអាហារូបត្ថម្ភ HEALTH AND NUTRITION** | | |
| | *3.1 ការទទួលបានសេវាសុខាភិបាល Access to health services* | | |
| 39 | ចំនួនមន្ទីរពេទ្យកុមារមេត្រី និងមណ្ឌលសុខភាពកុមារមេត្រីនៅសហគមន៍<br>Number of baby friendly hospitals and baby friendly communities | MoH | |
| | *3.2 ការរស់រានរបស់ម្តាយនិងកុមារ Child  and Maternal Survival* | | |
| 40 | អត្រាមរណៈរបស់ទារក<br>Infant Mortality Rate | CDHS | |
| 41 | អត្រាមរណៈរបស់កុមារអាយុក្រោម៥ឆ្នាំ<br>Under five mortality rate | CDHS | |
| 42 | អត្រាមរណៈរបស់មាតា<br>Maternal Mortality Ratio | CDHS | |
| 43 | ចំនួនកុមារដែលមានអាយុ៥-៥៩ខែ បានទទួលវីតាមីនអេ បែងចែកតាមអាយុ<br>Number of children by 6 -59 months that received Vitamin A supplements | CDHS | |
| 44 | ចំនួនភាគរយនៃកុមារដែលអាយុក្រោម១ឆ្នាំបានទទួលការចាក់ថ្នាំបង្ការពេញលេញ<br>Percentage of children under 1 received full immunization | CDHS | |
| 45 | ភាគរយនៃការប្រើប្រាស់អំបិលអ៊ីយ៉ូតនៅក្នុងគ្រួសារ<br>Percentage of households that use iodized salt | CDHS | |
| 46 | ភាគរយនៃកុមារអាយុក្រោម៥ឆ្នាំមិនគ្រប់ទម្ងន់ ខ្វះអាហារូបត្ថម្ភ<br>Percentage of underweight children under 5 years classified as malnourished | CDHS | |
| | *3.3 ជំងឺ Communicable Diseases* | | |
| 47 | អត្រាប្រេវ៉ាឡង់កុមារដែលមានជំងឺរលាកផ្លូវដង្ហើម ជំងឺគ្រុនចាញ់ គ្រុនឈាម និងជំងឺរបេង | MoH | |

| | | | |
|---|---|---|---|
| | Prevalence of respiratory infection, malaria, dengue and TB in children | | |
| 48 | អត្រាប្រេវ៉ាឡង់នៃកុមារដែលមានជំងឺរាគ<br>Prevalence of diarrhea in children | CDHS | |
| | *3.4 ពិការភាព Disability* | | |
| 49 | ចំនួនសេវាមូលដ្ឋានផ្តល់ដោយរដ្ឋាភិបាលដល់កុមារពិការ<br>Number of basic services for children with disabilities provided by the Government | | DAC |
| 50 | ចំនួនកុមារពិការបែងចែកតាមអាយុភេទប្រភេទនៃពិការភាពទីកន្លែងនិងសង្គមសេដ្ឋកិច្ច<br>Number of children with disabilities disaggregated by age, sex and type of disability by location and socio-economic backgrounds | | DAC |
| 51 | ចំនួនអ្នកជំនាញសុខភាពដែលមានការបណ្តុះបណ្តាលក្នុងការផ្តល់សេវាសុខភាពដល់កុមារពិការបែងចែកតាមទីកន្លែង<br>Number of health specialists trained to provide health services to children with disabilities by location | | DAC |
| 52 | ចំនួនគ្រូបង្រៀនដែលបានបណ្តុះបណ្តាលពីវិធីធ្វើការជាមួយប្រភេទផ្សេងៗគ្នានៃកុមារពិការ<br>Number of teachers trained on working with children with different types of disabilities | | DAC |
| 53 | ចំនួនកម្មវិធីលើកកម្ពស់ការយល់ដឹងជាសាធារណៈតាមប្រព័ន្ធផ្សព្វផ្សាយអំពីសិទ្ធិកុមារពិការ<br>Number of public awareness media programs to raise awareness of the rights of children with disabilities | | DAC |
| | *3.5 ជំងឺអេដស៍ HIV/AIDS* | | |
| 54 | អត្រាប្រេវ៉ាឡង់ជំងឺអេដស៍បែងចែកតាមអាយុ និងភេទ<br>Prevalence of HIV/AIDS by age and gender | | NCHADS |
| 55 | ចំនួនកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីសុខភាពបន្តពូជនិងជំងឺអេដស៍ដល់កុមារ<br>Number of awareness programs on reproductive health and HIV/AIDS for children | | NCHADS |
| 56 | ចំនួនភាគរយនៃស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍ទទួលបាននូវថ្នាំពន្យាART<br>Percentage of HIV+ pregnant women receiving ART for PMTCT | MOH_HIV Sentinel Surveilance | |
| | *3.6 ភាពរបួសស្នាម Injury* | | |
| 57 | ចំនួនកុមារស្លាប់បែងចែកតាមអាយុ ភេទ មូលហេតុនៃការស្លាប់ និងទីកន្លែង (ទីប្រជុំជន និងជនបទ) | MoI | |

| | | | |
|---|---|---|---|
| | Number of child deaths by age, sex, cause of death, and location (urban and rural) | | |
| | *3.7 ទឹកស្អាត និងអនាម័យ Water and Sanitation* | | |
| 58 | អត្រាសមាមាត្រគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់<br>Proportion of household having latrine | CSES | |
| 59 | អត្រាសមាមាត្រគ្រួសារដែលមានប្រភពទឹកស្អាតប្រើប្រាស់<br>Proportion of household having drinking water source | CSES | |
| | **4. ផ្នែកសង្គម SOCIAL** | | |
| | *4.1 ការថែទាំជំនួស Alternative care* | | |
| 60 | អង្គការដែលទទួលវិញ្ញាបនបត្រជាអង្គការសុវត្ថិភាពកុមារ<br>Organizations that receive child safety certification organization | | MoSVY |
| 61 | កុមារដែលទទួលបានការថែទាំជំនួសនៅតាមសហគមន៍ ត្រូវបានកំណត់អត្តសញ្ញាណ<br>Children who receive a replacement Care in Communities be identified | | MoSVY |
| 62 | ឃុំ/សង្កាត់ដែលបានដាក់បញ្ចូលបញ្ហាកុមារកំព្រា និងកុមារងាយរងគ្រោះទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន<br>Commune / Sangkat issues orphans And vulnerable children in the Development Plan And its investment program | | MoSVY |
| | *4.2 ចំណាកស្រុក Migration* | | |
| 63 | ជនរងគ្រោះដោយអំពើជួញដូរដែលត្រូវបានធ្វើមាតុភូមិនិវត្តន៍<br>Victims of trafficking who were repatriated | | MoSVY |
| | *4.4 កិច្ចការពារ Protection* | | |
| 64 | ជនរងគ្រោះដោយអំពើជួញដូរដែលត្រូវបានជួយគាំពារ និងជួយសង្គ្រោះ<br>Victims of trafficking who are supported and rescue | | MoSVY |
| 65 | កុមារទំនាស់នឹងច្បាប់នៅក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគារទាំង5 ដែលទទួលបានសេវាស្តារនីតិសម្បទា<br>Children conflict the law in correctional centers and 5 prisons who receive rehabilitation services | | MoSVY |
| 66 | កុមារតាមម្តាយក្នុងមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ<br>Child mothers in correctional centers and prisons | | MoSVY |

--------------------------

ឧបសម្ព័ន្ធទី៥៖ បញ្ជីសូចនាករតាមក្រសួង ស្ថាប័ន ដែលត្រូវដាក់បញ្ចូលក្នុងប្រព័ន្ធ CPMIS

## ក្រសួងមហាផ្ទៃ មានសូចនាករចំនួន ១០៖

១. សមាមាត្រនៃឃុំ សង្កាត់ដែលមានជំនួយការរដ្ឋបាលឃុំ សង្កាត់ដែលទទួលខុសត្រូវចំពោះកិច្ចការពារកុមារ

២. ភាគរយនៃអ្នកមានវិជ្ជាជីវៈក្នុងវិស័យយុត្តិធម៌ដែលបានទទួលវិញ្ញាបនបត្របញ្ជាក់ និងដោះស្រាយករណី ក)ជនល្មើស និង ខ)ជនរងគ្រោះជាអនីតិជន

៣. ភាគរយនៃថវិកាកិច្ចការពារកុមារ ធៀបនឹងថវិកាជាតិ

៤. ភាគរយនៃឃុំ សង្កាត់ដែលបានរៀបចំផែនការសកម្មភាព និងផែនការថវិកាសម្រាប់ការងារទាក់ទងនឹងកិច្ចការពារកុមារ

៥. សមាមាត្រនៃកុមារដែលមានអាយុក្រោម ៥ឆ្នាំបានចុះបញ្ជីកំណើតជាមួយអាជ្ញាធរមូលដ្ឋាន

6. ចំនួនបុគ្គលដែលត្រូវបានចាប់ខ្លួន និងកាត់ទោសពីបទឧក្រិដ្ឋកម្មលើកុមារ(រាប់បញ្ចូលករណីជួញដូរ)

7. ចំនួនកុមារដែលត្រូវបានជួញដូរទៅក្នុងទម្រង់ផ្សេងៗគ្នា ក្នុងចំណោមកុមារ ១០០.០០០នាក់

8. ចំនួនកុមារជាប់ឃុំ ក្នុងចំណោមកុមារ ១០០.០០០នាក់ រាប់បញ្ចូលទាំងកុមារកំពុងជាប់ឃុំបណ្តោះអាសន្នផងដែរ

9. ចំនួនកុមារដែលធំឡើងនៅក្នុងពន្ធនាគារដោយសារពួកគេនៅជាមួយឪពុកម្តាយ/អ្នកថែទាំដែលជាប់ឃុំ

10. ចំនួនកុមាររងគ្រោះដោយមនុស្សឃាតដោយចេតនា ក្នុងចំណោមកុមារ ១០០.០០០នាក់(អត្រាមនុស្សឃាត)

## ក្រសួងយុត្តិធម៌មានសូចនាករចំនួន ៣៖

១១. ច្បាប់ការពារកុមារពីទណ្ឌកម្មលើរាងកាយ និងអំពើហិង្សាក្នុងគ្រួសារ ត្រូវបានពិនិត្យ និងធ្វើវិសោធនកម្ម ដោយអនុលោមតាមបទដ្ឋានអន្តរជាតិ

១២. ច្បាប់ដែលផ្តន្ទាទោសចំពោះអំពើរំលោភបំពាន និងអំពើធ្វើអាជីវកម្មផ្លូវភេទកុមារ ត្រូវបានពិនិត្យ និងធ្វើវិសោធនកម្ម ដោយអនុលោមតាមបទដ្ឋានអន្តរជាតិ

១៣. ភាគរយនៃចំនួនកុមារី និងកុមារាអាយុក្រោម១៨ឆ្នាំ ដែលមានទំនាក់ទំនងជាមួយប្រព័ន្ធយុត្តិធម៌ និងអាជ្ញាធររដ្ឋបាលក្នុងឆ្នាំកន្លងទៅ ដែលបានទទួល៖ ក)កិច្ចគាំទ្រឯកទេស ខ)កិច្ចគាំទ្រពី ការបង្វែរការជាប់ឃុំ ឬស្តារឡើងវិញ ជំនួសឲ្យការឃុំខ្លួន

## ក្រសួងផែនការ មានសូចនាករចំនួន ១៥៖

១៤. ការប៉ាន់ប្រមាណប្រេវ៉ាឡង់ជាតិ សម្រាប់ទម្រង់សំខាន់ៗនៃអំពើហិង្សាលើកុមារ និងបញ្ហាកិច្ចការពារកុមារដទៃទៀត

១៥. ភាគរយនៃអ្នកថែទាំដែលយល់ស្របទៅនឹងភាពចាំបាច់ក្នុងការប្រើប្រាស់ទណ្ឌកម្មលើរាងកាយសម្រាប់ការចិញ្ចឹមកុមារ

១៦. ភាគរយនៃកុមារី និងកុមារាអាយុចន្លោះពី១-១៧ឆ្នាំ ដែលបានទទួលបទពិសោធន៍នៃវិធីសាស្ត្រអនុវត្តដាក់ពិន័យអហិង្សាណាមួយពីសំណាក់អ្នកថែទាំក្នុងរយៈពេល១ខែចុងក្រោយ ដោយបែងចែកទៅតាមភេទ និងអាយុរបស់កុមារ

១៧. ភាគរយនៃកុមារអាយុចន្លោះពី១៣-១៧ឆ្នាំ ដែលបានស្វែងរកជំនួយពីស្ថាប័ន ឬជំនួយពីអ្នកវិជ្ជាជីវៈសម្រាប់អំពើហិង្សា ក្នុងចំណោមកុមារដែលរាយការណ៍ឱ្យដឹងថាបានទទួលរងអំពើហិង្សាប្រភេទណាមួយ

១៨. ភាគរយ (%) នៃកុមារី និងកុមារា អាយុចន្លោះពី១៣-១៧ឆ្នាំ ដែលធ្លាប់ទទួលរងអំពើហិង្សាផ្លូវភេទណាមួយ និងបានស្វែងរកជំនួយពីអ្នកវិជ្ជាជីវៈ

១៩. ភាគរយនៃកុមារពិការភាពត្រូវបានកំណត់អត្តសញ្ញាណ ប្រភេទ និងកម្រិតពិការភាព

២០. ភាគរយនៃស្ត្រី និងបុរសអាយុចន្លោះពី១៥-៤៩ឆ្នាំ ដែលយល់ស្របថាការដែលប្តី/ដៃគូវាយដំប្រពន្ធរបស់ខ្លួន(ដៃគូរបស់ខ្លួន) គឺជារឿងត្រឹមត្រូវ

២១. កុមារដែលស្ថិតនៅក្រោមបន្ទាប់ភាពក្រីក្ររបស់ជាតិ

២២. ការប៉ាន់ប្រមាណចំនួនកុមារកំពុងរស់នៅក្នុងគ្រួសារក្នុងចំណាត់ថ្នាក់ក្រីក្រកម្រិត១ និងក្រីក្រកម្រិត២

២៣. ភាគរយនៃកុមារអាយុក្រោម១៨ឆ្នាំ ដែលមិនរស់នៅជាមួយឳពុកម្តាយបង្កើតរបស់ពួកគេ បើទោះបីយ៉ាងហោច ណាស់មានឳពុក ឬម្តាយម្នាក់ដែលនៅរស់ក៏ដោយ

២៤. ករណីអំពើហិង្សាផ្លូវកាយ និង/ឬ ផ្លូវចិត្តក្នុងចំណោមកុមារ ដែលប្រព្រឹត្តដោយអ្នកថែទាំក្នុងរយៈពេល១ខែកន្លងមក

២៥. ករណីអំពើហិង្សាផ្លូវភេទក្នុងវ័យកុមារ ដែលប្រព្រឹត្តដោយចារីណាមួយក្នុងរយៈពេល១ឆ្នាំកន្លងមក

២៦. ករណីអំពើហិង្សាផ្លូវភេទក្នុងវ័យកុមារនាពេលណាមួយក្នុងជីវិត ដែលប្រព្រឹត្តដោយចារីណាម្នាក់

២៧. សមាមាត្រនៃស្ត្រី និងកុមារីធ្លាប់មានដៃគូ អាយុចាប់ពី១៥ឆ្នាំឡើងទៅ ដែលបានទទួលរងអំពើហិង្សាផ្លូវកាយ និង/ឬ ផ្លូវភេទ ដោយដៃគូស្និទ្ធស្នាល បច្ចុប្បន្ន ឬអតីត ក្នុងរយៈពេល១២ខែកន្លងមក

២៨. ភាគរយនៃក្មេងជំទង់ស្រី និងប្រុស ដែលធ្លាប់ទទួលរងការសម្លុតគំរាមកំហែងក្នុងរយៈពេល១២ខែកន្លងមក

## ក្រសួងការងារ បណ្តុះបណ្តាល និងវិជ្ជាជីវៈ មានសូចនាករចំនួន ៣៖

២៩. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយស្តីពីពលកម្មកុមារ រួមទាំងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ត្រូវបានអនុវត្តដោយអនុលោមតាមបទដ្ឋានអន្តរជាតិ

៣០. ភាគរយនៃកុមារអាយុចន្លោះពី៥-១៧ឆ្នាំ ដែលកំពុងធ្វើពលកម្មកុមារ រាប់បញ្ចូលពលកម្មក្នុងទម្រង់គ្រោះថ្នាក់ផងដែរ

៣១. ភាគរយនៃស្ត្រី និងកុមារីអាយុចន្លោះពី១៥-១៩ឆ្នាំ ដែលបានផ្តល់កំណើតមុនអាយុ១៥ឆ្នាំ និងភាគរយនៃស្ត្រីអាយុ ចន្លោះពី២០-២៤ឆ្នាំ ដែលបានផ្តល់កំណើតមុនអាយុ១៨ឆ្នាំ ៖ ការធ្លាប់មានកូនមុនអាយុ១៥ឆ្នាំនិង១៨ឆ្នាំ

## ក្រសួងអប់រំ យុវជន និងកីឡា មានសូចនាករចំនួន ២៖

៣២. ភាគរយនៃគ្រូបង្រៀនដែលបានទទួលការបណ្តុះបណ្តាលអំពីការអនុវត្តដាក់ពិន័យបែបវិជ្ជមាន

៣៣. ទណ្ឌកម្មលើរាងកាយដែលប្រព្រឹត្តដោយគ្រូបង្រៀនក្នុងរយៈពេល១ឆ្នាំកន្លងមក

## ក្រសួងកិច្ចការនារី មានសូចនាករចំនួន ១៖

៣៤. ចំនួនម្តាយ និងឳពុក និងអ្នកថែទាំដែលបានទទួលការអប់រំពីកម្មវិធីចិញ្ចឹមកូនបែបវិជ្ជមាន

## ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) មានសូចនាករចំនួន ១៖

៣៥. ភាគរយនៃមូលនិធិកិច្ចការពារកុមារដែលផ្តល់ដោយអង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ

## អាជ្ញាធរមីន មានសូចនាករចំនួន ២៖

៣៦. ភាគរយនៃកុមារី និងកុមារានៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយមីន និងគ្រឿងផ្ទុះដទៃទៀត ដែលត្រូវបានផ្តល់ អន្តរាគមន៍បង្ការ និងអន្តរាគមន៍ផ្តល់ជំនួយដល់ជនរងគ្រោះដែលពាក់ព័ន្ធ

៣៧. ចំនួនកុមារដែលរបួស ឬស្លាប់ដោយមីន/IEDs

## អាជ្ញាធរប្រយុទ្ធប្រឆាំងជម្ងឺអេដស៍ មានសូចនាករចំនួន ១៖

៣៨. ការប៉ាន់ប្រមាណចំនួនកុមារផ្ទុកមេរោគអេដស៍/ជំងឺអេស៍

## ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានសូចនាករចំនួន ២៤៖

៣៩. ច្បាប់ស្តីពីកិច្ចការពារកុមារត្រូវបានបង្កើតឡើង

៤០. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងគោលនយោបាយទាក់ទងនឹងការឆ្លើយតបរបស់ស្ថាប័ន និងអ្នកមានភារកិច្ចចំពោះ កិច្ចការពារកុមារ ត្រូវបានរៀបចំ

៤១. ប្រព័ន្ធធានាគុណភាពសម្រាប់ការងារសេវាសង្គម ត្រូវបានដំណើរការ
៤២. ផែនការតាមវិស័យ និងអនុវិស័យស្តីពីកិច្ចការពារកុមារ ត្រូវបានបង្កើត
៤៣. គោលនយោបាយថែទាំជំនួសចំពោះកុមារឆ្នាំ២០០៦ ត្រូវបានពិនិត្យឡើងវិញ ដោយធ្វើឱ្យមានសង្គតភាពទៅនឹងគោលការណ៍ណែនាំរបស់អង្គការសហប្រជាជាតិ សម្រាប់ការថែទាំជំនួសចំពោះកុមារឆ្នាំ២០០៩
៤៤. ប្រព័ន្ធកិច្ចការពារកុមារដែលមានតួនាទី និងការទទួលខុសត្រូវដើម្បីដឹកនាំការឆ្លើយតប និងដំណើរការផ្តល់សេវាបញ្ជូនតាមលក្ខណៈស្តង់ដារដល់កុមារមានបញ្ហាផ្នែកកិច្ចការពារកុមារ ត្រូវបានដំណើរការ
៤៥. យន្តការសម្របសម្រួលវិស័យកិច្ចការពារកុមារជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធនៅកម្រិតថ្នាក់ជាតិ ត្រូវបានរៀបចំ
៤៦. ចំនួនបុគ្គលិកសង្គមកិច្ចដែលផ្តល់សេវាការពារកុមារ
៤៧. ចំនួនបុគ្គលិកសង្គមដែលបានបញ្ចប់ការបណ្តុះបណ្តាលផ្នែកសង្គមកិច្ច
៤៨. ប្រព័ន្ធទិន្នន័យរដ្ឋបាលដែលតាមដានទិន្នន័យទាក់ទងនឹងកិច្ចការពារកុមារ
៤៩. ភាគរយនៃនៃកុមារី និងកុមារអាយុចន្លោះពី០-១៧ឆ្នាំ ដែលរស់នៅជាមួយគ្រួសារដែលបានទទួលបានការឧបត្ថម្ភពីកម្មវិធីផ្ទេរសាច់ប្រាក់ ឬទទួលបានការឧបត្ថមពីកម្មវិធីគាំពារសង្គមដ៏ទៃទៀត
៥០. ភាគរយនៃកន្លែងថែទាំជំនួស រួមមានការថែទាំតាមមណ្ឌល និងការថែទាំតាមគ្រួសារ ត្រូវបានធ្វើអធិការកិច្ច ដោយអនុលោមទៅតាមបទដ្ឋានអប្បបរមាដែលកំណត់ដោយក្រសួងស.អ.យ
៥១. ចំនួនកុមារដែលត្រូវបានរាយការណ៍ឱ្យដឹងថាមានបញ្ហាកង្វល់ផ្នែកកិច្ចការពារកុមារ តាមរយ hotline
៥២. ចំនួនអ្នកផ្តល់សេវាថែទាំជំនួសនៅក្នុងប្រទេស
៥៣. ចំនួនកុមារដែលកំពុងរស់នៅក្រោមការថែទាំជំនួស
៥៤. ចំនួនកុមារដែលត្រូវបានបង្រួបបង្រួមគ្រួសារ ឬសមាហរណកម្ម
៥៥. ចំនួនកុមារដែលកំពុងរស់នៅក្នុងកន្លែងថែទាំជំនួសដែលបានទទួលការគ្រប់គ្រងករណី
៥៦. ចំនួនកុមារស្ថិតក្នុងការថែទាំដោយគ្រួសារសាច់ញាតិ
៥៧. ចំនួនកុមារស្ថិតក្នុងការថែទាំដោយគ្រួសារធម៌
៥៨. ចំនួនកុមារដែលត្រូវបានសម្រេចជាកម្មវត្ថុសុំកូនក្នុងប្រទេស
៥៩. ចំនួនកុមារដែលត្រូវបានស្វែងរកគ្រួសារល្អសម្រាប់សុំកូនអន្តរប្រទេស
៦០. ចំនួនកុមារដែលបានទទួលសេវាគ្រប់គ្រងករណីដោយបុគ្គលិកសង្គមកិច្ច
៦១. ចំនួនកុមារដែលបានទទួលរងអំពើហិង្សាដែលត្រូវបានផ្តល់សេវាសុខភាពសង្គម ឬសេវាយុត្តិធម៌/សេវាអនុវត្តច្បាប់
៦២. ចំនួនកុមារកំពុងរស់នៅ ឬធ្វើការតាមចិញ្ចើមថ្នល់

---------------------------

ឧបសម្ព័ន្ធទី៦៖សូចនាករនៅក្នុងប្រព័ន្ធទិន្នន័យ ឃុំសង្កាត់

| ឯកសារព័ត៌មានស្តីអំពីស្ថានភាពឃុំ/សង្កាត់ | | សូចនាករពាក់ព័ន្ធនិងសិទ្ធិកុមារ | | |
|---|---|---|---|---|
| ផ្នែកសង្គមកិច្ច | | | | |
| 1 | ស្ថានភាពកំរិតមត្តេយ្យសិក្សា | Yes | No | ប្រភព |
| 1.1 | ចំនួនកន្លែងមត្តេយ្យសហគមន៍ | | | |
| 1.2 | ចំនួនបន្ទប់មត្តេយ្យសហគមន៍ | | | |
| 1.3 | ចំនួនថ្នាក់មត្តេយ្យសហគមន៍ | | | |
| 1.4 | ចំនួនគ្រូបង្រៀនមត្តេយ្យសហគមន៍ | | | |
| 1.5 | ចំនួនគ្រូស្ត្រីបង្រៀនមត្តេយ្យសហគមន៍ | | | |
| 1.6 | ចំនួនសាលាមត្តេយ្យរដ្ឋនិងឯកជន | | | |
| 1.7 | ចំនួនបន្ទប់មត្តេយ្យរដ្ឋនិងឯកជន | | | |
| 1.8 | ចំនួនថ្នាក់មត្តេយ្យរដ្ឋនិងឯកជន | | | |
| 1.9 | ចំនួនគ្រូបង្រៀនមត្តេយ្យរដ្ឋនិងឯកជន | | | |
| 1.10 | ចំនួនគ្រូស្ត្រីបង្រៀនមត្តេយ្យរដ្ឋនិងឯកជន | | | |
| 2 | ស្ថានភាពកុមារចូលរៀនកំរីតមត្តេយ្យសិក្សា | | | |
| 2.1 | កុមារអាយុពី៣-៥ឆ្នាំរៀនថ្នាក់មត្តេយ្យ( ទាំងអស់ ) | | | |
| 2.2 | កុមារអាយុពី៣-៥ឆ្នាំរៀនថ្នាក់មត្តេយ្យសហគមន៍ | | | |
| 2.3 | កុមារអាយុពី៣-៥ឆ្នាំរៀនថ្នាក់មត្តេយ្យរដ្ឋនិងឯកជន | | | |
| 3 | ស្ថានភាពកំរីតសិក្សាបឋមសិក្សា | | | |
| 3.1 | ចំនួនសាលាបឋមសិក្សា | | | |
| 3.2 | ចំនួនបន្ទប់រៀនបឋមសិក្សា | | | |
| 3.3 | ចំនួនថ្នាក់រៀនបឋមសិក្សា | | | |
| 3.4 | ចំនួនគ្រូបង្រៀនសាលាបឋមសិក្សា | | | |
| 3.5 | ផលធៀបកុមារអាយុ៦-១១ឆ្នាំធៀបនិងចំនួនសាលា | | | |
| 3.6 | ផលធៀបកុមារអាយុ៦-១១ឆ្នាំធៀបនិងចំនួនបន្ទប់រៀន | | | |
| 3.7 | ផលធៀបកុមារអាយុ៦-១១ឆ្នាំធៀបនិងចំនួនថ្នាក់រៀន | | | |
| 3.8 | ផលធៀបកុមារអាយុ៦-១១ឆ្នាំធៀបនិងចំនួនគ្រូបង្រៀន | | | |
| 4 | ស្ថានភាពកុមារចូលរៀនកំរីតបឋមសិក្សា (សរុបចេញពីសៀវភៅស្ថិតិភូមិ) | | | |
| 4.1 | កុមារអាយុ៦ឆ្នាំ | | | |
| 4.2 | កុមារអាយុ៦ឆ្នាំបានចូលរៀន | | | |
| 4.3 | កុមារអាយុ៦ឆ្នាំមិនបានចូលរៀន | | | |
| 4.4 | កុមារអាយុពី៦-១១ឆ្នាំទាំងអស់ | | | |
| 4.5 | កុមារអាយុពី៦-១១ឆ្នាំកំពុងរៀន | | | |

| | | | | |
|---|---|---|---|---|
| 4.6 | កុមារអាយុពី៦-១១ឆ្នាំមិនទៅរៀន | | | |
| 4.7 | **កុមារីអាយុពី៦-១១ឆ្នាំទាំងអស់** | | | |
| 4.8 | កុមារីអាយុពី៦-១១ឆ្នាំកំពុងរៀន | | | |
| 4.9 | កុមារីអាយុពី៦-១១ឆ្នាំមិនទៅរៀន | | | |
| 4.10 | **កុមារាអាយុពី៦-១១ឆ្នាំទាំងអស់** | | | |
| 4.11 | កុមារាអាយុពី៦-១១ឆ្នាំកំពុងរៀន | | | |
| 4.12 | កុមារាអាយុពី៦-១១ឆ្នាំមិនទៅរៀន | | | |
| 5 | ស្ថានភាពកំរិតសិក្សាអនុវិទ្យាល័យដែលមាននៅក្នុងឃុំសង្កាត់ | | | |
| 5.1 | ចំនួនសាលាអនុវិទ្យាល័យ | | | |
| 5.2 | ចំនួនបន្ទប់រៀនសាលាអនុវិទ្យាល័យ | | | |
| 5.3 | ចំនួនថ្នាក់រៀនសាលាអនុវិទ្យាល័យ | | | |
| 5.4 | ចំនួនគ្រូបង្រៀនសាលាអនុវិទ្យាល័យ | | | |
| 5.5 | ផលធៀបកុមារអាយុ១២ទៅ១៤ឆ្នាំធៀបនិងចំនួនសាលា | | | |
| 5.6 | ផលធៀបកុមារអាយុ១២ទៅ១៤ឆ្នាំធៀបនិងចំនួនបន្ទប់រៀន | | | |
| 5.7 | ផលធៀបកុមារអាយុ១២ទៅ១៤ឆ្នាំធៀបនិងចំនួនថ្នាក់រៀន | | | |
| 5.8 | ផលធៀបកុមារអាយុ១២ទៅ១៤ឆ្នាំធៀបនិងគ្រូបង្រៀន | | | |
| 5.9 | ចំងាយមធ្យមពីចំនុចកណ្តាលភូមិទៅសាលាអនុវិទ្យាល័យ | | | |
| 6 | ស្ថានភាពកុមារចូលរៀនកម្រិតអនុវិទ្យាល័យ | | | |
| 6.1 | **កុមារអាយុពី១២-១៤ឆ្នាំទាំងអស់** | | | |
| 6.2 | កុមារអាយុពី១២-១៤ឆ្នាំកំពុងរៀន | | | |
| 6.3 | កុមារអាយុពី១២-១៤ឆ្នាំមិនទៅរៀន | | | |
| 6.4 | **កុមារីអាយុពី១២-១៤ឆ្នាំទាំងអស់** | | | |
| 6.5 | កុមារីអាយុពី១២-១៤ឆ្នាំកំពុងរៀន | | | |
| 6.6 | កុមារីអាយុពី១២-១៤ឆ្នាំមិនទៅរៀន | | | |
| 6.7 | **កុមារាអាយុពី១២-១៤ឆ្នាំទាំងអស់** | | | |
| 6.8 | កុមារាអាយុពី១២-១៤ឆ្នាំកំពុងរៀន | | | |
| 6.9 | កុមារាអាយុពី១២-១៤ឆ្នាំមិនទៅរៀន | | | |
| 7 | ស្ថានភាពកំរិតសិក្សាថ្នាក់វិទ្យាល័យដែលមាននៅក្នុងឃុំសង្កាត់ | | | |
| 7.1 | ចំនួនសាលាកំរិតវិទ្យាល័យនៅក្នុងឃុំ | | | |
| 7.2 | ចំនួនបន្ទប់រៀនកំរិតវិទ្យាល័យនៅក្នុងឃុំ | | | |
| 7.3 | ចំនួនថ្នាក់រៀនកំរិតវិទ្យាល័យនៅក្នុងឃុំ | | | |
| 7.4 | ចំនួនគ្រូបង្រៀននៅថ្នាក់វិទ្យាល័យនៅក្នុងឃុំ | | | |
| 7.5 | ផលធៀបយុវជនអាយុ១៥ទៅ១៧ឆ្នាំធៀបនិងចំនួនសាលា | | | |
| 7.6 | ផលធៀបយុវជនអាយុ១៥ទៅ១៧ឆ្នាំធៀបនិងចំនួនបន្ទប់រៀន | | | |

| | | | | |
|---|---|---|---|---|
| 7.7 | ផលធៀបយុវជនអាយុ១៥ទៅ១៧ឆ្នាំធៀបនិងចំនួនថ្នាក់រៀន | | | |
| 7.8 | ផលធៀបយុវជនអាយុ១៥ទៅ១៧ឆ្នាំធៀបនិងចំនួនគ្រូបង្រៀន | | | |
| 8 | **ស្ថានភាពយុវជនអាយុពី "១៥-១៧"ឆ្នាំមិនបានទៅរៀន** | | | |
| 8.1 | ចំនួនយុវជនអាយុពី១៥-១៧ឆ្នាំ | | | |
| 8.2 | ចំនួនយុវជនអាយុពី១៥-១៧ឆ្នាំមិនទៅរៀន | | | |
| 8.3 | ភាគរយយុវជនអាយុពី១៥-១៧ឆ្នាំមិនទៅរៀន | | | |
| 9 | **កម្មវិធីអក្ខរកម្ម( ស្ថិតិឃុំ)** | | | |
| 9.1 | ថ្នាក់អក្ខរកម្មកំពុងដំណើរការ | | | |
| 9.2 | ចំនួនសិស្សអក្ខរកម្មកំពុងរៀន | | | |
| 9.3 | ថ្នាក់អក្ខរកម្មបានបញ្ចប់ | | | |
| 9.4 | ចំនួនសិស្សអក្ខរកម្មបានបញ្ចប់ | | | |
| 9.5 | ចំនួនសិស្សអក្ខរកម្មបានបញ្ចប់ដោយប្រឡងជាប់ | | | |
| 10 | **ស្ថានភាពអនក្ខរជន** | | | |
| 10.1 | អ្នកមិនចេះអក្សរសរុបអាយុពី១៥-៦០ឆ្នាំ | | | |
| 10.2 | ស្ត្រីមិនចេះអក្សរអាយុពី១៥-៦០ឆ្នាំ | | | |
| 10.3 | អ្នកមិនចេះអក្សរសរុបអាយុពី១៥-១៧ឆ្នាំ | | | |
| 10.4 | ស្ត្រីមិនចេះអក្សរអាយុពី១៥-១៧ឆ្នាំ | | | |
| 10.5 | អ្នកមិនចេះអក្សរសរុបអាយុពី១៨-២៤ឆ្នាំ | | | |
| 10.6 | ស្ត្រីមិនចេះអក្សរអាយុពី១៨-២៤ឆ្នាំ | | | |
| 10.7 | អ្នកមិនចេះអក្សរសរុបអាយុពី២៥-៦០ឆ្នាំ | | | |
| 10.8 | ស្ត្រីមិនចេះអក្សរអាយុពី២៥-៦០ឆ្នាំ | | | |
| 11 | **ស្ថានភាពសុខភាពស្ត្រីនិងកុមារ** | | | |
| 11.1 | ចំនួនស្ត្រីបានសំរាលកូនក្នុងឆ្នាំ | | | |
| 11.2 | ចំនួនស្ត្រីសំរាលកូនដោយឆ្មបបុរាណ | | | |
| 11.3 | %ស្ត្រីដែលសំរាលកូនដោយឆ្មបបុរាណ | | | |
| 11.4 | ចំនួនមរណភាពមាតាក្រោយពេលសំរាលកូន ( ០-១ខែ ) | | | |
| 11.5 | ចំនួនទារកបានកើតក្នុងឆ្នាំ | | | |
| 11.6 | ចំនួនមរណភាពទារកអាយុពី០-១ខែ | | | |
| 11.7 | ចំនួនមរណភាពកុមារអាយុពី៥ឆ្នាំចុះ | | | |
| 11.8 | ចំនួនកុមារអាយុពី៩ខែ-១ឆ្នាំក្នុងឆ្នាំ | | | |
| 11.9 | ចំនួនកុមារអាយុពី៩ខែ-១ឆ្នាំមិនបានចាក់ថ្នាំបង្ការគ្រប់ចំនួន | | | |
| 11.10 | %កុមារអាយុពី៩ខែ-១ឆ្នាំមិនបានចាក់ថ្នាំបង្ការគ្រប់ចំនួន | | | |
| 12 | **ប្រភេទជនងាយរងគ្រោះ** | | | |
| 12.1 | ចំនួនជនរងគ្រោះដោយសារការរំលោភផ្លូវភេទ | | | |

| | | | | |
|---|---|---|---|---|
| 12.2 | ចំនួនជនរងគ្រោះដោយសារជួញដូរមនុស្ស | | | |
| 12.3 | ចំនួនគ្រួសារដែលមានសមាជិកប្រើប្រាស់គ្រឿងញៀន | | | |
| 12.4 | ចំនួនគ្រួសារដែលមានសមាជិកកើតជំងឺអេដស៍ | | | |
| 12.5 | ចំនួនកុមារកំព្រាអាយុក្រោម១៨ឆ្នាំដោយសារអេដស៍ | | | |
| 12.6 | ចំនួនកុមារកំព្រាអាយុក្រោម១៨ឆ្នាំ( ទូទៅគ្រប់ករណី ) | | | |
| 12.7 | ចំនួនមនុស្សចាស់ជរាគ្មានទីពឹង | | | |
| 12.8 | ចំនួនជនពិការអាចរកចំណូលបាន | | | |
| 12.9 | ចំនួនជនពិការមិនអាចរកចំណូលបាន | | | |
| 12.10 | ចំនួនជនពិការអាយុក្រោម១៨ឆ្នាំ | | | |
| 12.11 | ចំនួនគ្រួសារដែលរងគ្រោះដោយគ្រោះធម្មជាតិ | | | |
| 12.12 | ចំនួនជនរងគ្រោះដោយសារគ្រាប់មីននិងយុទ្ធភណ្ឌមិនទាន់ផ្ទុះ | | | |

-----------------------------------